
កំណាព្យតបគុណ



រៀបរៀងដោយ

ខ្ចុំព្រះករុណា

សាមណេរ សា ចាន់ភ័ត

ផ្សាយចេញពីក្រុមយុវសមណអ្នកនិពន្ធ

- ឈ្មោះសៀវភៅ : **កំណាព្យតបគុណ**
- រៀបរៀងដោយ : សាមណេរ **សា ចាន់រ៉ាត់**
- ឧបត្ថម្ភដោយ : ពុទ្ធបរិស័ទ និងក្រុមញាតិ
- ធ្វើចេញពីមាតុភូមិខ្ញុំ : **វត្តសោតណារាម** ភូមិស្រែល្អ ឃុំគោក-រមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ នៃព្រះរាជាណាចក្រកម្ពុជា
- កាលបរិច្ឆេទធ្វើចប់ : ថ្ងៃសៅរ៍ ១៥ កើត ខែបុស្ស ឆ្នាំរោង ចត្វាស័ក ព.ស. ២៥៥៦ ត្រូវនឹងថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០១៣
- បោះពុម្ពលើកទី ១ : ចំនួន ២០០ ក្បាល
- មួយក្បាលតម្លៃ : ៣.៣០០ រៀល
- អស់ទឹកប្រាក់ចំនួន : ៦៦០.០០០ រៀល= ១៦៥ ដុល្លារ
- រោងពុម្ពឈ្មោះ : **ម៉ៅ ផុន** (ភ្នំពេញ)
- ចែកផ្សាយក្នុងឱកាស : បុណ្យកឋិនវត្តទី និងឆ្លងចេតិយ
- ការផ្សាយរបស់ : ក្រុមឃុំសមណអ្នកនិពន្ធ
- ផ្តល់មតិយោបល់ : ម្ចាស់សៀវភៅផ្ទាល់
- Telephone : 098 370 097 / 087 370 097 / 017 809 650
- Facebook : Sa Chanratt@yahoo.com
- E-mail : chanratt_sa@yahoo.com
- កម្មសិទ្ធិរបស់ : ក្រុមឃុំសមណអ្នកនិពន្ធ

អារម្ភកថា

ដួងព្រះចន្ទ្រានារាត្រីថ្ងៃ ១៥ កើតគ្មានស្បៃពពកបិទបាំង ឬរារាំង កំពុងតែបញ្ចេញពន្លឺមកលើផ្ទៃនៃផែនដីបែបស្រទន់ ត្រចះត្រចង់ ឥតមានចន្លោះត្រង់ណា ឬអគតិ (លម្អៀង) ចំពោះបុគ្គលណាឡើយ និងមិនមានការសោកស្តាយរស្មីរបស់ខ្លួនមានឧបមាយ៉ាងណា ទឹកចិត្តនៃបុព្វការីជនទាំងឡាយមានមាតាបិតាជាដើម ដែលតែងតែមានសេចក្តីសន្តោសប្រោសប្រណីមកលើបុត្រធីតារបស់ខ្លួន ដោយព្រហ្មវិហារធម៌បួន សង្គហ-ធម៌ប្រាំ ព្រមទាំងបានធ្វើពលីកម្មសព្វគ្រប់បែបយ៉ាង បូជាកម្លាំងកាយចិត្តយ៉ាងច្រើនជាអនេកអនន្ត មិនអាចរាប់បានប្រមាណអស់ក៏មានឧបមាយ៉ាងនោះដែរ។

ដោយអាស្រ័យព្រះគុណដ៏ធំធេងនេះហើយ ទើបធ្វើឱ្យរូបខ្ញុំដែលត្រូវជាប្អូន ជាកូន ក្មួយ ចៅ ចៅទួត ជាសិស្សមានសេចក្តីនឹករឭកជ្រះថ្លាចំពោះព្រះគុណដ៏ក្រៃលែង ឥតយកអ្វីមកប្រៀបផ្ទឹមបានឡើយ ហើយក៏មិនអាចយកឧបករណ៍អ្វីមកវាស់វែង ថ្លឹងថ្លែងនូវគុណូបការៈដ៏មហិមានេះបានដែរ នៅពេលនេះមានតែបុញ្ញសម្បទាសព្វគ្រប់បែបប្រការ ដែលកូនចៅបានធ្វើសម្រេចហើយដោយល្អនេះ ឧទ្ទិសជូនចំពោះលោកអ្នកមានគុណទាំងឡាយតែប៉ុណ្ណោះ។

នៅវារោកាសថ្ងៃបុណ្យកឋិនតវេទី និងឆ្លងចេតិយសម្រាប់តម្កល់អដ្ឋិធាតុអ្នកមានគុណរបស់ឧបាសក **ថង ផូ** និងឧបាសិកា **សាន សឿម** នាមាតុភូមិខ្ញុំ សូមបញ្ជាក់ថា លោកទាំងពីររូបនេះហើយជាព្រះកន្លោង (ព្រះព្រហ្ម បុព្វទេវា បុព្វាចារ្យ និងអាហុនេយ្យបុគ្គល) ដ៏ច្បាស់ច្បងរបស់ខ្ញុំ

ពោលគឺលោកជាអ្នកផ្តល់កំណើតរូបរាងកាយ ចិញ្ចឹមបីបាច់ថែរក្សាឱ្យមានជីវិត បានឃើញពន្លឺរស្មីនៃទ្វីបលោកា ព្រមទាំងឱ្យកូនបានសិក្សារៀនសូត្រ និងបានចូលមកបួសបម្រើព្រះពុទ្ធសាសនាជាដើម។ ប្រសិនបើគ្មានលោកទាំងពីររូបនេះទេ រូបខ្ញុំក៏គ្មានថ្ងៃនេះដែរ «នៅលើលោកនេះ ខ្ញុំមិនទាន់រកឃើញបុរសរូបណា និងស្ត្រីរូបណាមានភក្តីភាព ស្មគ្រស្មោះ ស្នេហា ព្រមទាំងប្តូរផ្តាច់ជួយខ្ញុំ សព្វគ្រប់បែបយ៉ាងដូចជាលោកឪពុក និងអ្នកម្តាយរបស់ខ្ញុំឡើយ»។

អាស្រ័យនូវការដឹងគុណបុព្វការីជន នៃលោកអ្នកមានគុណរបស់ខ្ញុំ ដែលពួកគាត់កំពុងមានជន្មាយុរស់នៅសព្វថ្ងៃនេះ ខ្ញុំបានសូមការអនុញ្ញាតពីពួកគាត់ ដើម្បីសរសេរនូវកូនសៀវភៅមួយក្បាលឈ្មោះថា« **កំណាព្យតបគុណ**» ដោយទឹកចិត្តសោមនស្សយ៉ាងក្រៃលែង ពេលពួកគាត់ទាំងពីររូបយល់ព្រម និងត្រេកអរអនុមោទនាផងដែរ ពេលដឹងថាខ្ញុំចង់ធ្វើចង់សរសេរសៀវភៅនេះឡើង ប្រការនេះក៏ដើម្បីទុកជាធម្មបណ្ណាការ ចែកជូនពុទ្ធបរិស័ទយកទៅសិក្សារៀនសូត្រ ពិចារណា តាមសតិបញ្ញារៀងៗខ្លួន។

ខ្ញុំសង្ឃឹមទុកជាមុនថា តាមរយៈដងប៉ាកកា និងទឹកខ្មៅលេចចេញជាតួអក្ខរា រចនាបែបកំណាព្យកាព្យឃ្លោង សម្រេចរូបបានទៅជាកូនសៀវភៅនេះឡើង គង់នឹងសម្រេចបានជាប្រយោជន៍ជាក់ជាមិនខាន បើមិនតិចក៏ច្រើន បើមិនល្អក៏គង់ប្រសើរជាគ្មានសោះដែរ។

ជាអវសាននេះ ខ្ញុំសូមខន្តីអភ័យទោសានុទោសរាល់កំហុសឆ្គងដោយអចេតនាសព្វគ្រប់បែបប្រការ ដែលកើតមានក្នុងទីនេះ ព្រោះពេលវេលារៀបរៀងនេះខ្លីណាស់សម្រាប់រូបខ្ញុំ គឺត្រឹមតែ ១៥ ថ្ងៃប៉ុណ្ណោះ។

ដូច្នេះខ្ញុំរីករាយនឹងទទួលយកនូវការរិះគន់គ្រប់បែបយ៉ាង ពីលោកអ្នកសប្បុរសគ្រប់មជ្ឈដ្ឋាន និងលោកអ្នកអានគ្រប់សម័យកាលតរៀងទៅ។

វត្តសោភណារាម ភូមិស្រែល្អ ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ នៃព្រះរាជាណាចក្រកម្ពុជា

ថ្ងៃសៅរ៍ ១៥ កើត ខែបុស្ស ឆ្នាំរោង ចត្វាស័ក ព.ស. ២៥៥៦ ត្រូវនឹងថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០១៣

(រំឭកខួបវស្សាទី ៩ នៃការបព្វជ្ជាក្នុងបវរនៃព្រះពុទ្ធសាសនា)

ដោយបំណងល្អពីខ្ញុំព្រះករុណា

សាមណេរ **សា ចាន់ង៉ាត់**

(សមណានិស្សិតនៃសាកលវិទ្យាល័យ **ប្រៀលព្រាយ**)

(Student-Monk of Build Bright University)

ឧទ្ទិសកថា

ដោយអំណាចផលានិសង្សនៃកូនសៀវភៅនេះ ឬសៀវភៅមុនៗ និងមហាកុសលថ្នាក់បព្វជ្ជាអស់រយៈពេល ៩ វស្សាមកត្រឹមជន្មាយុ ២៦ ឆ្នាំរបស់ខ្ញុំនេះ ព្រមទាំងបុណ្យកុសលដទៃៗទៀតដូចជា ការសម្តែងធម៌ទេសនាតាមបុណ្យនានា ឬតាមរលកវិទ្យុនានាអស់រយៈពេលជាង ៣ ឆ្នាំកន្លងមកនេះ ឬបុណ្យកុសលថ្នាក់អាមិសទានផ្សេងៗទៀត សម្រេចបានទៅជាបុណ្យកុសល ចូរកើតមានដល់លោកឪពុក **ថង ថូ** អ្នកម្តាយ **សាន សឿម** អ្នកមីង **ថង រឹត** (សហរដ្ឋអាមេរិក) លោកតា **ខែ សាន** លោកយាយ **ប្ង យាន** លោកតា **ថង សា** លោកយាយ **អ្ង ក** បងប្អូនញាតិមិត្ត លោកអ៊ំ អ្នកមីង លោកមា លោកគ្រូអ្នកគ្រូ ព្រះឧបជ្ឈាយាចារ្យ ព្រះមហាក្សត្រ និងពុទ្ធបរិស័ទទាំងបព្វជិត គ្រហស្ថ នាម៉ឺនសព្វមុខមន្ត្រី បងប្អូនជនរួមជាតិ រួមពុទ្ធសាសនាដែលកំពុងតែរស់នៅទាំងក្នុង និងក្រៅប្រទេស ពិសេសគឺអស់លោកអ្នកទាំងឡាយ ដែលកំពុងតែកាន់សៀវភៅនេះតែម្តង ព្រមទាំងញាតិមិត្តសព្វសត្វទាំងអស់ដែលបានចែកស្ថានទៅហើយក្តី សូមឱ្យបានជួបប្រសព្វតែសេចក្តីសុខក្សេមក្សាន្ត និងសម្រេចបដោយពុទ្ធពរទាំងឡាយ ៤ ប្រការគឺ អាយុ ១ វណ្ណៈ ១ សុខៈ ១ ពលៈ ១ ព្រមទាំងសម្បត្តិទាំងឡាយ ៣ សម្បត្តិមនុស្ស ១ សម្បត្តិទេវតា ១ ព្រមទាំងសម្បត្តិព្រះនិព្វាន ១ កុំបីប្រែក្លាយទៅជាប្រការដទៃឡើយ។ សូមអនុមោទនា! សូមអនុមោទនាមហាកុសល!! សូមអនុមោទនាបុណ្យ!!!

មាតិកា

ឈ្មោះអត្ថបទ **ទំព័រ**

១.កូនអើយគិតឱ្យវែងឆ្ងាយ ១
២.ម៉ែជានរណា? ៣
៣.តើឱ្យពុកម៉ែពឹងលើអ្វីទៅ? ៥
៤.កូនខុសហើយម៉ែ! ៨
៥.ជីវិតមានន័យ ១០
៦.ខ្ញុំសូមប្រាប់កូន ១១
៧.កូនវង្វេងបឹង ១៣
៨.មួយជីវិតនេះជាក្មេងកំព្រា ១៥
៩.រូបល្អចាញ់ចិត្តល្អ ១៧
១០.តួនាទីមាតាបិតា ១៨
១១.តួនាទីកូនប្រុសស្រី ១៩
១២.គ្មានអ្វីប្រៀបបាន ២០
១៣.ខ្លាចអ្វីម្ល៉េះកូន! ២១
១៤.បំណងមេបា ២៣
១៥.កិត្តិយសមិនហួសគុណធម៌ ២៥
១៦.ប្រយ័ត្នត្រចៀក ២៦
១៧.អានុភាពព្រះពុទ្ធសាសនា ២៧
១៨.ទំព័រជីវិត ២៨
១៩.ថៃមរតកខ្មែរ ៣០
២០.ថៃវប្បធម៌ផងថ្លៃ ៣១

២១.សម្រែកអ្នកម្តាយ.....៣២
២២.សង្រ្គមឥន្ទ្រិយ.....៣៤
២៣.ចេះធ្វើទៅកើត!.....៣៦
២៤.ម៉ែឈឺណាស់កូន.....៣៧
២៥.សាមគ្គីគ្នាឡើង.....៣៩
២៦.ម៉ែពិតជាមានគុណ.....៤០
២៧.ថៃកេរ្តិ៍ដូនតា.....៤២
២៨.អាសូរម្តាយខ្ញុំ.....៤៣
២៩.ប្រភពបញ្ហា.....៤៥
៣០.រិះគន់ដើម្បីស្ថាបនា.....៤៦
៣១.គួរដឹងរឿងពិត.....៤៧
៣២.ខ្លួនយើងជាខ្មែរ.....៤៨
៣៣.រូបមន្តជីវិត.....៤៩
៣៤.ស្មារតីឧត្តម.....៥០
៣៥.ឧត្តមគតិ.....៥១
៣៦.កវីសូមផ្តាំ.....៥២
៣៧.ស្នេហាវប្បធម៌ផងថ្លៃ.....៥៥
៣៨.តើសល់អ្វីខ្លះ?.....៥៨
៣៩.រូបកាន់តែចាស់ចិត្តកាន់តែក្មេង.....៥៩
៤០.ទំនួញដូនតា.....៦១
៤១.តើអួតបានអ្វី?.....៦៣
៤២.ឈ្នះចាញ់បានអ្វី?.....៦៤

៤៣.ព្រមឬមិនព្រម?.....៦៦
៤៤.ព្រះណាជួយបាន?.....៦៨
៤៥.តើចង់បានអ្វី?.....៦៩
៤៦.ឆ្នាំថ្មីមនុស្សចាស់.....៧០
៤៧.ខ្ញុំថាហើយថា.....៧២
៤៨.ឥតដែនកំណត់.....៧៣
៤៨.ប្រសិទ្ធិភាពនៃសម្តី.....៧៤
៤៩.ស៊ីជោរខុសរឿង.....៧៥
៥០.អន្តរាយគ្រប់យ៉ាង.....៧៦
៥១.ឃើញគេល្អខ្លះផង.....៧៨
៥២.ពុធម៌នឹកបុណ្យ.....៧៩
៥៣.ចូរគិតថ្ងៃមួយណ៎ាកូន!.....៨០
៥៤.ត្រឹមតែជាសង្ខារ.....៨៣
៥៥.មរតកជីវិត.....៨៤
៥៦.វប្បធម៌គេទេកូន.....៨៦
៥៧.សាងអ្វីបាននោះ.....៨៨
៥៨.ត្រឹមតែជាខ្យល់មាត់.....៨៩
៥៩.ជីវិតគឺត្រៃលក្ខណ៍ធម៌.....៩០
៦០.អត់ទោសជូនបុណ្យ.....៩២
-សៀវភៅដែលរៀបរៀងដោយខ្ញុំព្រះករុណា.....៩៣
-នាមពុទ្ធបរិស័ទចូលរួមបោះពុម្ពសៀវភៅនេះ.....៩៤

១.កូនអើយគិតឱ្យវែងឆ្ងាយ

(បទព្រហ្មគីតិ)

កូនអើយឪនឹងស្តី ប្រុងស្មារតីណានួនល្អង
រស់នៅស្តាប់ប្អូនបង កុំកន្លងពីក្បួនច្បាប់។
កូនកុំមើលងាយគេ ខឹងអាងជេរខុសសណ្តាប់
រស់នៅប្រៀបដូចស្លាប់ កេរ្តិ៍ឈ្មោះយ៉ាប់ខ្វះញាតិមិត្ត។
កុំចង់តែសប្បាយ ចូរខ្វល់ខ្វាយរៀនសូត្រពិត
ទើបកូនមិនវិបរិត បាននៃបនិត្យសុខសួស្តី។
កូនកុំសេពសុរា ល្បែងហ៊ឺហាញៀនលេងស្រី
កុំញៀនជក់បារី ខូចស្មារតីឥតបានការ។
កូនកុំធ្វើតាមហ៊ាន ស្តីបំពានតាមតណ្ហា
កុំធ្វើឫកដូចខ្លា ចង់សុខាបៀតបៀនគេ។
បានកើតក្នុងមួយជាតិ កូនកុំឃ្លាតសីលទទេ
ស្តាប់ធម៌កុំទំនេរ នេះគឺកេរ្តិ៍ពុទ្ធសាសនា។
អក្សរសិល្ប៍លេខខ្មែរ កូនត្រូវថែគ្រប់រូបា
ប្រាសាទពីដូនតា ព្រៃព្រឹក្សាថែឱ្យល្អ។
យើងមានពុទ្ធសាសនា មានភាសាដ៏បវរ
កូនកុំពោលរឿងក្រ គ្មានបរមិនប្រឹងប្រែង។
កូនកុំជាប់ញៀនកាម មិនជឿតាមធម៌សម្តែង
រស់នៅចេះកោតក្រែង ជួយគេឯងកុំបីខាន។
កូនអើយគិតឱ្យឆ្ងាយ មើលថែម្តាយបន្ទន់ប្រាណ
រស់នៅគិតសន្តាន បើមានបានកុំភ្លេចទាន។

តិចច្រើនកូនត្រូវឱ្យ គឺតែងសោយសុគ៌និព្វាន
ជាតិក្រោយមិនអត់ឃ្លាន ព្រះទូន្មានយ៉ាងច្បាស់ច្បង។
កូនអើយឪសូមផ្តាំ យូរខែឆ្នាំក្រែកនឹង
រស់នៅស្តាប់ធម៌ផង នេះបំណងឪណ៎ាកូន។

ដោយសាមណេរ **សា ចាន់ណាត់**



(ព្រះគាថាប្រារព្ធចំអោះនក្ខត្តឫករបស់ជនពាល)

អា បមាទមនុយុញ្ជេថ អា កាមរតិសន្ថវំ
អប្បមត្តោ ហិ ឈាយន្តោ បប្បោតិ វិបុលំ សុខំ។

អ្នកទាំងឡាយ ចូរកុំប្រកបរឿយៗ នូវសេចក្តីប្រមាទ ចូរកុំប្រកប រឿយៗ នូវសេចក្តីរីករាយ ត្រេកអរក្នុងកាមឡើយ ត្បិតបុគ្គលអ្នកមិន ប្រមាទ ខំសង្កេតពិនិត្យ រមែងបានសេចក្តីសុខដ៏ទូលាយ។

Therefore, one should not be negligent, nor be addicted to sensual pleasures; for he who is established in mindfulness, through cultivation of Tranquillity and Insight Development Practice, experiences supreme happiness (i.e., realizes Nibbāna)

២.ម៉ែជានរណា?

(បទពាក្យជ្រាំពីរ)

ម៉ែគឺជាព្រះរបស់កូន ម៉ែគឺជាក្បូននៃប្រុសស្រី
ម៉ែគឺជាព្រះក្នុងលោកិយ ម៉ែប្រោសប្រណីចិញ្ចឹមបុត្រ។
ម៉ែជាព្រះព្រហ្មសែនកម្រ ម៉ែមានចិត្តល្អថ្លៃវិសុទ្ធ
ម៉ែថ្នមរូបកូនលើសបានម្កុដ ម៉ែស្មោះបំផុតមិនគេចកែ។
ម៉ែមិនឱ្យកូនធ្វើអាក្រក់ ម៉ែជូនមរតករាល់ថ្ងៃខែ
ម៉ែជាគ្រូពេទ្យនៅចាំថែ ម៉ែបើកប្រាក់ខែឱ្យកូនចាយ។
ម៉ែប្រៀបបីដូចជានាវា ម៉ែជូនពុំងាទៅត្រើយអាយ
ម៉ែស្នេហាបុត្រមិនជិនណាយ ម៉ែមិនដែលស្តាយទ្រព្យធនធាន។
ម៉ែគ្រូដំបូងដ៏ថ្លាថ្លៃ ម៉ែជូនចរណៃឱ្យទៅរៀន
ម៉ែទីប្រឹក្សាល្អរកគ្មាន ម៉ែគឺជាស្ពានកូនមាសស្ងួន។
ម៉ែផ្តល់កំណើតរូបរាងកាយ ម៉ែថែឆោមឆាយចិត្តមាំមួន
ម៉ែមានធម៌ព្រហ្មនៅក្នុងខ្លួន ម៉ែជួយផ្ទួនៗរាប់ពុំបាន។
ម៉ែនៅថែកូនយូរខែថ្ងៃ ម៉ែថ្នមថ្លើមសព្វអង្គប្រាណ
ម៉ែអ្នកមានគុណដ៏ចំណាន ម៉ែផ្តល់សុខសាន្តរាល់វេលា។
ម៉ែជាជម្រកទ្រនុំបុត្រ ម៉ែចិត្តបរិសុទ្ធណាស់ពុំងា
ម៉ែអ្នករង់ចាំនៅការពារ ម៉ែគ្រងស្ងួនភ្ងាលុះមរណា។
ម៉ែអ្នកវ៉ាប់រងមុខរបរ ម៉ែឱ្យស្លៀកសទៅវត្តវ៉ា
ម៉ែស៊ូលំបាកនឿយកាយា ម៉ែមិនដែលថាឱ្យកូនខ្ពស់។
ម៉ែគឺជាអ្នកដ៏អស្ចារ្យ ម៉ែមានមេត្តាឱ្យកូនរស់
ម៉ែចម្លងកូនឱ្យផុតគ្រោះ ម៉ែពិតមានឈ្មោះឧត្តមក្រៃ។

ម៉ែជាប្រទីបបំភ្លឺផ្លូវ ម៉ែតែងនិត្យនៅថ្នមបុត្រថ្លៃ
ម៉ែហ៊ានលះបង់គ្មានសំចៃ ម៉ែថ្នមផ្គាល់ដៃកូនគ្រប់គ្នា។
ម៉ែប្រាប់ឱ្យកូនខិតខំរៀន ម៉ែពិតជាមានព្រហ្មវិហារ
ម៉ែមានគុណធំហួសមេឃា ម៉ែចិត្តល្អជាលើត្រាណត្រើយ។
ម៉ែគឺជាម្លប់ដ៏ត្រជាក់ ម៉ែស្មោះវរលក្ខណ៍នៅកៀកកើយ
ម៉ែយកខ្លួនប្រាណធ្វើជាខ្នើយ ម៉ែមិនស្តាយឡើយចិត្តភក្តី។
ម៉ែគឺជាព្រះដ៏ចម្បង ម៉ែល្អឥតហ្មងក្នុងភពបី
ម៉ែជួយឱ្យកូនរស់មានន័យ ម៉ែចិត្តប្រពៃមិនងាយរក។
ម៉ែពិតមានគុណដ៏ជាក់ស្តែង ម៉ែព្រះសម្តែងល្អក្នុងលោក
ម៉ែហប្ញទ័យល្អកូនបានជ្រោក ម៉ែព្រះមានជោគរស្មីកូន។
ម៉ែគឺទេវតាជួយការពារ ម៉ែចិត្តព្រហ្មាមិនដែលសូន្យ
ម៉ែប្រាប់ឱ្យអ្នកដឹងជីដូន ម៉ែប្រាប់ឱ្យកូនស្គាល់ជីតា។
ម៉ែគឺជាព្រះគួរវន្ទា ម៉ែគួរបូជាដោយជ្រះថ្លា
ម៉ែគួរគោរពក្នុងលោកា ម៉ែផ្តល់សុខាដល់កូនៗ។

ដោយ សាមណេរ **សា ចាន់រ៉ាត់**



៣.តើឱ្យពុកម៉ែពឹងលើអ្វីទៅ?

(បទពាក្យជ្រាំបី)

ទូកពឹងច្រវាលើផ្ទៃសាគរ ក្តោងពឹងវាយោបក់បោកអសាត់
ទៅកាន់ត្រើយនាយស្វែងរកសម្បត្តិ សុខឬវិបត្តិមានរាល់វេលា។
ពុកម៉ែខ្លួនចាស់នឹកពឹងរកកូន បីដូចជាក្បូនដ៏ល្អសោភា
រស់នៅពឹងកូនចៅគ្រប់អង្គា ក្រែងផុតវេរាពេលខ្លួនចាស់ទៅ។
សេចក្តីប៉ុនប៉ងបានត្រឹមខកចិត្ត កូនចៅមានពិតតែដើរខុសផ្លូវ
ខំចិញ្ចឹមកូនសក់ខ្មៅដល់ស្កូវ តែពេលឥឡូវកូនប្រែក្រឡាស់។
ទ្រព្យធនម៉ែមានចែកកូនមិនស្តាយ ឱ្យរាល់រូបកាយទោះមានឬខ្វះ
ឱ្យតែកូនសុខម៉ែអរខ្លាំងណាស់ ពេលពុកម៉ែចាស់គ្រាន់រស់នៅផង។
ឥឡូវដល់ហើយអ្វីដែលគិតទុក ម៉ែហើយនិងពុកធ្លាក់ខ្លួនសៅហ្មង
ទៅពឹងកូនប្អូនគេឱ្យទៅបង ប្រកែកឆ្លើយឆ្លងឈ្លោះគ្នារញ៉ៃ។
ពុកម៉ែកំព្រាស់នៅផ្ទះខ្ទម រាងកាយទ្រុឌទ្រោមព្រួយចិត្តរាល់ថ្ងៃ
ខ្វះម្ហូបអាហារអង្ករត្រីប្រៃ ឱ!កូនម្តាយថ្លៃហេតុអ្វីដូច្នោះ។
ថាកូនស្រីទៅគ្នានៅស្រុកឆ្ងាយ ចុះចៅរាល់កាយហេតុអ្វីគិតខុស
កូនស្រីមិនកើតគួរណាស់តែប្រុស ប្រណីសន្តោសចិញ្ចឹមម៉ែផង។
គេមានផ្ទះថ្មសសរឥដ្ឋធំ ហេតុអ្វីមាសមុំឱ្យម៉ែសៅហ្មង
កូនពៅមិនជាហេតុអ្វីកូនបង ប្រព្រឹត្តកន្លងឱ្យម៉ែកំព្រា។
មើលចុះអាហារគេហូបមិនខ្វះ ខោអាវថ្មីចាស់សម្បូរហូរហៀ
កូនសប្បាយមែនតែម៉ែគ្រាំគ្រា រស់នៅវេទនាស្ទើរបែកឱរា។
ឱកូនសំឡាញ់មាសម្តាយអើយ មិនគួរសោះឡើយគ្មានមេត្តា
ខ្លួនម្តាយចាស់ហើយពឹងនរណា ខោអាវអាហារធ្វើបុណ្យទាន។

បើខ្លួនកូនក្រពុកម៉ែមិនថា កូនមានហឺហាតែម៉ែអត់ឃ្លាន
ចៅក៏ដូចគ្នាសុទ្ធតែអ្នកមាន លុយកាក់រាប់លានគួរតែជួយម៉ែ។
បើកូនសុខហើយម៉ែត្រេកអរណាស់ តែកម្មម៉ែក្រាស់លំបាកឥតល្ហែ
កាលធុតសង្គ្រាមម៉ែខំធ្វើស្រែ រៀងរាល់ថ្ងៃខែពុំសូវទំនេរ។
ស្តីពីតាវាគាត់ក៏ខំណាស់ កាប់ព្រៃជីកស្រះទុកគ្រាន់ជាកេរ្តិ៍
ខំតាំងពីព្រឹកថ្ងៃលិចទន់ទេរ ហត្ថាទាំងទ្វេដល់ផ្ទះឱបកូន។
ឥឡូវប្លែកណាស់រស់នៅក្រៀមក្រោះ កូនចៅធំអស់រសាត់ដូចក្បួន
ពីដើមមានណាស់ឥឡូវធ្លាក់សូន្យ មើលចុះជីដូនក៏ធ្លាក់ខ្លួនឈឺ។
ស្តីពីថ្នាំពេទ្យក៏គ្មានក្នុងផ្ទះ គ្មានទាំងប្រាក់មាសឬក៏ស្រែភ្លឺ
ទៅប្រាប់កូនចៅគេធ្វើមិនឮ រឹតតែបញ្ឈឺពោលស្តីឡូឡា។
ឱកូនសំឡាញ់នៃពុកម៉ែអើយ ម៉ែជិតលាហើយណាកូនកនិដ្ឋា
បើកូនភ្លេចម៉ែពុកក៏មិនថា ម៉ែសូមផ្តាំថាម្តងម្នាក់ទេកូន។
ពេលនេះម្តាយចាស់ជិតស្លាប់ទៅហើយ មិនទាមទារឡើយចូរមើលថែប្អូន
កុំទាស់ទែងគ្នានាំងងឹតសូន្យ ម៉ែសូមលាកូនទៅទាំងអាល័យ។
ឈប់ស្លេះត្រឹមនេះអស់លោកសប្បុរស ក្មេងចាស់ទាំងអស់ច្បាស់គ្មានសង្ស័យ
នៅក្នុងលោកនេះក៏ឃើញរាល់ថ្ងៃ ខ្ញុំមិនកាឡែពោលពាក្យមុសា។
ពុកម៉ែគេផ្សេងក៏ដូចម៉ែខ្ញុំ ឃើញហើយចិត្តយំសង្វេគចិន្តា
នឹកឃើញដូច្នេះទើបតែងអក្ខរា គ្រាន់ពិចារណានៃកូនប្រុសស្រី។
រៀបរាប់មកនេះមិនមែនទាំងអស់ តិចតួចប៉ុណ្ណោះមានចិត្តអប្រិយ
មិនតបគុណម៉ែបែរខ្នងធ្វើហី គិតចុះប្រុសស្រីមិនចេះតែថា។
សរសេរមកនេះនៅចុងបញ្ចប់ សូមលើកម្រាមដប់អភ័យទោសា
ក្រែងមានប៉ះពាល់ខុសឆ្គងយ៉ាងណា ខ្ញុំគ្មានចេតនាបៀតបៀនគ្រប់គ្នា។

បើខ្ញុំពោលទៅក្រែងមានកំហុស សូមអស់សប្បុរសគំនិតល្អជា
បើខ្ញុំពោលត្រូវដឹងគុណគ្រប់គ្នា ពុកម៉ែជារក្នុងផ្ទះនោះឯង។
ប្រការមួយទៀតខ្ញុំឆ្លៀតជូនបុណ្យ គ្រប់អស់មហាជនសូមភ្លឺចិញ្ចែង
ដោយអំណាចនៃធម៌ព្រះសម្តែង សូមអស់គម្តែងបានសុខសួស្តី។
សូមដឹងគុណឡើងរៀនស្តាប់ធម៌អាថ៌ ចម្រើនប្រាជ្ញាទើបផុតអវិជ្ជា
បើបានដឹងហើយចូរអ្នកឃ្មាតខ្មី ចម្រើនបារមីរៀងរាល់វេលា។
បើអ្នកដឹងគុណពុកហើយនិងម៉ែ ថែរាល់ថ្ងៃខែគាត់ចាស់ជរា
ពេលអ្នកស្លាប់ទៅកើតក្នុងសួគ៌ា ផុតទុក្ខនានាលុះនិព្វានហោង។

ដោយសាមណេរ **សា ចាន់ណាត់**

(ព្រះគាថាប្រារព្ធចំពោះព្រះសោអយ្យស្តេរ)

ន តំ មាតា បិតា កយិរ អញ្ញេ ញាតិ ច ញាតកា
សម្មាបណិហិតំ ចិត្តំ សេយ្យសោ នំ តតោ ករេ។

មាតាបិតា មិនគប្បីធ្វើហេតុនោះបាន ឬជនទាំងឡាយដទៃ ជាញាតិ មិនគប្បីធ្វើនូវហេតុនោះបាន ចំណែកខាងចិត្ត ដែលបុគ្គលតាំងទុកត្រូវហើយ រមែងធ្វើបុគ្គលនោះ ឱ្យប្រសើរជាងហេតុនោះបាន។

Not a mother, nor a father, nor any other relative can do more for the well-being of one than a rightly-directed mind can.

៤.កូនខុសហើយម៉ែ!

(បទពាក្យជ្រាំបី)

ពេលមានជីវិតកូនមិនបានគិត ដល់ម៉ែក្សយពិតទើបកូនភ្ញាក់ខ្លួន
បម្រើស្រាលធ្ងន់លើម៉ែនឹមនួន ក៏កូនមាសស្ងួនមិនបានធ្វើដែរ។
ចំណីអាហារហូបចុកទាំងខ្វះ ខ្លួនម្តាយសែនចាស់រស់នៅស្រុកស្រែ
កូនមិនដែលទៅសួរសុខទុក្ខម៉ែ គ្មានអ្នកមើលថែក៏កូនមិនខ្វល់។
ឱព្រះម៉ែអើយកូនស្តាយណាស់ ពីមុនល្ងង់ណាស់គ្មានដឹងខ្យល់
ពុកម៉ែនៅរស់មិនសាងមគ្គផល ព្រោះគិតមិនដល់គុណអ្នកម្តាយថ្លៃ។
នឹកឃើញគ្រាមួយកាលកូននៅតូច ម៉ែថែប្រៀបដូចពេជ្រចរណៃ
យកសក់បាំងកូនយកខ្លួនបាំងថ្ងៃ កូនស្ថិតក្នុងដៃព្រះម៉ែថ្នមបី។
ធ្វើការរកស៊ីមិនមានចន្លោះ ឆ្លៀតឱ្យបៅដោះមិនមានខ្មាសអ្វី
នៅមុខមហាជនមានប្រុសមានស្រី ក៏ម៉ែធ្វើហីឱ្យតែកូនឆ្អែត។
គុណធំយ៉ាងនេះរិះគិតមិនដឹង គុណល្អយ៉ាងហ្នឹងឃើញច្បាស់ក្រឡែត
គិតពីខែមាឃថាចាំខែចេត្រ ធ្វើបុណ្យជាហេតុតបគុណម៉ែខ្លះ។
មិនទាន់ដល់ផងម៉ែលាកូនហើយ អ្នកម្តាយត្រាណាត្រើយកូនៗខុសណាស់
ព្រោះមិនស្តាប់គ្រូយល់តែផ្តេសផ្តាស មិនថែម្តាយចាស់ឱ្យនៅម្នាក់ឯង។
មើលចុះខ្មមតូចស្ងៀមធ្វើមិនដឹង ខ្ញុំទុក្ខម្ល៉ឹងៗចិត្តវិលដូចផ្សែង
ទឹកដីខ្មមតូចដែលជាកន្លែង សូមជួយថ្លាថ្លែងរកម៉ែខ្ញុំផង។
ឱម្តាយសំឡាញ់ជាទីស្នេហា ម៉ែនៅឯណាម្តេចស្ងាត់តែម្តង
ពីដើមមកជួបម៉ែស្តីឆ្លើយឆ្លង ពេលនេះឯងហោងឃើញតែទីតាំង។
ឃើញគ្រែកន្ទេលម៉ែធ្លាប់សម្រាន្ត កូនទប់មិនបានព្រោះកូនខុសខ្លាំង
ឃើញក្រមាចាស់ម៉ែធ្លាប់បិទបាំង ឱអ្នកសង្ខំជួយរកម៉ែខ្ញុំ។

ពងទឹកឆ្មាំងបាយនិងខោអាវម៉ែ ពីរបីហូរហែកូនរឹតទុក្ខធំ
ម៉ែអើយពេលនេះកូនទុក្ខប៉ុនភ្នំ កូនចង់តែយំប្រាប់អស់ទេវតា។
ពេលនេះហួសហើយគ្មានត្រឡប់វិញ កូនទុក្ខទោម្នេញគ្មានពេលភ្លឺថ្លា
ម៉ែរស់ក្នុងខ្ទមកូននៅវីឡា សមដូចគេថាកូនដូចបក្សី។
មិនគួរសោះឡើយម៉ែអើយទៅណា កូនមកហើយវ៉ាសូមម៉ែស្រដី
ម្តេចនៅស្ងៀមឈឹងសម្រាន្តធ្វើហី កូនយកចំណីជូនម៉ែពិសា។
ពុទ្ធោម៉ែខ្ញុំគាត់ស្លាប់ទេដឹង ដៃជើងគាត់រឹងមិនស្តីចរចា
ម៉ែអើយៗម៉ែសូមភ្ញាក់ឡើងណា កូនជូនអាហារកូនមកដល់ហើយ។
មើលចុះញាតិមិត្តគេធ្វើអ្វីទៅ អ្នកម្តាយពាលពៅដេកធ្វើកន្តើយ
ខ្លះវាយក្តារមឈូសពុទ្ធោម៉ែអើយ ម៉ែលាកូនហើយឱ្យកូនពឹងអ្វី។
អស់លោកប្រុសស្រីសូមជួយខ្ញុំផង សូមជួយចម្លងទៅជួបម្តាយស្រី
គាត់នៅទីណាខ្ញុំសែនរឹងរៃ ពុទ្ធោម៉ែក្សយកូនខុសខ្លួនហើយ។

ដោយសាមណេរ **សា ចាន់ភ័ត**



៥.ជីវិតមានន័យ

(បទពាក្យជ្រាំបី)

ជីវិតគឺជាដំណើរផ្លូវឆ្ងាយ សុខទុក្ខសប្បាយមិនទៀងទាត់ទេ
ប្រែប្រួលផ្លាស់ប្តូរឥតមានទំនេរ អ្នកគួររិះរេខិតខំធ្វើល្អ។
ជីវិតប្រសើរមិនដោយសារទ្រព្យ ធ្វើល្អឱ្យជាប់ទើបថ្លៃបវរ
បានធ្វើបុណ្យហើយគួរខំបន្ត ធ្វើដោយស្មោះសទឹកចិត្តជ្រះថ្លា។
រស់នៅមានន័យលៃធ្វើបុណ្យទាន រស់មិនបំពានលើច្បាប់មាត្រា
រៀនច្បាប់ឱ្យច្បាស់ចម្រើនប្រាជ្ញា សិក្សាធម៌អាថ៌សាស្តាទូន្មាន។
ជីវិតមានន័យអាស្រ័យមានសីល ជម្រះមន្ទិលលះទ្រព្យធ្វើទាន
លះធម៌លាមកគំនិតឈ្លានពាន ប្រាថ្នានិព្វានទើបជួបសុខពិត។
ជីវិតបានសុខអាស្រ័យចិត្តស្ងប់ អ្នកគួរត្រឡប់អប់រំកាយចិត្ត
សេពគប់បណ្ឌិតស្តាប់ធម៌ហើយគិត ទើបបាននៃបនិត្យសម្បត្តិអសារ្យ។
លទ្ធផលគុណធម៌គឺយសសិរី ធ្វើឱ្យប្រុសស្រីរីករាយជ្រះថ្លា
លះកម្មអាក្រក់កម្ចាត់តណ្ហា ទើបបានសុខាលែងវិលកើតស្លាប់។
ជីវិតនៅមានគួរឆ្លៀតសាងគុណ កុំសាងទារុណនាំឈឺចុកចាប់
ធម៌ព្រះមានហើយអ្នកគួរប្រញាប់ សិក្សាហើយស្តាប់រកន័យជីវិត។

ដោយសាមណេរ **សា ចាន់ណាត់**



៦.ឱសូមប្រាប់កូន

(បទព្រហ្មគីតិ)

ឱៈឱកូនប្រុសស្រី ប្រុងស្មារតីស្តាប់ឱ្យបាន
គឺឪប្រាប់គ្រប់ប្រាណ តាំងសន្តានប្រុងសោតា។
កូនអើយទាំងប្រុសស្រី ក្នុងលោកិយគ្រប់អាត្មា
គេរស់បានសុខា គឺដោយសារមានវិជ្ជា។
កូនរស់ត្រូវរិះរេ កុំដៀលគេនាំវេរា
ធ្វើការខំស្ទុះស្ទា រកទ្រព្យគ្រាន់នៅក្មេង។
នៅតូចត្រូវខំរៀន គ្រប់របៀនកុំដើរលេង
ពេលយប់មុនចូលគេង កុំគិតផ្សេងពីធម៌អាថ៌។
ធំឡើងខំរកទ្រព្យ ប្រសើរគាប់ក្នុងគ្រួសារ
ធ្វើទានកុំភ្លេចណ៎ា ជូនដូនតាដែលស្លាប់ទៅ។
បើយកប្រពន្ធប្តី ចូលស្រដីទៅតាមផ្លូវ
កេរ្តិ៍ឈ្មោះមិនអាស្រូវ ល្អពេកកូវស្តាប់មេបា។
ការងារខំឱ្យណាស់ ចាំឱ្យច្បាស់ទៅវត្តវ៉ា
ទំនេរស្តាប់ទេសនា ទើបចិន្តាកូនបានសុខ។
រកស៊ីឱ្យស្របច្បាប់ ចិត្តស្វាហាប់ខំសម្រុក
លក់ដូរត្រីប្រហុក គ្រឿងហូបចុករៀរបាណា។
កូនអើយកុំលួចឆក់ កម្មអាក្រក់រងទុក្ខា
បើតាមព្រះទេសនា គ្មានថ្ងៃណាបានសុខទេ។
ចិត្តកូនត្រូវតែស្មោះ កុំឡេះឡោះប្រពន្ធគេ
ស្លាប់ទៅធ្លាក់និរយៈ ត្រូវគេជេរប្តឹងតវ៉ា។

កូនអើយពោលពាក្យពិត　　កុំប្រឌិតពោលមុសា
សម្តីគ្មានបានការ　　ចាញ់បក្សាបក្សីយំ។
កូនកុំសេពគ្រឿងញៀន　　បើបំពានរងទុក្ខធំ
សុរាក៏កូនកុំ　　សូមមាសមុំកុំចង់សាក។
សីលទានកូនកុំភ្លេច　　ថ្លៃជាងពេជ្រធ្វើកុំផ្អាក
ទោះក្រខ្សត់តោកយ៉ាក　　ទើបរូចចាកភាពក្រក្រី។
នេះហើយបណ្តាំឪ　　ស្តាប់ចុះពៅកុំគិតខ្លី
រស់នៅប្រុងស្មារតី　　ទើបសិរីចូលរកកូន។
សម្តីដែលឪប្រាប់　　ទុកជាច្បាប់កុំឱ្យសូន្យ
វិជ្ជាទុកដូចក្បូន　　ជួយរូបកូនផុតទុក្ខហោង។

ដោយសាមណេរ **សា ចាន់ន៉ាត់**

(ព្រះគាថាប្រារព្ធចំពោះបុរសម្នាក់)

ទីឃា ជាគរតោ រត្តិ　　ទីឃំ សន្តស្ស យោជនំ
ទីឃោ ពាលាន សំសារោ　　សទ្ធម្មំ អវិជានតំ។

រាត្រីវែង ចំពោះតែអ្នកភ្ញាក់រឭក (អ្នកដេកមិនលក់) យោជន៍វែង ចំពោះតែអ្នកនឿយហត់ សង្សារវដ្តវែង ចំពោះតែបុគ្គលពាល មិនដឹងច្បាស់នូវព្រះសទ្ធម្ម។

Long is the night to one who is wakeful; long is (the journey of) one yojana to the traveller who is tired; long is saṁsāra (round of rebirths) to the fool, who is ignorant of the true Dhamma (the Teaching of the Buddha).

៧.កូនភន្ទេចម៉ែ

(បទពាក្យជ្រាំបី)

អង្គុយម្នាក់ឯងក្នុងខ្ទមចង្អៀត　　កណ្តាលអធ្រាត្រយប់ក៏ត្រជាក់
ចូលដេកមិនលក់មាន់រងាវភ្ញាក់　　ទឹកភ្នែកហូរធ្លាក់ទុក្ខឥតឧបមា។
នឹកឃើញរឿងចាស់មិនធ្លាប់អត់ឃ្លាន　　ខ្លួនជាអ្នកមានសប្បាយហ៊ឺហា
លុយកាក់ម៉ូតូឡានថ្មីសង្ហា　　ផ្ទះថ្មីឡាជីវភាពធូរធារ។
កាលណោះកម្លាំងនៅហ៊ាំមាំមួន　　ឥឡូវធ្លាក់ខ្លួនក្លាយទៅជរា
ណាមួយកូនច្រើនខ្សត់ខ្សោយទ្រព្យា　　ស្តីពីពុកវាក៏មានស្រីទៀត។
កូននៅតូចៗម៉ែខំឱ្យរៀន　　ធ្លាក់ខ្លួនអត់ឃ្លានក៏ម៉ែត្បិតត្បៀត
ស៊ីឈ្នួលធ្វើការបែកញើសហូរព្រោត　　ខិតខំប្រឹងឆ្លៀតដោយចិត្តភក្តី។
កូនៗព្រឹកឡើងឱ្យទៅសាលា　　ខោអាវអាហារមានចាស់មានថ្មី
ផ្គត់ផ្គង់ឱ្យកូនទាំងប្រុសទាំងស្រី　　ម៉ែខំឃ្មាតខ្មីសប្បាយចិន្តា។
កូនរៀនថ្នាក់ទាបអស់ប្រាក់ស្ទើរៗ　　កូនរៀនថ្នាក់លើចុះលុយអស្ចារ្យ
ឱ្យប្រាក់កូនរៀនដោយសង្ឃឹមថា　　កូនធំកាលណាចិញ្ចឹមម៉ែផង។
កូនរៀនបានខ្ពស់រស់កាន់តែឆ្ងាយ　　ចិត្តកូនជិនណាយម៉ែខុសបំណង
កូនមានចំណេះបំភ្លេចប្អូនបង　　ចិត្តម៉ែសៅហ្មងកើតទុក្ខឥតល្ហែ។
ពេលបានជួបកូនម៉ែអរពេកក្រៃ　　ពុទ្ធោបុត្រថ្លៃធ្វើមិនស្គាល់ម៉ែ
កូនថាមិនដឹងអ្នកចម្ការស្រែ　　ខ្ញុំគ្មានពុកម៉ែដូចយាយឯងទេ។
ពេលឮសម្តីស្ទើរមិនជឿសោះ　　កូនស្អាតឥតខ្ចោះតែទាស់ចិត្តរេ
បំភ្លេចម្តាយថ្លៃគុណលោកទាំងទ្វេ　　កូនចាំបានទេមុខមាត់ម៉ែហ្នឹង។
កាលកូននៅតូចម៉ែច្រៀងបំពេ　　ហត្ថាទាំងទ្វេខំយោលអង្រឹង
អធ្រាត្រយប់ស្ងាត់ឱបកូនស្ងាត់ឈឹង　　ឱកូនព្រលឹងហេតុអ្វីធ្វើហី។

ម៉ែចេញពីស្រែមកកាន់ទីផ្សារ គ្មានពឹងនរណាក្រៅពីកូនអី
ខោអាវម៉ែចាស់មិនដែលស្គាល់ថ្មី ឱកូនពិសីម៉ែអួលឱរា។
មើលចុះផ្ទះធំទ្រនំគេខ្ពស់ មានបុណ្យសក្តិយសខ្ពស់ដូចចន្ទថ្លា
ម្តាយទីទាល់ក្រគ្មានអ្វីពិសា ឱកូនកនិដ្ឋាជួយម៉ែផងចុះ។
ឱកូនមាសស្ងួនស្មើដោយជីវិត ម៉ែលាវរមិត្រទៅហើយណាប្រុស
ម៉ែជូនពរកូនឱ្យចេះសន្តោស គឺស្គាល់ត្រូវខុសបាបបុណ្យសខ្លៅ។
ពីដើមម៉ែពកូនដោយហត្ថា ពេលចង់ប្រាថ្នាដើម្បីពចៅ
គេមិនឱ្យប៉ះខ្លាចកូនគេខ្លៅ សូម្បីតែហៅក៏មិនហ៊ានស្តី។
កាលមុនសង្គ្រាមបែកប្តីមិនថា ពេលនេះសោកាជួបកូនអប្រិយ
កូនវង្វេងបឹងចូលក្រុងដីថ្មី ប្លែកទាំងសម្តីនិងការប្រព្រឹត្ត។
រឿងនេះគឺមាននៅក្នុងសង្គម មិនមែនសើចយំឬពោលប្រឌិត
គឺពិតជាមានឥឡូវពិតៗ នេះហើយញាតិមិត្តកូនវង្វេងបឹង។

ដោយសាមណេរ **សា ចាន់ណាត់**



៨.មួយជីវិតនេះជាក្មេងកំព្រា

(បទពាក្យជ្រាំបី)

សម្លឹងមើលមេឃសង្វេគចិន្តា　　កុកក្តួលឱរាទុក្ខឥតមានល្ហែ
តាំងពីតូចមកព្រាត់ប្រាសពុកម៉ែ　　បងប្អូនផងដែររស់ទាំងត្រដរ។
យប់ហើយនឹងថ្ងៃត្រាច់ឥតឈប់ឈរ　　ក្នុងចិត្តថ្ងូរចង្ងូរជីវិតក្រីក្រ
រកស៊ីមួយពោះរស់តែមួយត　　គ្មានថ្ងៃបានល្អដូចគេសោះឡើយ។
ឱកម្មលិខិតជីវិតកំព្រា　　រស់ទាំងវេទនាទុក្ខឥតស្រាកស្បើយ
សូមផ្ទះគេជ្រកគេស្តីតោះតើយ　　បម្រើគេហើយនៅតែទាស់ចិត្ត។
កូនគេអ្នកមានព្រឹកទៅសាលា　　ឯយើងធ្វើការជូនគេពិត។
គេហូបចុកឆ្ងាញ់អាហារប្រណីត　　យើងបានត្រឹមលិទ្ធអាហារដែលគេ។
កូនគេស្លៀកពាក់មានថ្មីមានចាស់　　យើងមួយបន្លាស់គ្មានស្គាល់ថ្មីទេ
បើសិនចង់បានសូមត្រូវគេជេរ　　យើងបម្រើគេបានត្រឹមគ្រាំគ្រា។
ដេកពេលយប់ជ្រៅក្នុងខ្ទមចង្អៀត　　ចិត្តនឹកម្តាយទៀតរៀងរាល់វេលា
ម៉ែនៅទីណាកូនសែនរងា　　ពុកអើយម៉ែលាចោលកូនទៅណា។
មានយប់មួយនោះកូនដេកស្រមៃ　　ឃើញអ្នកម្តាយថ្លៃអង្អែលបុត្រា
ឱពុកញញឹមសប្បាយចិន្តា　　ជួបជុំគ្រួសាររីករាយស្រស់បស់។
ពេលកូនភ្ញាក់ឡើងអ្វីៗមិនពិត　　ធ្វើឱ្យដួងចិត្តកូនសែនក្រៀមក្រោះ
ណាមួយឥឡូវល្ងង់មិនចេះសោះ　　ការងារកូនស្មោះធ្វើដោយឃ្មាតខ្ចី។
មើលទីជីវិតដូចមិនទៀងទាត់　　មានតែពឹងវត្តសាងខ្លួនជាថ្មី
ស្វែងរកចំណេះទើបមានសិរី　　មកសូមទឹកដីស្នាក់នៅសិក្សា។
ព្រះសង្ឃទទួលដោយចិត្តត្រេកអរ　　ឱ្យរៀនបន្តស្វែងរកប្រាជ្ញា
ជីវិតបានសុខដោយគុណវត្តវ៉ា　　ក្រោមពុទ្ធសាសនាត្រជាក់ចិត្តក្រៃ។

យប់រៀនអក្សរថ្ងៃឡើងរៀនលេខ មិនសូវហ៊ានដេករៀនសូត្រធម៌ថ្លៃ
ក្នុងចិត្តគិតផ្សេងជួបម្តាយចរណៃ សូមឱ្យចង្រៃជៀសចេញឱ្យឆ្ងាយ។
ជីវិតឥឡូវដូចមានសង្ឃឹម ទឹកមុខញញឹមសុខទាំងចិត្តកាយ
តែនឹករឿងមួយគួរឱ្យសោកស្តាយ ព្រាត់ឪពុកម្តាយគ្មានអ្នកមើលថែ។
បើសិនពេលនេះអ្នកឃើញរូបកូន រសាត់ដូចក្បូនម្លេះសមចិត្តម៉ែ
ខ្លោចចិត្តយ៉ាងណាពិតគ្មានល្ហើយល្ហែ ឥឡូវនេះម៉ែលាកូនទៅហើយ។
ម៉ែអើយពុកអើយកូនខំប្រឹងប្រែង រៀនសូត្រខ្លួនឯងឥតមានពេលស្បើយ
កូនខំធ្វើបុណ្យជូនម៉ែដល់ត្រើយ ឱពុកផងហើយកុំឱ្យឃ្លៀងឃ្លាត។
កើតជាតិណាៗពីនេះទៅមុខ សូមជួបម៉ែពុកបងប្អូនគ្រប់ជាតិ
កុំឱ្យបែកគ្នាដូចជាតិនេះទៀត ដួងចិត្តចង្អៀតរស់នៅឯកា។
នេះគឺរឿង៉ាវស្តីពីជីវិត ដែលមានពិតៗមិនចេះតែថា
រឿងនេះគឺមាននៅក្នុងលោកា អស់លោកយាយតាខ្ញុំសូមលាហើយ។

ដោយ សាមណេរ **សា ចាន់ង៉ាត់**



៩.រូបល្អចាញ់ចិត្តល្អ

(បទពាក្យជ្រាំបី)

រូបល្អរាងខ្ពស់មុខគួរឱ្យខ្នាញ់ ក៏គង់នៅចាញ់ផ្លូវចិត្តល្អជា
រាងកាយល្វិតល្វន់គង់ត្រូវជរា មច្ចុទាមទារឱ្យដល់ក្តីស្លាប់។
តាមពិតរូបស្អាតមិនបដិសេធន៍ មកពីមានហេតុតាមសិក្សាស្តាប់
មុខមាត់ចិត្តល្អមិនខឹងប្រញាប់ ធ្វើទានតាមច្បាប់សំពត់និងបាយ។
ម្យ៉ាងទៀតបោសច្រាស់ទីលានចេតិយ អារាមចាស់ថ្មីដោយចិត្តខ្ជល់ខ្ចាយ
មិនខ្ជិលច្រអូសដុសលាងកកាយ សំរាមទាំងឡាយទៅកប់ដុតកោយ។
នេះគឺជាហេតុនាំឱ្យរូបស្អាត ចូរខំសង្វាតធ្វើកុំបណ្តោយ
កុំចេះតែចង់មិនដឹងមុខក្រោយ ស្លាប់ទៅតែងសោយសម្បត្តិសួគ៌ា។
រួចពីនោះមកកើតជាមនុស្សឆ្លាត មុខមាត់ស្អាតបាតដូចបានពណ៌នា
ដូច្នេះបងប្អូនយាយតាមីងមា ចូរខំស្ទុះស្ទាធ្វើឱ្យរាល់ថ្ងៃ។
កុំចេះតែចង់ដោយមិនបានគិត ឥឡូវធម៌ពិតមិនមែនកាឡៃ
ចូរអ្នកគិតចុះកុំដេកស្រមៃ ឱ្យជីវិតថ្លៃជួបសុខពិតហោង។

ដោយសាមណេរ **សា ចាន់រ៉ាត់**



១០.ឆ្លងទីមាតាបិតា

(បទពាក្យជ្រាំបី)

ក្នុងនាមខ្លួនឯងជាឪពុកម្តាយ គួរតែខ្វល់ខ្វាយគិតក្នុងចិន្តា
ត្រូវបំពេញធម៌ទាំងប្រាំប្រការ ដែលព្រះទេសនាទុកដូចជាក្បួន។
ទីមួយត្រូវចាំកុំឱ្យមានភ្លាត់ ខ្លួនត្រូវហាមឃាត់ចំពោះរូបកូន
កុំឱ្យធ្វើបាបនាំងងឹតសូន្យ កូនបងកូនប្អូនជួយដោយស្មោះស។
ទីពីរត្រូវតែតាំងចិត្តឱ្យស្អាត ព្យាយាមសង្វាតឱ្យកូនធ្វើល្អ
ជួយអស់ពីចិត្តដោយក្តីត្រេកអរ ធ្វើគ្រាន់កំដរឱ្យកូនភ្លឺថ្លា។
ទីបីអ្នកត្រូវខិតខំប្រិតប្រៀន ជួយកូនឱ្យរៀនស្វែងរកប្រាជ្ញា
ដល់កូនធំឡើងគ្នាមានកិច្ចការ ចិញ្ចឹមអាត្មានិងម្តាយឪពុក។
ទីបួនអ្នកត្រូវរកប្រពន្ធប្តី ឱ្យកូនប្រុសស្រីរៀបចំទៅមុខ
កុំបង្ខំកូនឱ្យគ្នាមានទុក្ខ រៀបចំដាក់ទុកឱ្យត្រូវចិត្តគ្នា។
ទីប្រាំអ្នកត្រូវចែកទ្រព្យឱ្យកូន កុំឱ្យដាច់សូន្យលំបាកវេទនា
ទុកធ្វើដើមទុនជួញដូរនានា ទើបផុតវេរាឈ្មោះអ្នកឧត្តម។

ដោយសាមណេរ **សា ចាន់ណាត់**



១១.តួនាទីកូនប្រុសស្រី

(បទពាក្យជ្រាំពីរ)

នែ៎កូនប្រុសស្រីផងរាល់កាយ តូចធំទាំងឡាយត្រូវដឹងថា
ខ្លួនឯងបានកើតមកពីណា ចូរអ្នកឧស្សាហ៍ខំរំឭក។
នាទីទីមួយអ្នកដឹងទេ តបគុណទាំងទ្វេទោះល្ងាចព្រឹក
ចិញ្ចឹមម៉ែឪជូនបាយទឹក ហើយព្យាយាមនឹកដោយជ្រះថ្លា។
ទីពីរអ្នកត្រូវតែខំជួយ កុំឱ្យលោកព្រួយរឿងកិច្ចការ
ទោះជាស្រាលធ្ងន់យ៉ាងម្តេចម្តា ចូរអ្នកឧស្សាហ៍ជួយកុំខាន។
ទីបីត្រូវតែតម្កល់ខ្លួន កុំទៅជាប់ជួនចោលខ្លួនប្រាណ
លក់ឈ្មោះត្រកូលធ្លាក់ដូចច្រាន បោះបង់សន្តានខូចគុណម៉ែ។
ទីបួនធ្វើខ្លួនល្ងឱ្យជាប់ អ្នកទទួលទ្រព្យចម្ការស្រែ
ដែលលោកចែកឱ្យជាហូរហែ ដូច្នេះគួរតែអ្នកត្រូវរៀន។
ទីប្រាំពេលដែលម៉ែឪស្លាប់ គួរតែប្រញាប់ធ្វើបុណ្យទាន
ឧទ្ទិសមគ្គផលដែលយើងមាន ជូនញាតិរយលានដែលស្លាប់ហើយ។
នាទីទាំងប្រាំអ្នកធ្វើល្អ ដោយចិត្តត្រេកអរពិតជាស្បើយ
ក្តីទុក្ខលែងមានតទៀតហើយ ដូច្នេះអ្នកអើយគួរដឹងគុណ។

ដោយសាមណេរ **សា ចាន់ណាត់**

១២.គ្មានអ្វីប្រៀបបាន

(បទពាក្យជ្រុំពីរ)

គ្មានស្នឹងណាមួយស្មើតណ្ហា គ្មានអ្វីជ្រះថ្លាស្មើសទ្ធា
គ្មានពន្លឺអ្វីស្មើវិជ្ជា គ្មានអ្វីវេទនាជាងក្តីស្លាប់។
គ្មានអ្វីក្នុងលោកធំជាងចិត្ត គ្មានអ្វីទុក្ខពិតជាងខុសច្បាប់
គ្មានអ្វីចង់លឿនស្មើប្រញាប់ គ្មានអ្វីចុកចាប់ស្មើបញ្ហា។
គ្មានរសអ្វីមួយស្មើសច្ចៈ គ្មានអ្វីជាប់ឆ្ងាក់ស្មើតណ្ហា
គ្មានអ្វីញៀនស្មើនឹងស្នេហា គ្មានអ្វីអស្ចារ្យស្មើនិព្វាន។
គ្មានឆ្កួតអ្វីស្មើល្បែងស្រាស្រី គ្មានរោគឈ្មោះអ្វីស្មើស្រែកឃ្លាន
គ្មានអ្វីសាហាវជាងឈ្លានពាន គ្មានអ្វីដែលមានស្មើធម៌អាថ៌។
គ្មានអ្វីវិនាសជាងប្រមាទ គ្មានអ្វីល្អស្អាតស្មើប្រាជ្ញា
គ្មានអ្វីទៀងទាត់ស្មើមរណា គ្មានអ្វីសោកាស្មើស្រឡាញ់។
គ្មានអ្វីអាក្រក់ស្មើជនពាល គ្មានអ្វីរោលរាលស្មើកំណាញ់
គ្មានអ្វីទុក្ខធំស្មើអ្នកចាញ់ គ្មានរសអ្វីឆ្ងាញ់ស្មើធម្មរស។
គ្មានអាវុធណាស្មើវាចា គ្មានអ្វីអនិច្ចាស្មើលាភយស
គ្មានឃើញអ្វីល្អស្មើធម្មទស្សន៍ គ្មានអ្វីល្អខ្ពស់ស្មើធម៌ព្រះ។
គ្មានអ្វីទុក្ខធំស្មើបញ្ចក្ខន្ធ គ្មានអ្វីប្រកាន់ស្មើមានៈ
គ្មានអ្វីខ្វល់ខ្វាយស្មើរង្កៀស គ្មានអ្វីមួយឈ្នះស្មើខ្លួនជាក់។
គ្មានអន្លង់ណាស្មើកាមា គ្មានជ្រោះមួយណាស្មើភវៈ
គ្មានងងឹតអ្វីស្មើមោឃៈ គ្មានអ្វីខ្វាក់ជាក់ស្មើអវិជ្ជា។
នេះគឺសេចក្តីពោលរៀបរាប់ យ៉ាងប្រសើរគាប់ជូនគ្រប់គ្នា
គ្រាន់ពិចារណាគ្រប់អង្គា សូមសុខរមនាមានដល់អ្នក។

១៣.ខ្លាចអ្វីម្ល៉េះកូន!

(បទពាក្យជ្រាំបី)

បណ្តារឿងរ៉ាវនៅក្នុងគ្រួសារ ស្មុគស្មាញអស្ចារ្យកើតរៀងរាល់ថ្ងៃ
ជីវភាពក្រីក្រលំបាកពេកក្រៃ ធ្វើការផ្គាល់ដៃស្វែងរកទ្រព្យា។
ស្តីពីគ្រួសារមានកូនតូចធំ ជួនវាយគ្នាយំពុំសូវត្រូវគ្នា
កូនធំបន្តិចឱ្យរៀនវិជ្ជា រៀងរាល់វេលាពុំសូវចន្លោះ។
ពេលកូនពេញវ័យមុខមាត់ស្អាតបាត ប្រាជ្ញាវៃឆ្លាតចេះដឹងទាំងអស់
ឪខំទុកដាក់ឱ្យមានគ្រួសារ រៀបមង្គលការឱ្យកូនឆោមឆាយ
ចែកទ្រព្យសម្បត្តិទុកឱ្យគ្រាន់ចាយ ឱ្យមិនរសាយទឹកចិត្តប្រិមប្រិយ។
គេបានដើមទុនរកស៊ីធូរធារ ចោលម្តាយពុំងារស់នៅរឹងរៃ
ភ្លេចគិតដល់ម៉ែឪរស់ក្នុងព្រៃ ព្រាត់ឆ្ងាយទីទៃពីកូនកនិដ្ឋា។
ខែភ្ជុំបុណ្យទានកូនមកម្តង។ ម៉ែអរកន្លងហួសថ្លែងវាចា
ឃើញចៅជិតឆ្ងាយចិត្តនឹកអស្ចារ្យ តែទាស់មួយថាយាយត្រក្រក្រី។
មើលចុះចានឆ្នាំងរនាបបែកបាក់ គ្មានអ្នកទុកដាក់ខ្វះម្ហូបត្រីប្រៃ
អង្ករតិចតួចខ្ទមចង្អៀតក្រៃ ឱកូនចរណៃម៉ែទុក្ខម្ល៉េះទេ។
កូនមានធូរធារទ្រព្យដូចសេដ្ឋី ខ្លាចប្រពន្ធប្តីចោលម្តាយទំនេរ
ជួបម៉ែឪម្តងលាក់លៀមចិត្តគេ ឱះឱមានមេខ្លាចអ្វីម្ល៉េះកូន។
កូននៅតូចៗម៉ែបីទទឹង គេងយោលអង្រឹងយប់ក៏ស្ងាត់សូន្យ
ពេលធំមានប្តីនិងប្រពន្ធកូន ឆ្ងាយដូចទុកក្បូនចេញពីកំពង់។
កាលម៉ែមាំមួនថៃកូនផ្គាល់ដៃ ហេតុអ្វីសព្វថ្ងៃឱ្យម្តាយលិចលង់
កូនខ្លាចចិត្តគេម្ល៉េះស្រស់ឆោមយង់ ម៉ែធ្លាក់អន្លង់កូនឡើងស្ថានសួគ៌។
កូនៗបានសុខតែម៉ែសោកា ជីវិតខ្លោចផ្សាហៅមិនសមគួរ

បើមិនជូនបាយគួរណាស់តែសួរ ឱ្យម៉ែញាក់ញ័ររស់នៅចង្អៀត។
ខ្លាចអ្វីម្ល៉េះកូនម្តេចមិនធ្វើល្អ សន្សំធម៌សខិតខំប្រឹងឆ្លៀត
មើលថែម៉ែឪសង្គ្រោះពួកញាតិ កុំបីឃ្លៀងឃ្លាតណ៎ាពៅព្រលឹង។

ដោយសាមណេរ **សា ចាន់ន៉ាត់**



(ព្រះគាថាប្រារព្ធចំពោះអានន្ទសេដ្ឋី)

បុត្តា មត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ
អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តា កុតោ ធនំ។

ជនពាលតែងព្រួយលំបាក ដោយសេចក្តីសម្គាល់ថា កូនទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន តាមដែលពិត សូម្បីខ្លួនរបស់ខ្លួនក៏មិនមាន ចំណង់បើកូនទាំងឡាយនឹងរាប់ថាមានអំពីណាបាន ទ្រព្យនឹងរាប់ថា មានអំពីណាបាន។

“I have sons, I have wealth”; with him (feeling of attachment) the fool is afflicted. Indeed, he himself is not his own, how can sons and wealth be his?

១៤.មំណាងមេចា

(បទព្រហ្មគីតិ)

នែ៎កូនទាំងស្រីប្រុស ចូលមកចុះប្រុងចាំស្តាប់
ពាក្យកាព្យទុកជាច្បាប់ គួរប្រញាប់ស្តាប់ឱ្យបាន។
ធម្មតាកើតជាមនុស្ស ត្រូវតែស្ទុះរៀនកុំខាន
វិជ្ជាទាំងប៉ុន្មាន យកដាក់ប្រាណកុំខ្ជីខ្ជា។
ម៉ែឪផងទាំងឡាយ គឺខ្វល់ខ្វាយជួយគ្រប់គ្នា
អំពើបាបនានា ឈប់ពុំងាកុំធ្វើទៀត។
ហាមកូនទាំងយប់ថ្ងៃ ប្រឹងលកលៃខិតខំឆ្លៀត
ឱ្យកូនមានមារយាទ ចិត្តចោលម្សៀតកុំឱ្យមាន។
មិនត្រឹមតែប៉ុណ្ណោះ បំណងស្មោះឱ្យខំរៀន
រាល់ច្បាប់គ្រប់របៀន គឺទូន្មានខំស្តីថា។
ម៉ែឪជួយមិនលែង តាំងពីក្មេងឬកុមារ
ជួយឱ្យមានគ្រួសារ ដែលកូនថាស្រឡាញ់ពិត។
ពេលរៀបការរួចហើយ មិនកន្តើយស្នេហ៍កូនស្និទ្ធ
ទ្រព្យធនមានឆ្ងាយជិត ចែករំលែកឥតស្តាយក្រោយ។
ម្យ៉ាងទៀតប្រាប់ថ្ងៃយប់ ជួយកូនគ្រប់មិនបណ្តោយ
ច្បាប់រដ្ឋមានមុនក្រោយ គឺលោកឱ្យរៀនទាំងអស់។
រស់នៅត្រូវខំឆ្លៀត ចេះយល់ញាតិកុំឡេះឡោះ
ធម៌អាថ៌ស្តាប់ដោយស្មោះ កុំចន្លោះចេះគួរសម។
ចិត្តកាយកុំក្អែងក្អាង ញាតិជិតខាងកុំបន្លំ
រាក់ទាក់ប្រឹងខិតខំ ហើយសន្សំបុណ្យកុសល។

រៀនចេះកុំឫកធំ សូមមាសមុំគិតឱ្យដល់
ខ្លួនមានត្រូវខ្វាយខ្វល់ គឺជួយដល់ញាតិផ្សេងផង។
បើកូនមានសក្តិយស កុំគិតហួសភ្លេចប្អូនបង
បើបានសុខឥតហ្មង គឺតបស្នងគុណម៉ែឪ។
បើកូនមានចំណេះ កូនត្រូវចេះគិតឱ្យត្រូវ
ជួយម៉ែឱ្យត្រូវផ្លូវ សុខពេកកូនណាកនិដ្ឋា។
បំណងឪនិងម៉ែ ចង់កែប្រែកូនៗថា
រស់នៅដោយប្រាជ្ញា ទើបឈ្មោះថាជីវិតសម។
នេះបំណងមេបា គ្រប់រូបាត្រូវខិតខំ
កូនអើយធ្វើឱ្យសម ពោលឱ្យចំគឺធ្វើល្អ។

ដោយសាមណេរ **សា ចាន់ភ័ត់**

(គាថាប្រារព្ធចំពោះព្រះនាងខុប្បលវណ្ណាថេរី)

មធុវា មញ្ញតី ពាលោ យាវ បាបំ ន បច្ចតិ
យទា ច បច្ចតី បាបំ អថ (ពាលោ) ទុក្ខំ និគច្ឆតិ។

បាបមិនទាន់ឱ្យផលត្រឹមណា ជនពាល តែងសម្គាល់នូវបាបនោះ ថាដូចទឹកឃ្មុំ លុះតែកាលណាបាបឱ្យផល ជនពាលទើបប្រទះនូវសេចក្តី ក្នុងកាលណោះ។

As long as the evil deed does not bear fruit, the fool thinks it is sweet like honey; but when his evil deed does bear fruit, the fool suffers for it.

១៥.កិត្តិយសមិនហួសគុណធម៌

(បទពាក្យជ្រុំពីរ)

កូនកើតបានរស់ព្រោះមានម៉ែ ចិញ្ចឹមថ្នមថែដោយមេត្តា
ពុកស្វែងរកទ្រព្យជួយគ្រួសារ ឱ្យកូនសិក្សារៀនវិជ្ជា។
អត្តភាពជាមនុស្សសែនក្រណាស់ ក្រព្រះបានត្រាស់ច្បាស់ធម្មា
បានរស់យសធំសូមផ្តាច់ពៀរ សាងពូជសទ្ធាផ្តាច់តណ្ហា។
មានក្រល្អប្លែកមកពីកម្ម រស់រានយូរឆ្នាំមានខ្លឹមសារ
បុណ្យចាស់ផ្លាស់វេនផ្តល់សុខា គុណធម៌ថ្លៃថ្លាស្ងួយជីវិត។
សំណង់អគារមានគ្រឹះទ្រ មនុស្សមានគុណធម៌ទើបល្អពិត
រស់រានសាងបុណ្យទើបស័ក្តិសិទ្ធិ សេពគប់បណ្ឌិតរួចចាកភ័យ។
កេរ្តិ៍ឈ្មោះថ្លៃថ្លាប្តូរវណ្ណៈ កិត្តិយសបុណ្យសក្តិថ្នាក់មន្ត្រី
ជំទាវឧកញ៉ាថ្នាក់សេដ្ឋី សេនាកុង្សីយ៍ព្រោះបុណ្យចាស់។
រូបស្អាតសង្ហាតផ្សំទ្រព្យធន វិជ្ជាលើសលន់ប្រសើរណាស់
ចរិយាមារយាទក៏មិនខ្វះ នេះហៅថាចាស់ហើយមានន័យ។

ដោយសាមណេរ **សា ចាន់ណាត់**



១៦.ប្រយ័ត្នត្រចៀក

(បទពាក្យជ្រាំបី)

អ្នកនិយាយតាមគំនិតគេយល់ រឿងរ៉ាវអំពល់គឺអ្នកស្តាប់ទេ
គួររៀនគិតកុំចេះតែជឿគេ គួរតែរិះរេឱ្យបានហ្មត់ចត់។
សម្តីមានខុសត្រូវជាធម្មតា តាមតែវោហារមិនអាចប្រាកដ
គេថាគេស្តីត្រូវមានអំណត់ អ្នកថាតែងហត់យើងតែងបានផល។
សម្តីគ្រាន់តែជាខ្យល់មាត់សោះ អ្នកស្តាប់ទាំងអស់តែងមានចម្ងល់
អ្នកខ្លះស្តាប់ហើយគិតមិនដល់ មិនដឹងឫសគល់ថារឿងយ៉ាងណា។
សម្តីគ្មានពណ៌រូបរាងស្គមធាត់ កើតពីខ្យល់មាត់អ្នកដែលប្រើការ
បើស្តាប់ដោយល្អតែងកើតប្រាជ្ញា ស្តាប់មិនពិចារណ៍ពិតលង់គំនិត។
អ្នកខ្លះជឿគេគ្រាន់តែឮតគ្នា ចុងក្រោយគ្រាំគ្រាព្រោះរឿងមិនពិត
ខ្លួនមិនដែលឃើញឬបានទៅជិត ប្រកាន់ថាមិត្តក៏គួរជឿបាន។
ការជឿតគ្នាពីមួយទៅពីរ ជាប្រពៃណីមានពីបុរាណ
រឿងខ្លះក៏ល្អគួរកាន់យកបាន រឿងយល់ស្មានៗគួរតែលះបង់។
សម្តីជនពាលគេតែងតែពោល បញ្ចុះបញ្ចូលទៅទីគ្មានប្លង់
ដូច្នេះអ្នកស្តាប់គួរតែធ្វើតផ្ទង់ ព្រះពុទ្ធគ្រប់អង្គទ្រង់ឱ្យពិចារណ៍។

ដោយសាមណេរ **សា ចាន់ណាត់**



១៧.អានុភាពព្រះពុទ្ធសាសនា

(បទពាក្យជ្រាំបី)

ធម៌ព្រះអរហន្តត្រាស់ដឹងក្នុងលោក បុគ្គលចូលមកធ្វើការសិក្សា
ស្តាប់ហើយត្រិះរិះគិតពិចារណា តែងកើតបញ្ញាគឺស្តាប់ដោយល្អ។
យើងរៀនបិដកធម៌ព្រះសម្ពុទ្ធ ខ្ពង់ខ្ពស់បំផុតហៅសែនកម្រ
កំណើតជាមនុស្សបានដោយផលល្អ គួរសិក្សាធម៌ព្រះពុទ្ធសាសនា។
បុគ្គលណាល្ងង់លង់ក្នុងគំនិត កិលេសរួបរឹតគ្មានថ្ងៃភ្លឺថ្លា
ពេលស្តាប់ធម៌ព្រះតែមួយគាថា កាត់វដ្តសង្សារឃ្លាងពីអបាយ។
វិជ្ជាក្នុងលោកមានច្រើនអនេក គឺការបែងចែកនៃគ្រូទាំងឡាយ
មានមន្តអាគមស្តោះផ្លុំរូបកាយ ព្រះពុទ្ធទាំងឡាយថាជាធម៌ថោក។
ធម៌ទាំងឡាយណារបស់អ្នកស្រុក សិក្សាគ្រប់មុខមិនជុតទុក្ខសោក
មិនមានប្រយោជន៍អ្នកប្រាជ្ញាប់ក្រោកវិជ្ជានោះថោកត្រូវគិតរិះរេ។
នៅក្នុងលោកនេះមានជនពួកខ្លះ ខ្លួនយល់មិនច្បាស់ខំដឹកនាំគេ
ធម៌ព្រះមិនរៀនខ្ជិលដេកលើគ្រែ អាគមមន្តស្នេហ៍ខំរៀនឆ្លៀវឆ្លាវ។
ចំណែកមនុស្សខ្លះគេមាននិស្ស័យ គំនិតថ្លាថ្លៃរៀនត្រៃសិក្ខា



១៨.ទំព័រជីវិត

(បទពាក្យជ្រាំបី)

ប្រសូតចាកគភ៌ជាទារកខ្ចី　　ម៉ែបាត់ស្មារតីស្ទើរសូន្យសង្ខារ
ម៉ែស្រក់ទឹកភ្នែកអួលណែនឱរា　　ដើម្បីបុត្រាម៉ែស៊ូអត់ធ្មត់។
ឈាមហូរធ្លាក់ចុះសាច់ម៉ែស្លេកស្លាំង　　កាយគ្មានកម្លាំងចិន្តារន្ធត់
បួងសួងប្រាថ្នាម៉ែសូមឆ្លងផុត　　ពីទុក្ខសុទ្ធៗសូមជៀសឱ្យឆ្ងាយ។
កូនថៅតូចៗម៉ែមើលថែប្រាណ　　ចិញ្ចឹមកល្យាណគ្មានចិត្តជិនណាយ
ងូតទឹកដុសលាងជូននំទឹកបាយ　　ឱ្យកូនឆោមឆាយបៅដោះម៉ែផង។
យប់មួយថ្ងៃមួយម៉ែព្រួយថែកូន　　ទឹកមុខស្រពោនខ្លួនប្រែសៅហ្មង
ប្រៀបកាលក្រមុំខុសគ្នាកន្លង　　នេះហើយនួនល្អងទឹកចិត្តម៉ែឪ។
ទំព័រជីវិតផ្តិតរឿងច្រើនណាស់　　កូនកុំក្រឡាស់ចូរគិតរកផ្លូវ
តបគុណលោកវិញកុំសាងអាស្រូវ　　ក្រែងលោស្លាប់ទៅរងទុក្ខពេកក្រៃ។
កិច្ចការរវល់អ្នកគួរតែឆ្លៀត　　ជួយមើលថែញាតិគ្រប់គ្រាយប់ថ្ងៃ
កុំចាំគាត់ស្លាប់ទើបគិតស្រមៃ　　ជូនម្ហូបថ្លៃៗខោអាវអាហារ។
គ្រប់រូបយើងគេទាំងអស់ប្រុសស្រី　　បើខ្វះស្មារតីពិតត្រូវសោកា
គឺត្រូវសោកស្តាយពេលម៉ែមរណា　　លោកតែងពោលថាគឺដឹងគ្មានន័យ។
ឈប់ស្លេះប៉ុណ្ណឹងពីព្រះគុណម៉ែ　　ធ្លាប់ពោលហូរហែមិនបាច់លកលៃ
ថ្លែងពីគុណឪធំឥតឧបមេយ្យ　　សិក្សាអត្ថន័យទើបបានយល់ច្បាស់។
ម៉ែព្រួយមើលកូនថែទ្រព្យសម្បត្តិ　　ឯឪខំស្តាត់រកទ្រព្យថ្មីចាស់
ម៉ែបីថ្នាក់ថ្នមកូនសុខខ្លាំងណាស់　　ឯឪជួយណាស់រឿងសព្វកិច្ចការ។
គុណម៉ែប្រៀបដូចជាព្រះចន្ទថ្លៃ　　គុណឪចរណៃដូចព្រះសូរិយា
គុណម៉ែប្រៀបដូចជាហ្វូងតារា　　គុណឪនោះណាឥតត្រាវប់បាន។

នេះគ្រាន់តែប្រៀបមិនមែនដូច្នោះ កូនចៅស្រីប្រុសរៀនស្តាប់កុំខាន
ព្រះគុណធំណាស់លើអ្នកគ្រប់ប្រាណ ពេលដឹងថ្មើរម៉ានគួរប្រញាប់ធ្វើ។
ទំព័រជីវិតប្រាប់ពីព្រះគុណ កុំសាងទារុណគំនិតភ្លីភ្លើ
ស្តាប់ម៉ែឪខ្លះកុំលូងលីលើរ កុំអាងលើទ្រព្យគឺបុណ្យយសសក្តិ។
ធ្វើបាបម៉ែឪជារឿងសោយសោក ធ្វើបាបក្នុងលោកជាប់គុកច្រវាក់
រកស៊ីមានក្រជារឿងមាសប្រាក់ កូនចៅគ្រប់ថ្នាក់រៀនគិតចុះណា។

ដោយសាមណេរ **សា ចាន់ភ័ត**



(ព្រះគាថាប្រារព្ធចំអោះព្រះថេរៈឈ្មោះឆន្ន)

ន ភជេ បាបកេ មិត្តេ ន ភជេ បុរិសាធមេ
ភជេថ មិត្តេ កល្យាណេ ភជេថ បុរិសុត្តមេ។

បុគ្គល មិនគួរគប់មិត្តអាក្រក់ មិនគួរគប់បុរសថោកទាប គួរគប់តែមិត្តដែលល្អ គួរគប់តែបុរសជាន់ខ្ពស់។

One should not associate with bad friends, or with the vile. One should associate with good friends, and with those who are noble.

១៩.ថែមរតែកខ្មែរ

(បទព្រហ្មគីតិ)

ពូជខ្មែរមានភាសា ចេះរចនាអក្សរដែរ
ចេះដឹងគុណពុកម៉ែ ចេះមើលថែកេរ្តិ៍ដូនតា។
នេះខ្មែរសម័យមុន មិនស៊ីយស៊ុនខុសតម្រា
ធ្វើអ្វីស្តាប់មេបា កាន់សាសនាព្រះសម្ពុទ្ធ។
ខ្មែរមានវត្តអារាម ខ្មែរជឿតាមធម៌បរិសុទ្ធ
ទើបខ្មែរខ្លាំងបំផុត អាចរួចផុតពីឈ្លានពាន។
កូនអើយពេលឥឡូវ ខំរៀនទៅគ្រប់របៀន
ចំណេះដែលយើងមាន ទុកជាស្ពានឆ្លងអន្តរាយ។
ពេលនេះក្រគោកយ៉ាក ព្រួយលំបាកចិត្តខ្វល់ខ្វាយ
កុំចង់តែសប្បាយ លះចិត្តកាយទើបសុខសាន្ត។
ធ្វើល្អក្នុងលោកិយ ជួបសិរីគ្រប់ៗប្រាណ
ផលបុណ្យក៏កូនបាន ស្លាប់ចែកស្ថានសុខកន្លង។
កូនអើយថែសាសនា ព្រះសម្មាល្អឥតហ្មង
រស់នៅស្តាប់ប្អូនបង ទើបនួនល្អងបានភ្លឺថ្លា។

ដោយសាមណេរ **សា ចាន់ណាត់**



២០.ថែរក្សាព្រះពុទ្ធសាសនា

(បទព្រហ្មគីតិ)

ខ្មែរអើយភ្ញាក់ខ្លួនឡើង　　កុំប្លែកឆ្មើងភ្លេចស្មារតី
រៀនសូត្រទាំងប្រុសស្រី　　ថែទឹកដីជាតិខេមរា។
ខ្លួនធំមុំត្រូវចាំ　　ស្តាប់បណ្តាំពាក្យដូនតា
ខ្មែរមានពុទ្ធសាសនា　　សែនថ្លៃថ្លាថែឱ្យគង់។
សេពគប់ជឿបរទេស　　មិនគួរធ្វេសក្រែងលិចលង់
ខូចខាតធ្លាក់អន្លង់　　មិនគួរល្ងង់លង់គំនិត។
វប្បធម៌សាសន៍ដទៃ　　គេលកលៃចូលមកជិត
ជិះជាន់គ្មានអាណិត　　កុំថាមិត្តទុកចិត្តគេ។
ខ្មែរល្បីពេញលោកា　　ខុសមួយក្តារសែនខ្មាសគេ
វិនាសគ្មានសល់ទេ　　ជឿសាសន៍គេសម្លាប់ជាតិ។
សាសនាភាសាខ្លួន　　ប្រាប់ផ្ទួនៗកុំវិវាទ
បានយសភ្លេចផៅញាតិ　　នេះមារយាទមិនគួរគ្រាប់។
រៀនខ្ពស់យសឧត្តម　　ត្រូវខិតខំគោរពច្បាប់
ហិង្សាវាយចាក់កាប់　　គួរប្រញាប់ជៀសឱ្យឆ្ងាយ។

ដោយសាមណេរ **សា ចាន់ណាត់**



២១.សម្រែករបស់អ្នកម្តាយ

(បទពាក្យជ្រាំបី)

ភ្លៀងធ្លាក់ថ្ងៃរះរន្ទះបាញ់ផាំង ខ្យល់ព្យុះបក់ខ្លាំងកក្រើកទឹកដី
ទឹកជន់ស្លាប់មនុស្សទឹករឹងស្លាប់ត្រី ស្លាប់កើតជាតិថ្មីព្រោះរឿងសង្ខារ។
សំឡេងម៉ែថ្ងូរអាសូរចិត្តម៉ែ កើតទុក្ខឥតល្ហែស្រក់ទឹកនេត្រា
ម៉ែព្រួយរាល់ថ្ងៃព្រោះកូនជីវ៉ា គ្មានចិត្តមេត្តាអាណិតម៉ែសោះ។
កាលកូននៅតូចចិត្តម៉ែសប្បាយ ពេលកូនធំកាយចិត្តម៉ែក្រៀមក្រោះ
ព្រោះកូនសព្វថ្ងៃគិតអ្វីឡេះឡោះ ជ្រុលខូចខ្លួនអស់ប្លែកទាំងចរិយា។
រូបរាងកាយខ្ពស់តែគំនិតខ្លី សម្តីឥតន័យពោលឥតខ្លឹមសារ
សក់វែងក្រហមខៀវលឿងហ៊ីហា មិនស្តាប់នរណាធ្វើតាមចិត្តឯង។
ការងារធ្វើដៃរតែលុយគ្មានសល់ មិនគិតខ្វាយខ្វល់ចាយមិនចេះក្រែង
កាលនៅតូចៗចេះទុកចាត់ចែង ឥឡូវចំបែងខុសពីធម្មតា។
មានកូនបួនដប់តែមិនដឹងគុណ ត្រូវរងទារុណពើតឈឺណាស់ណា
ទុករូបម៉ែចោលឱ្យរស់ឯកា ហេតុអ្វីកនិដ្ឋាឱ្យម៉ែកំព្រា។
អង្រាត្រយប់ស្ងាត់ក្នុងខ្ទមចង្អៀត ភ្លៀងធ្លាក់ខ្លាំងទៀតម៉ែសែនរងា
កង្កែបហ៊ឹងយំនឹកកូនគ្រប់គ្នា ឱរាគ្រាំគ្រាម៉ែទុក្ខទោម្នេញ។
វស្សាទឹកជន់ហូរប្រៀបពេញស្ទឹង រសាត់រឹងៗគ្មានត្រឡប់វិញ
ប្រៀបដូចកូនម៉ែមានជើងដើរចេញ ចាកឆ្ងាយរលេញមិនមករកម៉ែ។
ជំនោរកត្តិកកាយម៉ែត្រជាក់ ខ្លួនម៉ែញ័រញាក់ណាកូនមាសស្នេហ៍
បើកូននៅជិតម៉ែឱបថ្នមថែ ពេលនេះកូនម៉ែរស់នៅឯណា។
ដួងចិត្តម៉ែយំផ្សំដោយទឹកភ្នែក អាសូរខ្លួនពេកសង្វេគឱរា
រាងកាយម៉ែចាស់ស្រវាំងនេត្រា ខ្វះម្ហូបអាហារហូបអត់ហូបឃ្លាន។

ម៉ែចង់រ៉ាយរ៉ាប់ប្រាប់កូនមាសមុំ ថាម៉ែទុក្ខធំក្តីសោករយលាន
ទឹកភ្នែកម៉ែស្រក់កូនមិននៅកៀន ព្រោះកូនម៉ែញៀនតែព្រះដទៃ។
ប្រាំងហើយវស្សាចេះតែកន្លង ចិត្តម៉ែកួចផ្សងឱ្យកូនចេះលៃ
បាបបុណ្យសខ្មៅនិងគុណទោសពៃ ឱ្យកូនគ្រប់វ័យប្រុងប្រាណប្រាជ្ញា។
សូមឱ្យកូនៗចេះស្តាប់ពាក្យម៉ែ កុំបីកែប្រែភ្លេចពុទ្ធសាសនា
រៀនអ្វីរៀនចុះកុំភ្លេចធម៌អាថ៌ ឆ្លាតវៃម្តេចម្តាកុំភ្លេចសីលទាន។
រាងកាយកូនស្អាតសូមចិត្តកូនល្អ សម្បុរកូនសកុំធ្វើបំពាន
កុំធ្វើតាមចង់គ្មានប្លង់កុំហ៊ាន មានទ្រព្យធនធានកុំភ្លេចគំនិត។
បើកូនបានរស់កុំភ្លេចពេលស្លាប់ គួរខំប្រញាប់ធ្វើបុណ្យឱ្យស្និទ្ធ
គួរលះធម៌ថោកកាន់ធម៌ព្រះពិត ទើបបាននៃបនិត្យសុខសួគ៌អមតៈ។

ដោយសាមណេរ **សា ចាន់រ៉ាត់**

(ព្រះគាថាប្រារព្ធចំពោះព្រះមហាកប្បិនត្ថេរៈ)

ធម្មប្បីតិ សុខំ សេតិ វិប្បសន្នេន ចេតសា
អរិយប្បវេទិតេ ធម្មេ សទា រមតិ បណ្ឌិតោ។

បណ្ឌិត ដែលមានសេចក្តីឆ្អែតក្នុងធម៌ មានចិត្តជ្រះថ្លាហើយ រមែងដេកជាសុខ រមែងត្រេកអរ ក្នុងធម៌ដែលព្រះអរិយៈ ប្រកាសទុកហើយ គ្រប់ពេល។

He who drinks in the Dhamma lives happily with a serene mind; the wise man always takes delight in the Dhamma (Bodhipkkhiya Dhamma) expounded by the Noble Ones (ariyas).

២២.សង្ឃមឥន្ទ្រិយ

(បទកាកគតិ)

បណ្តោច្រើនណាស់ ឃើញជួបជាក់ច្បាស់ រឿងតូចរឿងធំ
បើខ្វះស្មារតី ពិតមិនឧត្តម ទុក្ខសោកក្រៀមក្រំ
ច្បាស់មិនសង្ស័យ។
ឧបមាដូចខ្លា កោងកាចឫស្យា បៀតបៀនរាល់ថ្ងៃ
ឱ្យម្រឹគរងទុក្ខ ចំបែងអាល័យ អន្តរាយភិតភ័យ
ព្រោះអំណាចខ្លួន។
រីឯសត្វចាប ឫកពាសុភាព ប្រាជ្ញមិនមាំមួន
ពេលចូលទ្រនុំ ស្រែកយំអង្រួន ពុំសមគាប់ជួន
ច្រើនស្លាប់ព្រោះមាត់។
ដូចប្រុសស្រីខ្លះ ច្រើនខាតប្រាក់កាស ស្មារតីភ្លាំងភ្លាត់
រឿងរ៉ាវតិចតួច មិនចេះហាមឃាត់ ជួបរឿងទៀងទាត់
ព្រោះខ្វះពិចារណ៍។
ភ្នែកឃើញរូបកាយ មាត់មិនឡែបខាយ កុំថ្លូរចរចា
ត្រចៀកឮសូរ ត្រូវមានមេត្តា អត់ធ្មត់ឧស្សាហ៍
ធ្វើថ្លង់ទើបល្អ។
ច្រមុះធុំក្លិន មុនពោលគិតសិន រិះរកខ្មៅស
កុំខឹងស្តីជេរ និន្ទាបន្ត នេះផ្លូវបវរ
នាំឱ្យខ្ពង់ខ្ពស់។
អណ្តាតអត់ឆ្អឹង លិឍភ្លក្សខំប្រឹង ឱ្យបានដឹងរស
ហឹរខារជូរប្រៃ មិនគួរគិតហួស ភ្លេចភ្លាំងជ្រុលជ្រួស

ឆ្ងាញ់ហួសស្មារតី។

កាយតូចធំខ្ពស់	ប៉ះពាល់សម្ផស្ស	មនុស្សសត្វប្រុសស្រី
ត្រជាក់ក្តៅទន់	ត្រូវយល់សេចក្តី	នេះជាចំណី
	ក្តីក្តៅក្រហាយ។	
ចិត្តសែនសំខាន់	ដឹងហើយប្រកាន់	មិនចេះជិនណាយ
ចងពៀរព្យាបាទ	ជាកម្មវែងឆ្ងាយ	ត្រូវដឹងគ្រប់កាយ
	សង្រ្គមតន្ត្រិយ។	
ខ្មែរមានភាសា	មានពុទ្ធសាសនា	ដ៏ល្អគ្មានពីរ
គួរថែរក្សា	កុំបីជាន់ឈ្លី	គួរមានសាមគ្គី
	កសាងជាតិខ្មែរ។	
រឿងល្អស្តីចុះ	ឃើញទោសកំហុស	គួរប្រាប់ឱ្យកែ
មិនត្រូវនិន្ទា	បង្ហូចហូរហៃ	ត្រូវខិតខំថែ
	កេរ្តិ៍ដូនតាខ្មែរ។	

ដោយសាមណេរ **សា ចាន់ភ័ត**



២៣.ចេះធ្វើទៅកើត!

(បទពាក្យជ្រាំបី)

ត្រចៀកឮច្បាស់បែរជាធ្វើថ្លង់ ផ្លូវរៀចថាត្រង់ខុសពីគោលដៅ
ភ្នែកភ្លឺធ្វើខ្វាក់ត្រជាក់ថាក្តៅ អ្នកចេះលង់ខ្លៅពាលធ្វើធំពិត។
អ្នកលង់ធ្វើធំសម្លាប់អ្នកប្រាជ្ញ រឿងនេះគួរខ្លាចសង្គមងងឹត
ហាមាត់បិទគូថរស់នៅគ្មានសិទ្ធិ គួរឱ្យអាណិតស្លាប់អស់រាប់លាន។
មហាលោតផ្លោះសង្គមធ្លាក់សូន្យ ព្រាត់ប្រាសបងប្អូនបាត់បង់ធនធាន
វប្បធម៌សាសនាត្រូវអន្តរធាន បរទេសឈ្លានពានគឺបែកសាមគ្គី។
ព្រះសង្ឃមិនមានវត្តត្រូវវិនាស បដិមារូបព្រះវាយចោលខ្ទេចខ្ទី
វិហារកុដិសង្ឃធ្វើឃ្លាំងដាក់ជី និស្សិតមូលមីរគរឆ្អឹងដូចភ្នំ។
បិទភ្នែកវាយខ្មែរប្រែសង្គមថ្មី សល់តែទឹកដីខ្មែរត្រូវទុក្ខធំ
តើនេះហើយឬកែប្រែសង្គម ឱះឱលោកធំចេះធ្វើទៅកើត?
បានកើតជាខ្មែរកុំប្រែភ្លេចខ្លួន ចេះសាសន៍ចិនយួនកុំភ្លេចកំណើត
ថៃពុកម៉ែចាស់លោកអ្នកបង្កើត ឈ្មោះអ្នកល្អឆើតសមជាកូនខ្មែរ។
សាសនាព្រះពុទ្ធគួរថែរក្សា កុំបានដុល្លារផ្លាស់ចិត្តប្រួលប្រែ
បោះបង់មើលងាយជិះជាន់ជាតិខ្មែរ ដូច្នេះគួរតែថែកេរ្តិ៍ខ្មែរយើង។

ដោយសាមណេរ **សា ចាន់ណាត់**



២៤.ម៉ែឈឺណាស់កូន

(បទពាក្យជ្រាំពីរ)

ថ្ងៃរះហើយលិចជាធម្មតា ដូចគ្រប់សង្ខារកើតហើយស្លាប់
វិលវល់ចុះឡើងភ្លឺស្រអាប់ ពើតឈឺចុកចាប់ហួសនឹងថ្លែង។
បណ្តាពួកសត្វកើតក្នុងគភ៌ ត្រូវភ័យញាក់ញ័រគ្រប់កន្លែង
ពិសេសគឺមនុស្សដែលឃើញស្តែង លំបាកក្រៃលែងគ្រប់មាតា
ថ្ងៃសត្វកើតមកក្នុងភគ៌ម៉ែ អ្វីៗប្រួលប្រែខុសធម្មតា
ម្តងស្រេកម្តងឃ្លានទូវអាហារ ឃ្លានហឺរជូរខារសព្វទិវា
បាំងពីរបីខែម៉ែដឹងខ្លួន ថាកូនមាសស្អួនមានជន្មា
ម៉ែលួចត្រេកអរឃើញពុំងា ម៉ែភ័យវេទនានៅថ្ងៃមួយ។
យប់ថ្ងៃកន្លងពោះម៉ែធំ ម៉ែខ្លាចណាស់មុំចិត្តសែនព្រួយ
ម៉ែបន់ទេវតាសូមឱ្យជួយ ម៉ែសូមជំនួយពីដួនតា។
កូនអើយនៅថ្ងៃម៉ែប្រសូត ស្ទើរតែរបូតចាកលោកា
ម៉ែសែនអួលក្តៅសព្វកាយា ញើសឈាមនោះណាធ្លាក់ស្ទើរអស់។
សាច់ម៉ែស្លេកស្លាំងកម្លាំងខ្សោយ ដង្ហើមចុងក្រោយក៏គ្មានសោះ
ម៉ែបាត់ស្មារតីមុខក្រៀមក្រោះ នៅគ្រាចន្លោះកូនកើតមក។
ពេលម៉ែភ្ញាក់ខ្លួនអស់កម្លាំង ព្រោះម៉ែឈឺខ្លាំងណាស់ពន្លក
ម៉ែឱបក្រសោបធ្វើជម្រក បំបៅពន្លកពេលថ្មីៗ។
បុត្រថ្លៃចរណៃបណ្តូលចិត្ត ម៉ែសែនអាណិតកូនពិសី
ដូចបានឆ្លងផុតជ្រោះអវិចី ម៉ែលែងព្រួយភ័យណានួនល្អង។
កូនអើយថ្ងៃម៉ែឆ្លងទន្លេ គឺមិនស្រួលទេទុក្ខកន្លង
ចុកស្តឹកស្រពន់ឈឺឆ្អឹងខ្នង ដួងចិត្តម៉ែផ្សងឆ្លងគ្រោះថ្នាក់។

ម៉ែយំម៉ែស្រែកទប់មិនបាន　　វេទនាក្នុងប្រាណក្តៅអួលអាក់
ភ្នែកម៉ែស្រវាំងប្រៀបដូចខ្វាក់　　ញើសហូរសស្រាក់ហួសបរិយាយ។
កូនអើយម៉ែឈឺឥតឧបមា　　ថ្ងៃកូនកើតណាស្រស់ឆោមឆាយ
ពេលកូនធំប្រាណកុំភ្លេចម្តាយ　　ហើយកុំសប្បាយភ្លេចគុណម៉ែ។

ដោយសាមណេរ **សា ចាន់ណាត់**

(ព្រះគាថាប្រារព្ធចំពោះអាយុវឌ្ឍនកុមារ)

អភិវាទនសីលិស្ស　　និច្ចំ វុឌ្ឍាបចាយិនោ
ចត្តារោ ធម្មា វឌ្ឍន្តិ　　អាយុ វណ្ណោ សុខំ ពលំ។

ធម៌ ៤ ប្រការគឺ អាយុ ១ វណ្ណៈ ១ សុខៈ ១ ពលៈ ១ រមែងចម្រើនដល់អ្នក ដែលមានសេចក្តីឱនកាយថ្វាយបង្គំជាប្រក្រតី មាន សេចក្តីកោតក្រែង ដល់បុគ្គលដែលចម្រើនជាងខ្លួន អស់កាលជានិច្ច។

For one who always respects and honours those who are older and more virtuous, four benefits, viz., longevity, beauty, happiness and strength, will increase.

២៥.សាមគ្គីភ្លាឡើង

(បទពាក្យជ្រាំពីរ)

រៀបរាប់ណែនាំតាមអក្ខរា ប្រាប់ជនខេមរាទាំងប្រុសស្រី
រស់រានសាមគ្គីដោយឃ្មាតខ្មី ថែថួនទឹកដីកេរ្តិ៍ជូនតា។
វប្បធម៌ខ្មែរល្អក្រគ្មានពីរ មានប្រពៃណីខ្ពស់ថ្លៃថ្លា
ខ្មែរមានអក្សរល្អភាសា សុភាពរាបសាស្តីពីរោះ។
ទឹកដីកេរ្តិ៍ខ្មែរសម្បូរជី ប្រាសាទមូលមីរស្អាតខ្ពង់ខ្ពស់
សិល្បៈរបាំល្បីកេរ្តិ៍ឈ្មោះ ប្រជាបានរស់សុខឥតហ្មង។
កវីបណ្ឌិតពិតឧត្តម ស្មារតីខិតខំក្រែកន្លង
បន្សល់ស្នាដៃដូចស្ពានឆ្លង ទុកជូនប្អូនបងចងជាកេរ្តិ៍។
កូនចៅកើតទាន់ជំនាន់ក្រោយ មិនគួរបណ្តោយគួរអិះរេ
សិក្សាថែទាំកុំថាទេ កុំខឹងស្តីជេរល្មើសភ្លេចខ្មែរ។
សិក្សាបានខ្ពស់យសឧត្តម មិនត្រូវបន្លំភ្លេចឪម៉ែ
កុំបានរស់ក្រុងមើលងាយស្រែ គួរខិតខំថែវប្បធម៌ជាតិ។
យុវជនក្លាហានត្រូវដឹងខ្លួន ស្រឡាញ់ជាប់ជួនកុំវិវាទ
ថែទាំភាសានិងមារយាទ ផ្សព្វផ្សាយថែមទៀតរឿងល្អៗ។

ដោយសាមណេរ **សា ចាន់ណាត់**



២៦.ម៉ែពិតជាមានគុណ

(បទពាក្យជ្រាំពីរ)

ពពោះប្រសូតស្រេចលើម៉ែ អស់ប្រាំបួនខែនិងដប់ថ្ងៃ
ទឹកក្តៅត្រជាក់ធ្វើផ្ទាល់ដៃ ហឺរខារជូរប្រៃតមអាហារ។
ដេកដើរអង្គុយប្រុងបំផុត ថ្នមលើសបានម្តុដពីទេវតា
ព្រោះគភ៌ឡើងធំខុសធម្មតា រមួលចុកផ្សាមិនគប្បី។
សាច់ផ្តើមចើមធំស្បែកស្លេកស្លាំង ថមថយកម្លាំងខ្សោយស្មារតី
មិនឃ្លានបាយទឹកម្ហូបចំណី ក្នុងចិត្តមមែចង់ឃើញបុត្រ។
បេះដូងម៉ែមានព្រហ្មវិហារ ស្នេហ៍បុត្រពុំងាថ្លៃវិសុទ្ធ
យប់ថ្ងៃម៉ែសូមឱ្យឆ្លងផុត គ្រោះកាចបំផុតឆ្លងទន្លេ។
ឱះឱកូនស្ងួនបណ្តូលចិត្ត មេឃខ្មៅងងឹតខ្យល់បក់រេ
ពពករសាត់ព្រះចន្ទជ្រេ ម៉ែឈឺម្ល៉េះទេសព្វរាងកាយ។
ខ្មមតូចជរាប្រក់ស្បូវភ្លាំង ម៉ែឈឺស្ទើរគាំងហួសបរិយាយ
ភ្លៀងធ្លាក់ទឹកជន់ណាឆោមឆាយ ខ្វះម្ហូបទឹកបាយនិងអាហារ។
ជញ្ជាំងបាំងខ្យល់បិទវាំងនន ម៉ែប្រសូតកូនអនាថា
ក្រាលកន្ទេលកក់ឆ្អើរភ្លើងណា ដូចសាច់គេអារឆ្អើរភ្លើងក្តៅ។
កូនកើតមកភ្លាមស្រែកយំង៉ា ម៉ែស្តុតចិន្តាណាស់ឆោមឆ្ងៅ
ម៉ែអត់បានដេកខ្លួនហ្មងសៅ ភ្នែកម៉ែឡើងក្តៅណាជីវ៉ា។
ម៉ែបានដឹងខ្លួនស្រវាបី លើកកូនពិសីដោយហត្ថា
ឱ្យកូនបៅដោះដោយស្រស់ថ្លា ភ្លេចក្តីឈឺផ្សាទាំងប៉ុន្មាន។
ម៉ែថ្នមបំពេបុត្រចរណៃ អស់គ្រាយប់ថ្ងៃមិនសម្រាន្ត
ងូតទឹកដុសលាងសព្វអង្គប្រាណ ឱ្យតែកល្យាណមានសិរី។

ម៉ែពិតជាព្រះដ៏ច្បាស់ច្បង ប្រសើរកន្លងក្នុងលោកិយ
ម៉ែជាជម្រកកូនប្រុសស្រី ក្នុងភពផែនដីដ៏អស្ចារ្យ។
ម៉ែប្រៀបបីដូចជាគង្គា កូនៗគ្រប់គ្នាដូចមច្ឆា
គុណម៉ែប្រៀបដូចព្រះសូរិយា បំភ្លឺលោកាឱ្យឃើញច្បាស់។
គុណម៉ែដូចចន្ទពេញបូណ៌មី ក្នុងពេលរាត្រីមេឃស្រឡះ
ផែនដីដូចកូនសុខខ្លាំងណាស់ គុណម៉ែក្រៃក្រាស់លើសប្រឹថពី។
សិក្សាគុណម៉ែគួរគោរព ត្រជាក់លើសម្លប់ព្រៃគិរី
ព្រោះគុណបរិសុទ្ធល្អគ្មានពីរ កូនត្រូវសំពីតបគុណលោក។

ដោយសាមណេរ **សា ចាន់ណាត់**



(ព្រះគាថាប្រារព្ធចំពោះឆព្វិយនិក្ខ)

សព្ពេ តសន្តិ ទណ្ឌស្ស សព្ពេសំ ជីវិតំ បិយំ
អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ។

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា (ព្រោះថា) ជីវិតជាទីស្រឡាញ់របស់សត្វទាំងឡាយ បុគ្គលគួរធ្វើខ្លួនឱ្យជាឧបមា ហើយមិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេឱ្យប្រហារឡើយ។

All are afraid of the stick, all hold their lives dear. Putting oneself in another's place, one should not beat or kill others.

២៧.ថៃកេរ្តិ៍ដូនតា

(បទពាក្យជ្រាំពីរ)

ហត្ថាទាំងទ្វេចាប់ប៉ាកកា ថ្លាថ្លែងអក្ខរាប្រាប់ប្រុសស្រី
រៀបរាប់តាមដឹងប្រឹងស្មារតី កតញ្ញូខន្តីចូរគិតខ្មែរ។
ទឹកដីសីមាថៃឱ្យគង់ កុំឱ្យលិចលង់ប្តូរប្រួលប្រែ
ប្រាសាទថ្មល្អខិតខំថែ ព្រៃភ្នំវាលស្រែផ្លូវបើកបរ។
វប្បធម៌សាសនាភាសាជាតិ ចរិយាមារយាទថៃឱ្យល្អ
កុំធ្វេសបរទេសចូលជាន់ក ខ្មែរកាន់តែក្រចិនយួនមាន។
ខិតខំសិក្សាឧស្សាហ៍គិត ដីខ្មែរល្អពិតគេឈ្លានពាន
សម្បត្តិខ្មែរច្រើនខ្វះធនធាន ខ្មែរអើយខំរៀនសាមគ្គីគ្នា។
សម្តីពីរោះយសឧត្តម តាំងខ្លួនឱ្យសមកុំនិន្ទា
ឃើញល្អគាំទ្រជួយការពារ កុំបីនិន្ទាធ្មេចនេត្រា។
សិល្បៈរបាំចាំកុំភ្លេច មរតកមាសពេជ្រពីដូនតា
កុំខ្ពស់ភ្លេចខ្លួនក្រែងខ្លោចផ្សា បាត់បង់ខេមរាជាតិអន្តរាយ។
កើតក្នុងពោះម៉ែជាខ្មែរម្នាក់ កុំភ្លើភ្លេចធ្លាក់ធម៌អបាយ
បោះបង់ជាតិខ្លួនពួនសប្បាយ ខ្មែរអើយរាល់កាយប្រុងស្មារតី។

ដោយសាមណេរ **សា ចាន់ណាត់**



២៨.អាសូរម្តាយខ្ញុំ

(បទពាក្យជ្រាំពីរ)

សំឡេងបក្សីព្នៃរងំ　　នឹកម្តាយភិរម្យឆ្ងាប់ថ្មមបី
ចិញ្ចឹមថៃកូនទាំងប្រុសស្រី　　ដោយចិត្តភក្តីគ្មានគេចកែ។
ទឹកហូរទៅបាត់ខ្យល់ផាត់រឹង　　ក្នុងចិត្តរំពឹងឃើញពុកម៉ែ
គាត់រស់នៅឆ្ងាយចម្ការស្រែ　　គ្មានអ្នកមើលថែរស់យ៉ាងណា។
ឱម្តាយពន្លកស្មើជីវិត　　ពេលនេះឃ្លាតពិតកូនសោកា
នឹកឃើញគ្រាតូចម៉ែផ្តាំថា　　ធំឡើងកនិដ្ឋាមើលម៉ែចាស់។
ដឹងហើយដកស្នងការងារស្រែ　　ពុំសូវបានល្ហែម៉ែខំណាស់
ភ្ជួរដីខ្លួនឯងឆ្លៀតជីកស្រះ　　ថ្ងៃក្តៅស្រឡះម៉ែមិនឈប់។
ចំណីអាហាររកឱ្យកូន　　មិនឱ្យដាច់សូន្យខំសព្វគ្រប់
ខំអើយសែនខំទាំងថ្ងៃយប់　　កូនជ្រកក្រោមម្លប់សុខពេកក្រៃ។
អង្រឹងកូនគេងម៉ែបំពេ　　ហត្ថាទាំងទ្វេបីចរណៃ
យកខ្លួនបាំងខ្យល់សក់បាំងថ្ងៃ　　កូនតូចថ្លើមថ្លៃបៅដោះម្តាយ។
ទឹកដោះគឺឈាមកូនជញ្ជក់　　ឆ្អែតហើយដេកលក់មិនខ្វល់ខ្វាយ
ម៉ែឆ្លៀតធ្វើការរៀបទឹកបាយ　　ទុកជូនឆោមឆាយពេលកូនភ្ញាក់។
ពុះឱសរែកទឹកឆ្លៀតបោសផ្ទះ　　ម៉ែខំរូតរះឥតទាស់ទាក់
បោកគក់ខោអាវជូនរលក្ខណ៍　　ទឹកក្តៅត្រជាក់ថៃពាលពៅ។
មើលចុះម៉ែស្គមអស់កម្លាំង　　ដៃជើងស្លេកស្លាំងគ្មានរាងរៅ
ខោអាវក៏ចាស់មួយជាប់នៅ　　សំពត់នោះកូវក៏រហែក។
ត្រជាក់រងាស្រែកឃ្លានបាយ　　ចិត្តម៉ែមិនណាយរឹងជាងដែក
តស៊ូថៃកូនស្រស់អនេក　　គឺពិតជាប្លែកលើលោកា។

ទឹកចិត្តអ្នកម្តាយថ្លៃពេកពន់ គុណច្រើនសែនធ្ងន់ឥតឧបមា
ធំហួសព្រៃភ្នំវាលព្រឹក្សា ឬអាកាសាទ្វីបទាំងបួន។
គុណធំអនេកចំឡែកចិត្ត ឮហើយអាណិតម៉ែផ្ទួនៗ
ចិញ្ចឹមថែកូនចិត្តមាំមួន ស៊ូជួយមាសស្ងួនចិត្តនឹងធឹង។
ទឹកចិត្តព្រះណាស្មើពុកម៉ែ បង្កើតថ្មមថែពៅព្រលឹង
កូនស្រែកយំខ្លាំងលោមបាត់ឈឹង បីដូចជាស្ទឹងខែវស្សា។
ថាទឹកត្រជាក់ចាញ់ចិត្តម៉ែ ភ្លឺដូចដួងខែចាញ់មាតា
សមុទ្រសែនធំឥតឧបមា គឺព្រះត្រាស់ថាតូចជាងម៉ែ។
គុណល្អយ៉ាងហ្នឹងប្រឹងឱ្យបាន កូនចៅគ្រប់ប្រាណកុំភ្លេញភ្លែរ
តបគុណលោកវិញរាល់ថ្ងៃខែ កុំមានភ្លេចម៉ែឱ្យកំព្រា។
អាសូរម្តាយខ្ញុំដូចម្តាយគេ ហត្ថាទាំងទ្វេសូមវន្ទា
ថ្វាយបង្គំគុណម៉ែគ្រប់គ្នា ក្តីសុខនានាកូនជូនម៉ែ។
ដោយបុណ្យកូនសាងទាំងប៉ុន្មាន ជូនម៉ែគ្រប់ប្រាណកុំមានឃ្លោត
សីលទានទាំងអស់កូនជូនញាតិ សូមជួបម៉ែទៀតតរៀងទៅ។
សូមឱ្យអ្នកម្តាយជួបសួស្តី ជាតិនេះជាតិថ្មីកុំអាស្រូវ
បើម៉ែមានកូនដើរត្រូវផ្លូវ ចិញ្ចឹមម៉ែឪតទៅអើយ។

ដោយសាមណេរ **សា ចាន់ភ័ត**



២៩.ប្រភពបញ្ញា

(បទពាក្យជ្រាំបី)

លង់ខ្លៅឈ្លាសវៃអាស្រ័យប្រាជ្ញា　　ឃោរឃៅឫស្យាព្រោះទោសៈចិត្ត
បន្ទំឆបោកជាទោសទុច្ចរិត　　សុខក្នុងជីវិតជាផលបុណ្យចាស់។
ខ្ពង់ខ្ពស់ថោកទាបអាស្រ័យលើកម្ម　　គំនិតសាំញ៉ាំមកពីមិនច្បាស់
លោភៈក្នុងចិត្តនាំឱ្យក្រណាស់　　តណ្ហាសែនក្រាស់ចង់មិនរសាយ។
សាងសីលធ្វើបុណ្យជាផ្លូវសួគ៌ា　　និន្ទាចងពៀរជាផ្លូវអបាយ
ចង់ឈ្នះចាញ់គ្នាជាពូជខ្វល់ខ្វាយ　　ចិត្តស្ងប់សុខកាយជាផលខន្តី។
ជួញដូរគេចគយជារឿងគេចពន្ធ　　ការតែងនិពន្ធជារឿងកវី
កុហកញុះញង់ជាទោសសម្តី　　ធ្លាក់ដល់អវិចីព្រោះក្តីប្រមាទ។
មើលងាយដៀលគេរឿងខ្វះមេត្តា　　ខឹងប្រើហិង្សាជាធម៌មិនស្អាត
លង់ខ្លៅក្រទ្រព្យព្រោះមិនសង្វាត　　កោងកាចហួសខ្នាតជាពូជវេរា។
ទូន្មានផ្លូវចិត្តជាផ្លូវនិព្វាន　　លះទ្រព្យធ្វើទានព្រោះមានសទ្ធា
វិលវល់កើតស្លាប់ព្រោះអវិជ្ជា　　បញ្ហានានាពិតមានប្រភព។

ដោយសាមណេរ **សា ចាន់ភ័ត**



៣០.រិះគន់ដើម្បីស្ថាបនា

(បទពាក្យជ្រុំពីរ)

ហាស្លាក់ខ្លាក់ស្លែងសម្តែងប្រាប់ បើពោលត្រូវច្បាប់ខុសចិត្តញាតិ
ឃើញខុសថាត្រូវនឹងឃ្លៀងឃ្លាត បង្កវិវាទទាស់គំនិត។
បើសថាខ្មៅខុសសច្ច: ភ្នែកភ្លឺធ្វើខ្វាក់រឿងមិនពិត
ពន្លឺភ្លឺច្បាស់ថាងងឹត នេះហៅប្រឌិតអគតិ។
ត្រចៀកឮច្បាស់តាមផ្លូវប្លង់ ប្រែប្រួលធ្វើថ្លង់ខូចសតិ
ទះដៃអបអរទាំងទិដ្ឋិ នេះគឺអស្មិមានៈថោក។
អណ្តាតអត់ឆ្អឹងប្រឹងគ្រលាស់ បានត្រឹមដឹងរសអាហារជោក
ហឹរខារជូរប្រៃឆ្ងាញ់ស្មោកគ្រោក សប្បាយវិយោគជាធម្មតា។
សរសើរលើកជើងភ្លើងមាននះ ប្រកាន់យកឈ្នះចិត្តឥស្សា
ការពិតក្នុងលោកខ្ជិលសិក្សា ជឿបានដុល្លារមិនខ្វល់គិត។
សាសនាព្រះពុទ្ធទូន្មានច្បាស់ តែកិលេសក្រាស់ខ្មៅងងឹត
មោហៈវង្វេងបាំងការពិត ដុតរោលរួបរឹតស្លាប់ទាំងរស់។

ដោយសាមណេរ **សា ចាន់ភ័ត**



៣១.គួរដឹងរឿងពិត

(បទពាក្យជ្រាំពីរ)

ពេលមានជីវិតគិតធម៌អាថ៌ ធម៌អនិច្ចាកុំរសាយ
ទុក្ខធំក្នុងខ្លួនមិនសប្បាយ គួរដឹងរាល់កាយអនត្តា។
មានពេលទំនេរអានសៀវភៅ ជួយបង្ហាញផ្លូវជួបសុខា
ឆ្លៀតស្តាប់គេខ្លះរកប្រាជ្ញា កុំអួតអាត្មាប្រកាន់ខ្លួន។
អ្នកកុំបោះបង់ច្បាប់ក្បួនខ្នាត គួរតែសង្វាតឱ្យខ្ជាប់ខ្ជួន
ចំណេះវិជ្ជាមានមាំមួន ទើបបានរួចខ្លួនពីអវិជ្ជា។
មានះក្នុងខ្លួនពួនសាងកម្ម ទិដ្ឋិសាំញាំជាវេរា
វិលវល់ក្នុងភពរាល់វេលា បើខ្វះធម្មាសែនកម្សត់។
ប្រាថ្នាក្តីសុខត្រូវស្គាល់ប្លង់ កុំតាមចំណង់នាំឱ្យហត់
ធ្វើដោយស្មារតីមានអំណត់ ទើបសន្តិបទផ្តល់សុខា។
កើតក្នុងមួយជាតិកុំឃ្លាតគិត ត្រិះរិះរឿងពិតក្នុងសាសនា
កុំជឿឱ្យធំជាងបញ្ញា ឮតាមគេថាជឿផ្តាប់មុខ។
ធ្វើល្អបានល្អកម្រដឹង តែរឿងមួយហ្នឹងខំសម្រុក
ភ្លក្លឹកល្បីល្បាញអស់ទាំងស្រុក ចុងក្រោយសំកុកខុសបំណង។

ដោយ**សាមណេរ សា ចាន់ណាត់**



៣២.ខ្ញុំនយើងជាខ្មែរ

(បទពាក្យជ្រាំពីរ)

ពាក្យខ្មែរប្រៃថាសុខក្សេមក្សាន្ត　　រឹងមាំថ្កើងថ្កានមានទឹកដី
ភាសាអក្សរល្អប្រិមប្រិយ　　រន្ទឺល្បាញល្បីក្នុងសកល។
វប្បធម៌ខ្ពង់ខ្ពស់យសខ្មែរល្អ　　ស្លៀកពាក់បវរមិនបាច់ខ្វល់
ចងក្បិនអាវប៉ាក់មិនគួរខ្វល់　　បិទបាំងគ្មានសល់ខ្លួនប្រាណជិត។
សម័យទំនើបវិទ្យាសាស្ត្រ　　មិនសូវរៀនខ្មាសបង្ហាញផ្ទិត
ខើចលើខើចក្រោមអាងមានសិទ្ធិ　　បង្ហាញមិនគិតខ្លួនជាខ្មែរ។
នៅក្មេងចេះស្លៀកបិទបាំងជិត　　ដល់ធំអាងសិទ្ធិភ្លេចកេរ្តិ៍ម៉ែ
ដើរហើរឡួយឆាយប្តូរប្រួលប្រែ　　ម៉ាស្សាហូរហែមុខដូចព្រាយ។
សក់ក្បាលក្រហមវែងអន្លាយ　　គេដៀលដល់ម្តាយមើលពេបជ្រាយ
ទូរស័ព្ទសាសងចិត្តទន់ងាយ　　រោវរាយមាយកូនអត់ប្តី។
គួរអនិច្ចាសង្វេគណាស់　　ក្មេងមើលងាយចាស់ភាន់ស្មារតី
ថាចាស់បុរាណមិនដឹងអ្វី　　មនុស្សសម័យថ្មីយ៉ាងហ្នឹងហើយ។
ការីកចម្រើនមិនហាមឃាត់　　រឿងមិនគួរភ្លាត់សីលធម៌ឡើយ
មិនគួរភ្លេចភ្លាំងភាំងតោះតើយ　　ចាំកុំភ្លេចឡើយយើងជាខ្មែរ។

ដោយសាមណេរ **សា ចាន់ណាត់**



៣៣.រូបមន្តជីវិត

(បទពាក្យជ្រាំពីរ)

ជីវិតប្រៃថាធ្វើដំណើរ ជីវិតប្រសើរព្រោះវិជ្ជា
ជីវិតសុខស្ងប់បានសុខជា ព្រោះមានមាគ៌ាពិតប្រាកដ។
ប្រសើរខ្ពង់ខ្ពស់រស់ឧត្តម ស្មារតីខិតខំមានអំណត់
កាន់ការងារអ្វីបានហ្មត់ចត់ ទើបមានបែបបទរស់ថ្លៃថ្លា។
រស់រានមានសីលសុខស្ងប់ស្ងាត់ តែងសោយសម្បត្តិមនុស្សទេវតា
ធ្វើបុណ្យសុន្ទរ៍ទានមានមេត្តា ប្រុងប្រៀបប្រាជ្ញាលះធម៌ខ្មៅ។
មនុស្សល្អសែនក្រក្នុងលោកិយ បើពាលអប្រិយមិនបាច់ហៅ
មានច្រើនស្អេកស្កះដុះដូចស្មៅ មិនផុតពូជផៅពង្សនេះសោះ។
ចំណង់ចង់សុខស្ងប់ក្សេមក្សាន្ត តែមិនអាចបានត្រូវក្រៀមក្រោះ
ត្រូវរងទុក្ខសោកស្លាប់ទាំងអស់ រូបមន្តសប្បុរសធម៌ព្រះពុទ្ធ។
រស់ហើយគោរពរតនត្រ័យ ខំភ្ជាប់និស្ស័យផ្លូវបរិសុទ្ធ
បាបកម្មទាំងឡាយជៀសឱ្យផុត ឈ្មោះថាពាក់ម្កុដទៅស្ថានសួគ៌។

ដោយសាមណេរ **សា ចាន់ភ័ត**



៣៤.ស្មារតីឧត្តម

(បទពាក្យជ្រុំពីរ)

ថ្លាថ្លែងរៀបរាប់ពីស្មារតី　　នាំយសសិរីក្នុងជីវិត
បើខ្ជិលច្រអូសនឹងងងឹត　　មិនដឹងធម៌ពិតខ្វល់ចំបែង។
ស្មារតីកើតឡើងពីការស្តាប់　　បាលីសារស័ព្ទគ្រប់កន្លែង
ត្រិះរិះរឿងរ៉ាវដោយថ្លឹងថ្លែង　　បែងចែកចាត់ចែងរឿងដោយល្អ។
ឆ្ងល់សួរសំណួររាល់ចម្ងល់　　កម្ចាត់កង្វល់រកខ្មៅស
សាកសួរស្រាវជ្រាវប្រឹងបន្ត　　នេះផ្លូវបវរនាំកើតបញ្ញា។
កត់ត្រាចំណាំចាំពាក្យពេចន៍　　រំលឹកកុំភ្លេចរាល់ខ្លឹមសារ
ទន្ទេញអានថែមប្រឹងឧស្សាហ៍　　កម្ចាត់មោហាឆ្ការលង់ខ្លៅ។
តូចធំចាស់ក្មេងអាស្រ័យវ័យ　　លង់ឆ្លាតឈ្លាសវៃមានគោលដៅ
បញ្ញាកើតឡើងទាំងក្នុងក្រៅ　　ច្បាប់ប្រៀនប្រដៅចូរចងចាំ។
ស្មារតីឧត្តមព្រោះខំរៀន　　ចំណេះរបៀនរាល់ខែឆ្នាំ
ស្តាប់គិតសាកសួរកត់ចំណាំ　　នេះពាក្យបណ្តាំត្រូវយល់ដឹង។

ដោយសាមណេរ **សា ចាន់ង៉ាត់**



៣៥.ឧត្តមគតិ

(បទព្រហ្មគីតិ)

លើកពាក្យប្រាប់ប្រុសស្រី ដាស់ស្មារតីទាំងតូចធំ
សាមគ្គីប្រមូលផ្តុំ គ្រប់និគមស្រុកភូមិស្ថាន។
កើតមកជាកូនខ្មែរ កុំភ្លេចម៉ែញាតិសន្តាន
ចំណេះប្រឹងគ្រប់ប្រាណ រៀនកុំខានប្រឹងខ្មីឃ្មាត។
រាប់អានញាតិជិតខាង កុំក្អេងក្អាងឈ្លោះវិវាទ
ចរិតនិងមារយាទ មិនគួរឆ្លៀតមើលងាយគេ។
ក្បួនច្បាប់រៀនកុំភ្លេច ស្តីពាក្យពេចន៍ខឹងកុំជេរ
ធ្វើអ្វីត្រូវរិះរេ ពេលទំនេរធ្វើបុណ្យទាន។
ទឹកដីព្រៃព្រឹក្សា ថែរក្សាការឈ្លានពាន
យុទ្ធសាស្ត្រគ្រប់របៀន ត្រូវប្រិតប្រៀនរៀនទាំងអស់។
រៀនច្បាប់ឱ្យផ្ចិតផ្ចង់ ត្រូវស្មោះត្រង់កុំចន្លោះ
កុំលួចទ្រព្យរបស់ កុំឡេះឡោះភ្លេចដូនតា។
លាភយសខ្ពស់ឧត្តម កុំបន្លំភ្លេចសាសនា
ស្រឡាញ់ជាតិខេមរា ទើបឈ្មោះថាជាកូនខ្មែរ។

ដោយសាមណេរ **សា ចាន់ណាត់**



៣៦.កថីសូមផ្តាំ

(បទព្រហ្មគីតិ)

បឋមសូមលើកហត្ថ ប្រណិប័តន៍គុណកែវបី
សូត្រធម៌ឱនសិរសី កាត់ខ្លីៗដោយជ្រះថ្លា។
រំលឹកគុណពុកម៉ែ គ្រូផងដែរគ្រប់រូបា
ចិញ្ចឹមថែរក្សា ផ្តល់សុខាដំបូន្មាន។
បន្ទាប់នឹងពោលប្រាប់ អោហារស័ព្ទដែលខ្លួនមាន
ប្រាប់ជនឱ្យប្រិតប្រៀន គ្រប់របៀនរៀនឱ្យច្បាស់។
អ្វីៗកើតមានហេតុ ច្បាស់ក្រឡែតប្រាកដណាស់
សត្វលោកមោហៈក្រាស់ ទាំងក្មេងចាស់អវិជ្ជា។
កើតមកលើលោកា ទាន់សាសនាព្រះភគវា
ជាលាភធំមហិមា គួរស្មុះស្មាសាងកុសល។
សាសនាមិនវែងឆ្ងាយ ក្តីអន្តរាយនឹងមកដល់
វីរក់កើតខ្វាយខ្វល់ ចលាចលគ្រប់កន្លែង។
ឥឡូវក៏ឃើញច្បាស់ មិនអៀនខ្មាសមិនកោតក្រែង
ធ្វើអ្វីតាមចិត្តឯង អួតក្តែងៗខុសតម្រា។
សីលប្រាំចាំមិនច្បាស់ ប្រព្រឹត្តផ្តាសតាមតណ្ហា
ជក់ថ្នាំញៀនយ៉ាម៉ា សេពសុរាឆ្គួតលីលា។
ក្មេងខ្លះភ្លើភ្លេចខ្លួន ទៅជាប់ជួនឆ្លងរោគា
កើតអេដស៍មើលលែងជា សែនវេទនាទុក្ខក្រៀមក្រំ។
សក់ក្បាលដូចភ្លើងឆេះ ស្លៀកសំយេះមិនសាកសម
លាបឡេម៉ាស្សាផ្សំ មើលឱ្យចំដូចបិសាច។

ទំនេរជិះឌុបគ្នា ធឹកស្រាបៀរស្រវឹងកាច
ឮហើយគួរឱ្យខ្លាច អាងអំណាចទ្រព្យបុណ្យសក្តិ។
ស្រីខ្លះកាន់ឫកឆ្នាស ពូកែណាស់វាយកាប់ចាក់
ភ្លីភ្លើងអាងមាសប្រាក់ ជាប់ច្រវាក់ខូចកេរ្តិ៍ម៉ែ។
ទៅរៀនដើរញ៉ៀប្រុស ប្រព្រឹត្តខុសតាមប្រុសស្នេហ៍
ពោះធំជិតគ្រប់ខែ គ្មានប្តីថែក្បត់មេបា។
ខ្ញុំប្រាប់អ្នកកុំខឹង ពោលតាមដឹងមិនមុសា
ឃើញច្បាស់តាមសួនច្បារ សិស្សសាលាក៏មានដែរ។
ទៅរៀនគេចសាលា ទៅស្នេហាតាមវាលស្រែ
ចូលបាជួបគូស្នេហ៍ ធឹកហូរហែច្រៀងរាំផង។
ប្រុសខ្លះធ្វើជើងកាង អួតក្អេងក្អាងភ្លេចប្អូនបង
ស្រីស្រាល្បែងស៊ីសង ដាច់ចំណងស្តីលែងបាន។
ចាស់ខ្លះឫកអ្នកលេង យកស្រីក្មេងប្រលោមប្រាណ
មាសប្រាក់ដូរទិញឡាន ឱ្យតែបានផ្គាប់តណ្ហា។
យាយខ្លះចាស់តែឈ្មោះ រឿងក្នុងពោះឥតបានការ
ចាំផ្ទះភ្លេចវត្តវ៉ា ខឹងឡូឡាស្តីមិនគិត។
តាខ្លះចាស់តែសក់ ពោលកុហកស្តីមិនពិត
ទានសីលមិនដែលគិត អួតអាងសិទ្ធិខុសម្យ៉ាង។។
អ្នកខ្លះបានរៀនខ្ពស់ អាងកិត្តិយសដូចជើងកាង
ទ្រព្យធនមានអស់យ៉ាង គ្មានសំណាងកើតបណ្ឌិត។
លោកធម៌មានប្រាំបី ព្រះជិនស្រីទ្រង់ត្រាស់ពិត
ដឹងហើយកុំជាប់ស្អិត គួរិះគិតសព្វទិវា។

សព្វសត្វគ្រប់រូបា ប៉ងប្រាថ្នាជួបសុជា
សុខទុក្ខជាគូគ្នា បានធូរធារកុំភ្លេចក្រ។
អ្នករស់កុំភ្លេចស្លាប់ គួរប្រញាប់ធ្វើកម្មស
រស់រៀនសាងតែល្អ បុណ្យកំដរជួយលើកស្ទួយ។
បានកើតទាន់សាសនា ព្រះសម្មាមានតែមួយ
សាងបុណ្យៗនឹងជួយ អ្នកកុំព្រួយពិតជួយបាន។
បើរស់មិនសាងល្អ ច្បាស់វ័ណ្ណកជាមិនខាន
នរកធ្លាក់ដូចច្រាន ប្រេតតិរច្ឆានទៀងប្រាកដ។
ពាក្យកាព្យមានវែងខ្លី សូមអភ័យរាល់បាទបទ
វេលាមានកំណត់ សូមសន្មត់ចប់ឯង។

ដោយសាមណេរ **សា ចាន់រ៉ាត់**

៣៧.ស្នេហាវប្បធម៌ផងថ្លៃ

(បទពាក្យប្រាំពីរ)

អូ!ហូ!កវីសូមថ្លែងប្រាប់ សរសេរកូនច្បាប់សង្ខេបខ្លី
តាមការយល់ឃើញជូនប្រុសស្រី ខ្វះខាតម្តេចក្តីសូមមេត្តា។
ថ្លាថ្លែងសម្តែងមនុស្សឥឡូវ ប្រព្រឹត្តខុសផ្លូវច្បាប់មាត្រា
យកខុសធ្វើត្រូវផ្គាប់តណ្ហា មិនគិតនរណាធ្វើតាមចិត្ត។
ស្តីពីពួកក្មេងឥឡូវផ្តាស ពូកែខ្លាំងណាស់ផ្លូវងងឹត
ប្រកាន់យល់ខុសអួតអាងសិទ្ធិ ធ្វើអ្វីមិនគិតវប្បធម៌ជាតិ។
បង្កើតស្នេហាប្រហារខ្លួន ឆ្លងរោគផ្ទួនៗអំពល់ញាតិ
វាយទាត់កាប់ធាក់ធឹកស្រាទៀត ចរិតមារយាទមិនគប្បី។
ប្រុសទុកសក់វែងក្រហមខៀវ តាំងខ្លួនធ្វើស្តាវឫករាជសី
បង្ហោះម៉ូតូអួតស្រីៗ ប្រកាច់ដេកដីក៏មានដែរ។
ដំណើរហោះហើរដើរខុសកាល ស្រីស្រាបណ្តាលភ្លេចឪម៉ែ
អ្នកផ្សារអ្នកក្រុងមិនចំស្រែ វល់ដើរញ៉ៅភ្លេចសិក្សា។
ខោអាវមិនដឹងលេងម៉ូតស្អី ប៉ោងគូថជើងខ្លីអាវវែនតា
ស្លៀកពាក់មិនសមជាខេមរា តែងខ្លួនម៉ាស្សាខាត់ស្បែកស។
ជាន់ឫកកាច់រាងផ្ទៀងនេត្រា បើប្រាប់ស្តីថាប្រកែកត
ដើរលេងយប់ថ្ងៃគ្មានរបរ ចិត្តខ្មៅខ្លួនសដូចកុកគ្រោង។
អ្នកខ្លះមិនខ្មាសខ្លួនជាស្រី ប៉ោងពោះឥតប្តីគ្មានគូគ្រង

ញៀនថ្នាំផឹកស្រាច្រៀងឡូងៗ ប្រព្រឹត្តខុសឆ្គងក្បត់មេបា។
កូនខ្លះម៉ែឱ្យទៅរៀនសូត្រ គេចខ្លួនរហូតពីសាលា
ពពាក់ពពូនតាមសួនច្បារ ក្លែមសាច់ផឹកស្រារាំញាក់ខ្ជូរ។
អាវសខោខៀវស្អាវពេញទី ឱបថើបញក់ញីតាមភ្លើងពណ៌ា
ម៉ូតូឌុបគ្នាហួសកុងទ័រ ប្រកាច់ស្លាប់ញ័រចោលទទេ។
រៀនឈ្នួលក្រៅម៉ោងកុហកម៉ែ នាំគ្នាទៅញ៉ៅមាត់ទន្លេ
ឱបរឹតអង្អែលមិនខ្មាសគេ មាត់ស្នឹងតាមឆ្នេរច្រើនស្អេកស្កះ។
ហ្វៃសប៊ុយលេងឆាតភ្លេចសូត្ររៀន រវល់ជាប់ញៀនហ្គេមផ្តេសផ្តាស
ទូរស័ព្ទទំនើបជាប់ពាក់ហ្កាស បទភ្លេងធុងបាសងក់តែក្បាល។
កូនរៀនមិនចេះបន្ទោសគ្រូ ថារៀនយូរៗគំនិតស្រាល
តាមពិតកូនគាត់មិនឈឺឆ្អាល រវល់ងប់ក្បាលឯណោះសោះ។
ខ្លួនធំដូចឈ្លោកគំនិតពាល ចេះស្ទើរព្រាលៗហួសពេលអស់
បែរឆ្វេងបាត់ស្តាំសែនក្រៀមក្រោះ បីដូចជាកោះនៅឯកា។
នេះស្តីពីក្មេងខុសឆ្គាំឆ្គង មិនតាមគន្លងលោកមេបា
មិនខុសតែក្មេងទេយាយតា ទោះចាស់ប៉ុនណាក៏ខុសដែរ។
ចាស់ខ្លះគាត់ខ្វះការយល់ដឹង ផឹកស្រាស្រវឹងលក់ដីស្រែ
ខឹងប្រពន្ធកូនដៀលពុកម៉ែ ដេញឆ្មាវាយឆ្កែប្រើហិង្សា។
តាខ្លះខ្លួនចាស់ចិត្តនៅក្មេង ច្រៀងរាំដើរលេងភ្លេចធម៌អាថ៌
ខ្លួនខ្ចីលបានអួតនិងឥស្សា ស្រវឹងឡូឡាជេរកូនចៅ។

យាយខ្លះខ្លួនចាស់ចិត្តនៅស្ទាវ ចង់ធ្វើជំទាវឱ្យគេហៅ
ខាត់ស្បែកត្រាំឡេខំលាបម្សៅ មុខសកខ្មៅដូចក្អែកព្រៃ។
ខ្ញុំថាហាក់ដូចជ្រុលទេដឹង អស់លោកកុំខឹងក្នុងហឫទ័យ
បើមានខុសខាតសូមអភ័យ នេះខ្ញុំលកលៃតាមចិត្តឯង។
ថាស្តីរៀបរាប់ចង់ឱ្យល្អ ខ្ពង់ខ្ពស់បវរគ្រប់កន្លែង
គឺគ្មានចេតនាដៀលសម្តែង ចង់ឃើញជាក់ស្តែងខ្មែរសុខសាន្ត។

ដោយសាមណេរ **សា ចាន់រ៉ាត់**

(ព្រះគាថាប្រារព្ធចំពោះអោធិរាជកុមារ)

អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ
តិណ្ណំ អញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ។

បើបណ្ឌិតដឹងថា ខ្លួនជាទីស្រឡាញ់ គួររក្សាខ្លួននោះឱ្យល្អ គួរសួនគ្រងខ្លួនទុកក្នុងវ័យទាំងបី វ័យណាមួយ។

If one knows that one is dear to oneself, one should protect oneself well. During any of the three watches (of life) the wise man should be on guard (against evil).

៣៨.តើសល់អ្វីខ្លះ?

(បទពាក្យជ្រាំពីរ)

អវិជ្ជាចងកម្មតួសង្ខារ ចំណងតណ្ហាចារទុក្ខខ្លាំង
សង្សារវែងឆ្ងាយមិនមានច្រាំង វស្សាឬប្រាំងក៏គ្មានដែរ។
កើតចាស់ឈឺស្លាប់សង្ខារជាក់ ជាប់ដោយត្រៃលក្ខណ៍តែងប្រួលប្រែ
ស្លាប់ទាំងអ្នកផ្សារចម្ការស្រែ ស្លាប់រាល់ថ្ងៃខែមិនចន្លោះ។
ក្តីស្លាប់ជាធម៌តែងមានពិត ទោះពាលបណ្ឌិតក្មេងកំលោះ
មានក្រសខ្មៅស្លាប់ទាំងអស់ ស្ត្រីបុរសតែងមរណា។
ក្តីស្លាប់គ្មានអ្នកណាចង់បាន ចង់តែសុខសាន្តគ្រប់រូបា
ចង់រស់បានយូរយូរវស្សា តែអនិច្ចាមិនដូចចិត្ត។
ជីវិតនៅមានកុំជាប់ធ្នាក់ មោហៈលោភៈក្រោធងងឹត
ជាប់ស្អិតក្នុងទ្រព្យនៃញាតិមិត្ត ចុងក្រោយប្រឌិតបោកប្រាសសោះ។
រស់រានមានទ្រព្យកុំភ្លេចទាន ឱ្យតាមធនធានដោយស្ម័គ្រស្មោះ
គឺមនុស្សទាំងឡាយស្លាប់ទាំងអស់ គិតចុះសប្បុរសសល់អ្វីខ្លះ?

ដោយសាមណេរ **សា ចាន់ណាត់**

៣៩.រូបកាន់តែចាស់ចិត្តកាន់តែក្មេង

(បទពាក្យជ្រាំបី)

បាយខុនចងដៃសំឡេងភ្លេងការ ឮច្បាស់កាលណាឱរាព្រួយភ័យ
នឹកឃើញកាលខ្លួនអាយុជាងម្តែ ចិត្តគិតលកលែចង់ការម្តងទៀត។
ខ្លួនកាន់តែចាស់មិនរៀនធម៌អាថ៌ ភ្នែកពាក់វ៉ែនតាមិនគិតខំឆ្លៀត
ក្បត់ប្រពន្ធខ្លួនលាក់ពួនចោលម្សៀត ល្បិចកល់ស៊ីកសៀតគឺលែងស្រីស្រា។
និយាយពីកូនប្រហែសមួយតៅ និយាយពីចៅរាប់ភ្លេចហើយណា
ខ្លួនឯងចាស់សោះស្នេហ៍តែកញ្ញា គេហៅខ្លួនតាឱ្យនាងហៅបង។
ពួកនាងបានលុយប្រចុំយហៅតាម ដោយសារញៀនញ៉ាមលុយកាក់បាត
មិនខ្មាសកូនចៅញាតិមិត្តអ្នកផង ប្រព្រឹត្តកន្លងតាមតែតណ្ហា។
ខារអូខេច្រៀងរាំឆ្លើយឆ្លង ស្រីញីអូនបងធឹកស៊ីតាមបា
កណ្តាលអធ្រាត្រស្រែកច្រៀងឡូឡា មកផ្ទះកាលណាបានរឿងតែម្តង។
បើប្រពន្ធស្តីរឹងរូសមិនស្តាប់ ម្តងនោះជិតស្លាប់បើកបុករបង
ប៉ូលីសទៅជួយខ្មាសគេកន្លង កូនយំរំពងចៅៗសើចតា។
ម្យ៉ាងទៀតបើសិនយាយបើកវិទ្យុ ដូចចាប់ដាក់គុកចិត្តមិនជ្រះថ្លា
បើឮចម្រៀងពីរឿងស្នេហា មុខរីកដូចផ្កាលង់តាមបទភ្លេង។
ចំណែកអ្នកខ្លះគេក៏ល្អដែរ ធ្វើបុណ្យរាល់ខែតាំងពីនៅក្មេង
ចិត្តគេនឹងធឹងមិនបានវង្វេង ឬគិតអ្វីផ្សេងក្រៅពីធម៌អាថ៌។
រីឯយាយខ្លះមិនដែលទៅវត្ត មើលតែចៅគាត់គ្មានខ្វល់នរណា
ខ្វល់តែការផ្ទះនិងកន្ត្រកស្លា ភ្លឺឡើងកាលណាមើលកូនជូនគេ។
នេះហើយរស់នៅដោយខ្វះប្រាជ្ញា កើតទាន់សាសនាមិនគិតរិះរេ
មិនខំសាងគុណធ្វើបុណ្យទុកទេ ខឹងអ្វីអាងជេរដូចនៅកុមារ។

ដឹងថាខ្លួនចាស់ម្តេចមិនសាងចិត្ត ធ្វើតែទុច្ចរិតដឹងចាំកាលណា
ប្រយ័ត្នស្លាប់ទៅរងទុក្ខសោកា សមដូចលោកថារូបចាស់ចិត្តក្មេង។

ដោយសាមណេរ **សា ចាន់រ៉ាត់**



(ព្រះគាថាប្រារព្ធចំអោះព្រះខ្ចបនន្ទសាក្យបុត្ត)

អត្តានមេវ បឋមំ បដិរូបេ និវេសយេ
អថញ្ញមនុសាសេយ្យ ន កិលិស្សេយ្យ បណ្ឌិតោ។

បណ្ឌិត គួរតម្កល់ខ្លួនទុក ក្នុងគុណដ៏សមគួរជាមុនសិន ហើយសឹមប្រៀនប្រដៅអ្នកដទៃ ជាខាងក្រោយ (ធ្វើយ៉ាងនេះ) នឹងមិនលំបាកឡើយ។

One should first establish oneself in what is proper; then only one should teach others. A wise man should not incur reproach.

៤0.ទំនួញដួនតា

(បទព្រហ្មគីតិ)

ពូជខ្មែរល្អថ្កើងថ្កាន　　គឺធ្លាប់បានល្បីល្បាញណាស់
ប្រាសាទក្បាច់ល្អល្អះ　　មីរដេរដាសពេញទឹកដី។
ផ្ទៃដីធំអស្ចារ្យ　　ព្រៃព្រឹក្សាស្រស់ប្រិមប្រិយ
ក្នុងទឹកសម្បូរត្រី　　ឯក្នុងដីសម្បូររ៉ែ។
ពូជខ្មែរមានភាសា　　ចេះរចនាអក្សរដែរ
ចេះដឹងគុណពុកម៉ែ　　ចេះមើលថែកេរ្តិ៍ដូនតា។
នេះខ្មែរសម័យមុន　　មិនស៊ីយស៊ុនខុសតម្រា
ធ្វើអ្វីស្តាប់មេបា　　កាន់សាសនាព្រះសម្ពុទ្ធ។
ខ្មែរមានវត្តអារាម　　ខ្មែរជឿតាមធម៌បរិសុទ្ធ
ទើបខ្មែរខ្លាំងបំផុត　　អាចរួចផុតពីឈ្លានពាន។
កូនអើយពេលឥឡូវ　　ខំរៀនទៅគ្រប់របៀន
ចំណេះដែលយើងមាន　　ទុកជាស្ពានឆ្លងអន្តរាយ។
ពេលនេះក្រតោកយ៉ាក　　ព្រួយលំបាកចិត្តខ្វល់ខ្វាយ
កុំចង់តែសប្បាយ　　លះចិត្តកាយទើបសុខសាន្ត។
ឥឡូវមានក្មេងខ្លះ　　គំនិតផ្តាសមិនថែប្រាណ
ញៀនថ្នាំកែលែងបាន　　ដូចគេច្រានធ្លាក់ក្នុងជ្រោះ។
អ្នកខ្លះញៀនស្រីស្រា　　ជក់យ៉ាម៉ាសាងបាបគ្រោះ
ស្រីខ្លះធ្វើជ្រុលជ្រួស　　មានផ្ទៃពោះឥតខាន់ស្លា។
ការងារធ្វើឡេះឡោះ　　មិនគិតសោះរឿងឧស្សាហ៍
តែងខ្លួនខំម៉ាស្សា　　ខាត់ស្បែកថ្លាបង្អួតប្រុស។

ស្លៀកពាក់ខើចស្តើងខ្លី ឃើញសាច់ខ្វីគ្មានដឹងខុស
សីលធម៌រឹតធ្លាក់ចុះ ម្តេចស្រីប្រុសមិនគិតផង?
កូនអើយថៃសាសនា ព្រះសម្មាល្អឥតហ្មង
រស់នៅស្តាប់ប្អូនបង ទើបនួនល្អងបានភ្លឺថ្លា។
អក្ខរាឪចារទុក រាយទំនុកជូនកនិដ្ឋា
កូនឪកុំភ្លេចណ៎ា ជួយខេមរាទាំងអស់គ្នា។
កូនអើយក្នុងលោកិយ ប្រុងស្មារតីគ្រប់វេលា
ខ្លួនល្អកុំនិន្ទា ថាគេទាខ្លួនឯងមាន់។
វេលាឪមានខ្លី កូនប្រុសស្រីស្តាប់ឱ្យទាន់
វប្បធម៌គ្រប់ជំនាន់ កូនកុំជាន់ដើរកន្លង។
ឪសូមជូនពរអ្នក មានបួនជាក់ណានួនល្អង
ធ្វើអ្វីគិតខ្មែរផង នេះបំណងឪណ៎ាកូន។

ដោយសាមណេរ **សា ចាន់ណាត់**

៤១.តើអ្នកបានអ្វី?

(បទពាក្យជ្រាំពីរ)

រឿងល្អកម្រសត្វលោកដឹង　　បើខុសវិញហ្នឹងលឿនរហ័ស
ធម៌ព្រះសម្តែងថ្លែងយ៉ាងច្បាស់　　កម្រដឹងណាស់ខុសមាត្រា។
ពាក្យពិតវែងស្លែងបើតាមដឹង　　ស្តីប្រាប់ទៅខឹងកើតទោសា
អ្នកអាងបង្កកើតហិង្សា　　និន្នាឥស្សាចងអាឃាត។
ការអួតជារឿងខ្វះសន្តោស　　ប្រកាន់យល់ខុសអន់មារយាទ
ប្រកាន់យកឈ្នះកើតវិវាទ　　នាំឱ្យឃ្លៀងឃ្លាតចាកបញ្ញា។
អួតអាងចង់ឱ្យគេសរសើរ　　ថាខ្លួនគ្រាន់បើខ្ពស់ថ្លៃថ្លា
មានះក្នុងខ្លួនផ្សំមោហា　　មើលងាយគេថាមិនស្មើខ្លួន។
ក្នុងលោកគ្មានអ្វីគួរយកឈ្នះ　　ទៀងតែវិនាសមិនមាំមួន
គ្មានទីកំបាំងរត់ជ្រកពួន　　មច្ចុអង្រួនផ្តាច់សង្ខារ។
រស់រៀនសាងបុណ្យអប់រំចិត្ត　　ប្រព្រឹត្តសុចរិតផ្តាច់តណ្ហា
កុំឱ្យកិលេសវាយប្រហារ　　ឈឺចាប់ចុកផ្សាក្នុងហឫទ័យ។
ការយកឈ្នះបាបទើបប្រសើរ　　ប្រៀបដូចជណ្តើរសួគ៌ាលៃ
ឯការយកឈ្នះអ្នកដទៃ　　ដូចធ្លាក់អវិចីទាំងរស់ហោង។

ដោយសាមណេរ **សា ចាន់ណាត់**



៤២.ឈ្នះចាញ់បានអ្វី?

(បទកាកគតិ)

ប្រកួតតតាំង តវ៉ាប្រឆាំង ច្បាំងយកឈ្នះចាញ់
ជាប់ស្អិតក្នុងរស ព្រោះតែចង់ឆ្ងាញ់ ចិត្តស្អប់ស្រឡាញ់
ទើបភ័យសោកា។
ព្រះពុទ្ធទ្រង់ត្រាស់ ព្រះធម៌យ៉ាងច្បាស់ ធម៌អនិច្ចា
ជីវិតមិនទៀង កុំប្រើហិង្សា ព្រោះក្នុងលោកា
គ្មានអ្នកឈ្នះទេ។
គ្រប់អស់អ្នកឈ្នះ តែងជួបប្រទះ ពៀរគ្មានទំនេរ
រីឯអ្នកចាញ់ គុំកួនខឹងជេរ ផ្តន្ទាយើងគេ
គ្រប់គ្រាយប់ថ្ងៃ។
អ្នកឈ្នះជាប់ពៀរ អ្នកចាញ់គ្រាំគ្រា ច្បាស់មិនសង្ស័យ
ឆ្អែតចិត្តក្តៅកាយ ស្ទើរស្លាប់ក្សិណក្សយ ព្រោះបាបចង្រៃ
ដុតរោលដួងចិត្ត។
ការចង់ចាញ់ឈ្នះ នាំឱ្យវិនាស កុសលសុចរិត

តណ្ហាទោសៈ មោហៈងងឹត មានៈខ្មៅពិត
ផ្តល់ទុក្ខសាមាន្យ។
អ្នកខ្លាំងអ្នកខ្សោយ នាទីចុងក្រោយ ត្រូវស្លាប់គ្រប់ប្រាណ
ប្រុសស្រីតូចធំ និគមភូមិឋាន រត់គេចមិនបាន
ពីក្តីមរណា។
រស់មិនរៀនសូត្រ ត្រូវលង់រហូត គឺគ្មានប្រាជ្ញា
រស់ចង់ឈ្នះគេ តែចាញ់អាត្មា បាបដុតប្រហារ
ឈ្នះចាញ់បានអ្វី?

ដោយសាមណេរ **សា ចាន់ភ័ត**



៤៣.ព្រមឬមិនព្រម?

(បទកាកគតិ)

រីបញ្ចក្ខន្ធ តែងតែប្រកាន់ រូបហើយនឹងនាម
ថាជាតួខ្លួន មាំមួននៅស្ងៀម សាច់ស្បែកឆ្អឹងឈាម
ថាទ្រព្យអាត្មា។
ការកើតតែងស្លាប់ ទោះយូរឬឆាប់ ជារឿងធម្មតា
មិនគួរប្រកាន់ ធម៌អនត្តា ចុងក្រោយមរណា
គ្រប់អស់យើងគេ។
សក់ខ្លៅប្រែស្កូវ ព្រមហើយឬនៅ មានដឹងខ្លួនទេ
រាងកាយទ្រុឌទ្រោម វ័យក៏ផ្តើមជ្រេ មិនគួរទំនេរ
សាងបុណ្យកុសល។
ធ្មេញរឹងសស្មោះ ឥឡូវបាក់អស់ ត្រចៀកឮខ្យល់
ភ្នែកប្រែស្រវាំង ទ្រូងសែនខ្វាយខ្វល់ នេះឯងលទ្ធផល
នៃច្បាប់សង្ខារ។
ទ្រព្យធនមានដែរ មាសប្រាក់ហូរហៃ ដីស្រែចម្ការ
ប្រពន្ធកូនប្តី ជីដូនជីតា ត្រូវព្រួយសោកា
ពេលព្រាត់ប្រាសគ្នា។
មានគូនឹងក្រ អាក្រក់គូល្អ ក្បត់ស្មោះគ្រប់គ្រា
សុខគូនឹងទុក្ខ សរសើរនិន្ទា លាភយសឈឺជា
តែងជួបរាល់ថ្ងៃ។
ការប្រកាន់ស្និទ្ធ បានត្រឹមខកចិត្ត ជួបទុក្ខពេកក្រៃ
ព្រោះអវិជ្ជា កំណាចព្រៃផ្សៃ កាត់ផ្តាច់និស្ស័យ

ឱ្យឆ្ងាយធម្មា។

ស្រឡាញ់ជាទុក្ខ	ស្នេហ៍ជាប្រមុខ	ភ័យព្រួយវេទនា
រស់ឆ្ងាយទានសីល	ជាប់ពៀរវេរា	ចុងក្រោយគ្រាំគ្រា
	ព្រោះខ្វះស្មារតី។	
រស់ទល់នឹងស្លាប់	ជាទល់ឈឺចាប់	នេះច្បាប់លោកិយ
គ្មានអ្វីតវា	ស្លាប់ទាំងប្រុសស្រី	ទុក្ខគ្មានប្រណី
	ព្រមឬមិនព្រម?	

ដោយ សាមណេរ សា ចាន់ន៉ាត់

(ព្រះគាថាប្រារព្ធចំពោះព្រះសម្ពុជនត្ថេរៈ)

បុព្វេ បមជ្ជិត្វា បច្ឆា សោ នប្បមជ្ជតិ
មំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា។

គ្គលណា កាលពីមុនប្រមាទហើយ លុះកាលជាខាង ក្រោយគេមិនប្រមាទវិញ បុគ្គលនោះឈ្មោះថា ញ៉ាំងខន្ធាទិលោកនេះឱ្យភ្លឺច្បាស់ដូចព្រះចន្ទរះផុតចាកពពក។

He, who has been formerly unmindful, but is mindful later on, lights up the world with the light of Magga Insight a; does the moon freed from clouds.

៤៤.ព្រះណាជួយបាន?

(បទពាក្យជ្រាំបី)

បាបបុណ្យសខ្មៅតូចធំផ្ទុយគ្នា នរកសួគ៌ាលង់ខ្លៅបណ្ឌិត
ទាបខ្ពស់លឿនយឺតកុហកប្រឌិត ខ្លីវែងឆ្ងាយជិតដឹងគ្រប់រូបា។
សូរិយាតែងរះនាទិសខាងកើត យប់ដប់ប្រាំកើតចន្ទរះភ្លឺថ្លា
រនោចងងឹតមានតែអន្ធកា ទោះហ្វូងតារាក៏គ្មានរស្មី។
ធម្មជាតិសុទ្ធសឹងរឿងស្មានមិនដល់ ស្មុគស្មាញសែនឆ្ងល់មិនយល់សេចក្តី
បញ្ញាទន់ទាបបរលោកលោកិយ នេះជនប្រុសស្រីកម្រដឹងពិត។
រកស៊ីមានក្រជារឿងដើមទុន រឿងបាបឬបុណ្យវែងនៅលើចិត្ត
បន់ស្រន់បួងសួងប្រាសចាកធម៌ពិត សច្ចៈមិនស្និទ្ធខ្វល់រឿងជឿគេ។
ផ្លូវសួគ៌និព្វានចង្អៀតទក់ៗ ឯផ្លូវនរកស្រស់ស្អាតម្ល៉េះទេ
សាសនានៅមានច្រើននៅទំនេរ បើផ្លូវនិរយលឿនមិនបាច់ប្រាប់។
គម្ពីរធម៌អាថ៌បិដកព្រះពុទ្ធ ថ្លៃថ្លាបរិសុទ្ធគឺជាក្បួនច្បាប់
មិនអានសូត្ររៀនត្រិះរិះខំស្តាប់ រហ័សប្រញាប់ជឿតែគ្រូទាយ។
ត្រចៀកនៅឮភ្នែកភ្លឺធ្វើខ្វាក់ អាគមផ្ទុំដាក់មន្តព្រាហ្មណ៍មន្តព្រាយ
បើប្រាប់ធម៌ពិតកាច់ករពេបជ្រាយ មានៈផ្សំលាយព្រះណាជួយបាន?

ដោយសាមណេរ **សា ចាន់ណាត់**



៤៥.តើចង់បានអ្វី?

(បទពាក្យជ្រាំបី)

បក្សីហោះហើរឥតស្គាល់អាកាស ផែនដីសែនក្រាសជន្លេនមិនដឹង
កង្កែបកូនក្អាត់រស់តែក្នុងបឹង ឥតស្គាល់ដំណឹងទន្លេសមុទ្រ។
សត្វជ្រូកមាន់ទារស់ភ្លេចថ្ងៃស្លាប់ ត្រូវបានម្ចាស់ចាប់ទើបភ័យតក់ស្លុត
រស់បានធំធាត់ស្លាប់ជៀសមិនផុត អាំងចៀនស្លដុតយកជាចំណី។
ថាសត្វធាតុទៅគ្នាគ្មានប្រាជ្ញា ចុះមនុស្សធម្មតាស្លាប់ព្រោះរឿងអ្វី
ប្រាថ្នាយសសក្តិសម្បត្តិសេដ្ឋី ភរិយាស្វាមីលុះភ្លេចមរណា។
ប្រាថ្នាចង់សុខតែមិនដឹងប្លង់ ប្រាថ្នាផូរផង់គ្មានប្រាជ្ញា
ចង់រួចពីទុក្ខតែជាប់តណ្ហា ឱ្យស្តាប់ធម៌អាចំថាគ្មានវេលា។
ចង់ធ្វើទានដៃរតែខ្វះធនធាន ប្រាថ្នានិព្វានតែខ្វះធម្មា
ចង់ជួបសុខស្ងប់តែជាប់វេរា ចង់ទៅសួគ៌ាថាជាប់កូនចៅ។
បើស្តាប់ធម៌ព្រះថាមារជ្រៀតជ្រែក យប់ថ្ងៃជាប់ដេកអាងថាល្ងង់ឆ្លៅ
ធ្វើអ្វីខុសឆ្គងអាងភ្លេចគោលដៅ បែបនេះលោកហៅតើចង់បានអ្វី។
ចង់នេះចង់នោះមិនចេះចប់សោះ ធិតក្បត់ស្ម័គ្រស្មោះគ្មាត្រាប្រណី
បើចង់ដូច្នេះហៅខ្វះស្មារតី ចង់គ្មានសិរីតើចង់បានអ្វី។

ដោយសាមណេរ **សា ចាន់ណាត់**



៤៦.ឆ្នាំថ្មីមនុស្សចាស់

(បទពាក្យជ្រាំបី)

អរុណពណ៌មាសជះចាំងរស្មី　　មកលើផែនដីនាព្រឹកព្រលឹម
បញ្ចេញរូបឆោមយាត្រាសន្សឹម　　ទៅទិសបស្ចិមជារឿងធម្មតា។
រីអស់មនុស្សសត្វកើតក្នុងលោកិយ　　តែងជាចំណីនៃក្តីមរណា
ក្មេងចាស់ឈឺស្លាប់គ្មានអ្វីតវា　　នេះឯងសង្ខារកើតហើយវិនាស។
ឆ្នាំចាស់ផ្លាស់ទៅឆ្នាំថ្មីមកដល់　　ចិត្តខ្វះកុសលខ្វល់ហើយរង្កៀស
អាយុត្រូវអស់គ្មានអ្វីយកឈ្នះ　　ស្លាប់គ្រប់តែផ្ទះរាល់ថ្ងៃខែឆ្នាំ។
ចូលដល់ឆ្នាំថ្មីភ្លេចថាវ័យចាស់　　គិតអ្វីផ្តេសផ្តាស់ភ្លេចពាក្យព្រះធ្មាំ
ដើរហើរលេងល្បែងស្រីញីស្រាថ្នាំ　　បើកុសលកម្មនឹកមិនឃើញទេ។
មកវត្តស្តាប់ធម៌ថារវល់ណាស់　　បើរាំធុងបាសទើបបានទំនេរ
បើហៅទៅបុណ្យថាជាប់ការគេ　　ជិះម៉ូតូជ្រៃតែងខ្លួនទៅបា។
បបួលធ្វើបុណ្យថាគ្មានលុយទេ　　ធឹកស៊ីប៉ាវគេសុទ្ធតែដុល្លារ
ឆ្នាំមុនឆ្នាំនេះមិនទាន់ជ្រះថ្លា　　ចាំអាយុហាទើបចង់ទៅវត្ត។
ធម៌តាមវិទ្យុចេះតែច្រឡំ　　ល្បែងស្រីស្រាផ្សំចេះតែចាំស្ទាត់
បើសូត្រធម៌ព្រះចេះតែភ្លាត់មាត់　　មិនដូចជាគាត់ម្នាក់ឯណោះសោះ។
បើសួរធម៌អាចំថាខ្ញុំនៅឆៅ　　មើលកូនថៃចៅនៅចាំទាំងអស់
ទូរទស្សន៍រឿងភាគចាំគ្មានចន្លោះ　　ប្តូរផ្តាច់ស្មុគ្រស្មោះគឺភ្លេចវត្តវ៉ា។
បើផ្លូវមកវត្តចេះតែវង្វេង　　តែបើផ្លូវផ្សេងគ្មានភ្លេចម្តងណា
អានសៀវភៅទាល់តែវ៉ែនតា　　តែបើចូលបាភ្លឺច្បាស់ដូចថ្ងៃ។
ពីមុនថាក្រមិនចង់ធ្វើទាន　　ឥឡូវនេះមានមាសប្រាក់ក្នុងដៃ
ធ្វើបុណ្យមិនកើតព្រោះខ្វះនិស្ស័យ　　ចិត្តបាបចង្រៃភ្លេចដល់ថ្ងៃចាស់។

មួយឆ្នាំកន្លងអាយុថយចុះ ចេះតែគិតខុសប្រព្រឹត្តផ្តេសផ្តាស
គិតថាខ្លួនធំសុខភាពមាំណាស់ គ្មានអ្វីប្តូរផ្លាស់ដូចលោកទេសន៍ទេ។
គួរអនិច្ចាឆ្នាំថ្មីមនុស្សចាស់ អ្វីៗប្តូរផ្លាស់គ្មានពេលទំនេរ
បើភ្លេចបុណ្យទានពិតធ្លាក់និរយៈ អ្នកអើយរិះរេធ្វើបុណ្យដាក់ទាន។
សិរីសួស្តីកើតពីធ្វើល្អ សន្សំធម៌សស្តាប់ព្រះទូន្មាន
លះបង់ចិត្តបាបគំនិតឈ្លានពាន ចូរខំសាងស្តានស្តាប់ធម៌ព្រះពុទ្ធ។

ដោយសាមណេរ **សា ចាន់ភ័ត**



អប្បកោ អយំ លោកោ តនុកេត្ថ ទិបស្សតិ
សកុណ្ដោ ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ។

លោកិយមហាជននេះ ជាមនុស្សងងឹត បណ្តាជនទាំងនេះ ជន តិចគ្នា ដែលឃើញច្បាស់ (នូវខន្ធាទិលោកនេះដោយអំណាច អនិច្ច លក្ខណៈជាដើម) ជនតិចគ្នា ដែលទៅកាន់ឋានសួគ៌ ដូចសត្វស្លាប (ដែល ជាប់សំណាញ់របស់ព្រានហើយ) តិចណាស់ ដែលរួចអំពីសំណាញ់ ដូច្នោះ។

Brind are the people of this world: only a few in this world see clearly (with Insight). Just as only a few birds escape from the net, so also, only a few get to the world of the devas, (and Nibbāna).

៤៧.ខ្ញុំថាហើយថា

(បទពាក្យជ្រាំពីរ)

លោកាប្រែថាវិនាសទៀង　　ជួនរាំងជួនស្ងៀងព្យុះសង្ឃរា
រាំងស្ងួតទឹកជន់គ្មានលោះគ្រា　　កើតស្លាប់តគ្នាក្នុងសង្សារ។
អវិជ្ជាវង្វេងឆ្វេងភ្លេចស្តាំ　　អំណាចតួកម្មភ្ជាប់តណ្ហា
ភពជាតិកំណើតផ្តល់ជីវ៉ា　　ឈឺជាមរណាកើតទុក្ខធំ។
បញ្ចក្ខន្ធមានតែរូបនិងនាម　　ដិតតាមទាក់ទាមប្រមូលផ្តុំ
ប្រកាន់ហួងហែងចំបែងផ្សំ　　ព្រាត់ប្រាសក្រៀមក្រំព្រួយគ្រាំគ្រា។
សង្ខារមិនទៀងតែងវិនាស　　គ្មានអ្វីយកឈ្នះមច្ចុរាជា
ស្លាប់ទាល់តែអស់គ្រប់ៗគ្នា　　បើមិនស្ទុះស្ទាតិចស្តាយក្រោយ។
ស្ទុះស្ទាគឺការសាងបុណ្យទាន　　លះបាបសាងស្ថានកុំបណ្តោយ
សីលត្រូវរក្សាទានត្រូវឱ្យ　　ស្លាប់ទៅតែសោយសុគ៌និព្វាន។
អ្នកខ្លះគេនាំទៅវត្តវ៉ា　　មិនចេះជ្រះថ្លាសាងសីលទាន
កំណាញ់រិះស្វិតជ្បិតចង់មាន　　ធ្វើបាបបំពានជ្បិតខ្លាចក្រ។
ហួងហែងប្រកាន់ស្រែចម្ការ　　មាសប្រាក់ដុល្លារមានដល់ក
មិនយូរប៉ុន្មានធ្លាក់ខ្លួនក្រ　　ឈឺស្លាប់ភ្នែកសថាហើយថា។

ដោយសាមណេរ **សា ចាន់ណាត់**



៤៧.ឥតដែនកំណត់

(បទពាក្យជ្រាំបី)

ជន្លេនរុកដីមិនដឹងជម្រៅ បក្សីហើរទៅមិនដឹងមេឃា
កើតទាន់សាសនាមិនដឹងធម្មា រស់បៀតបៀនគ្នានាំទុក្ខវែងឆ្ងាយ។
ស្លឹកឈើកម្រើកព្រោះវាតាបក់ ចិត្តកាចអាក្រក់នាំឱ្យខ្វល់ខ្វាយ
បើរស់សាងបាបទុក្ខឥតរសាយ ឈឺចិត្តក្តៅកាយជាផលទុច្ចរិត។
គ្រប់សត្វសង្ខារសទ្ធតែប្រែប្រួល មិនបានសុខស្រួលនៅក្នុងជីវិត
សរសើរនិន្នាលាភយសមានពិត សុខទុក្ខវិបរិតជាច្បាប់សង្ខារ។
ការកើតនិងស្លាប់កំណត់មិនបាន ស្លាប់លាចាកឋានមិនដឹងទៅណា
កន្លែងចោលសពគប់ដុតផ្តាប់ផ្ងារ កើតមនុស្សទេវតាតិរច្ឆានឬប្រេត។
ប្លង់ផ្លូវព្រះមាននិព្វានបើកទ្វារ ទានសីលភាវនានៅច្បាស់ក្រឡែត
សរសើរលាភយសមានបុណ្យជាហេតុ កុំចាំខ្លួនឆ្អែតទើបនឹកឃើញទាន។
អវិជ្ជាសង្ខារចារពីរឿងកម្ម ស្លាប់កើតលានឆ្នាំតាមខ្សែវិញ្ញាណ
រស់ឃ្លេទុក្ខច្រើនតាមឧបាទាន បើវៀរនិព្វានឥតដែនកំណត់។

ដោយសាមណេរ **សា ចាន់ណាត់**



៤៨.ប្រសិទ្ធិភាពនៃសម្តី

(បទពាក្យជ្រាំបី)

អំពៅស្ករត្នោតផ្អែមហើយបាត់ទៅ ទឹកឃ្មុំនោះកូវក៏ផ្អែមជាប់ចិត្ត

តែចាញ់សច្ចៈសម្តីពោលពិត ជាខ្លឹមជីវិតជាធម៌មិនស្លាប់។

មនុស្សមានតម្លៃអាស្រ័យសម្តី ទាក់ទងប្រុសស្រីត្រូវបានក្បួនច្បាប់

រក្សាពាក្យពិតដែលខ្លួនរ៉ាយរ៉ាប់ នេះគឺសាស័ព្ទពាក្យសត្យពាក្យសង្ឃ។

និយាយខ្លីខ្លឹមតាមភាពជាក់ស្តែង ពាក្យពិតវែងស្លែងតែត្រូវតាមប្លង់

មិនស្តីតាមហ៊ានពោលតាមចំណង់ សម្តីត្រូវត្រង់ជាប្លង់គុណគាប់។

ដោយសាមណេរ **សា ចាន់រ៉ាត់**



៤៩.ស៊ីជោរខុសរឿង

(បទពាក្យជ្រាំពីរ)

បញ្ឆោរលើកជើងដូចហ៊ឹងចង បើខុសបំណងដូចត្រីឆ្អើរ
បើពេញចិត្តវិញដូចគ្រាន់បើ បើពោលសរសើរឫកក្លាហាន។
បើខឹងច្រើនខូចប្រយោជន៍ធំ ប្រសិនបើយំលួងមិនបាន
បើខុសធ្លាក់ជ្រោះដូចគេច្រាន បើចង់មានបានផ្សំតណ្ហា។
បើចង់លឿនច្រើនតែផុតលេខ តែបើបានដេកភ្លេចធ្វើការ
បើខ្ជិលឡើងរឹលខូចបញ្ជា តែបើឧស្សាហ៍តែរឿងខុស។
បើកមាត់និយាយតែព្រោកប្រាជ្ញ បើបានអំណាចភ្លេចសន្តោស
បើបានជាត្រូវភ្លេចកំហុស បើបានជាចុះភ្លេចឡើងខ្ពស់។
បើបានជាស្អិតបេះមិនបាន ញៀនជាប់សន្តានគ្មានអ្វីជួស
បើបានជាឆ្ងាញ់ញៀនជាប់រស ទោះត្រូវធ្លាក់ជ្រោះក៏មិនដឹង។
ចិត្តអើយៗចិត្តផ្តិតចងពៀរ ម្តងឈឺម្តងជាឆ្លូតលាយខឹង
ស៊ីជោរខុសរឿងអារម្មណ៍ដឹង បើតែអ៊ីចឹងគ្មានសុខទេ។
នេះគឺមាយានៃដួងចិត្ត គ្មានក្តីអាណិតខ្លួនយើងគេ
ដុតរោលរាល់ថ្ងៃគ្មានទំនេរ ស៊ីជោរម្ល៉េះទេចិត្តអើយចិត្ត។

ដោយសាមណេរ **សា ចាន់ណាត់**



៥0.អន្តរាយគ្រប់យ៉ាង

(បទពាក្យជ្រាំពីរ)

តួកម្មតាក់តែងសត្វសង្ខារ　　កើតស្លាប់មរណាចារមិនទៀង
ប្រៀបដូចមេឃជួនរាំងជួនភ្លៀង　　មិនមានលំអៀងទៀងប្រាកដ។
សត្វនិងមនុស្សគ្មានអ្វីពូកែ　　ឈឺស្លាប់ហូរហែតាមកំណត់
ត្រូវព្រាត់ប្រាស់គ្នាសែនកម្សត់　　ខ្មៅសក្រខ្សត់ស្លាប់ដូចគ្នា។
ឈើខ្ពស់ថ្មរឹងបឹងសែនធំ　　សមុទ្រព្រៃភ្នំព្យុះសង្ឃរា
ពពករសាត់ជ្រែកមេឃា　　សូរិយោចន្ទ្រាគង់ប្តូរផ្លាស់។
ក្នុងលោកគ្មានអ្វីរត់ជ្រោកពួន　　បិតថេរមាំមួនអ្នកជាម្ចាស់
ត្រូវលះសម្បត្តិមាសប្រាក់កាស　　ក្មេងប្រែជាចាស់ឃើញរាល់ថ្ងៃ។
ប្រពន្ធកូនប្តីស្រែចម្ការ　　សូម្បីជីវាក៏ត្រូវក្ស័យ
សាច់ស្បែកឆ្អឹងឈាមគ្មានតម្លៃ　　ឈាមថ្លើមសរសៃក៏គ្មានន័យ។
នរណាក៏ដឹងកើតហើយស្លាប់　　ត្រូវឈឺចុកចាប់សែនព្រួយភ័យ
ទោះអ្នកស្រែផ្សារចម្ការព្រៃ　　ក៏ត្រូវមមៃខ្លាចស្លាប់ដែរ។
រឿងស្លាប់ហាមប្រាប់មិនបានទេ　　តាំងពីបុព្វេគ្មានពេលល្ហែ

ព្រាត់ប្រាស់ញាតិមិត្តកូនឃ្លាតម៉ែ ផ្លាស់ប្តូរប្រួលប្រែតែងវិបត្តិ។

ក្នុងលោកគ្មានអ្វីត្រូវតវ៉ា ជាច្បាប់សង្ខារបានបញ្ញត្តិ

ជរាព្យាធិតែងមកស្កាត់ មច្ចុតែងកាត់គ្រប់ជន្មា។

អវិជ្ជាតណ្ហាចារឿងកម្ម ស្មុគស្មាញសាំញ៉ាំសែនគ្រាំគ្រា

វិលវល់កើតស្លាប់គ្រប់ៗគ្នា តាមពេលវេលាបុណ្យខ្លួនមាន។

នេះគឺរឿងរ៉ាវរាប់រឿងពិត ស្តីតាមគំនិតបញ្ញាញាណ

បរមត្ថសច្ចៈព្រះទូន្មាន ទុកដូចជាស្ពានឆ្លងសង្សារ។

មុននឹងបិទភ្នែកលាចាកលោក គួរសាងជម្រកពូជសុខា

ចុងក្រោយអន្តរាយកុំភ្លេចណា ផ្លូវព្រះសម្មាកុំបោះបង់។

ដោយ**សាមណេរ សា ចាន់រ៉ាត់**



៥១.ឃើញគេល្អខ្លះផង

(បទព្រហ្មគីតិ)

បូញមាត់បត់ដុំដៃ ជាវិស័យនៃមនុស្សពាល
កិលេសឆេះរោលរាល ជេរចំទាលខ្វះមេត្តា។
ដឹងឮរឿងអ្នកផ្សេង ច្រើនវង្វេងកើតទោសា
មើលងាយដៀលគេថា អប្បបញ្ញាមិនស្មើខ្លួន។
មើលគេឃើញតែខុស មិនសន្តោសខឹងគុំកួន
បាបកម្មសាងផ្ងួន។ ទៅជាប់ជួនតែផ្លូវមារ។
មានៈធម៌មិនស្តាប់ ចោលក្បួនច្បាប់សាងវេរ
កពូនអវិជ្ជា ឆ្ងាយធម្មាពួនសាងកម្ម។
ធម៌អាថ៌ចេះតែភ្លេច ជេរប្រទេចចេះតែចាំ
ទោសគេយូរខែឆ្នាំ កត់ចំណាំពោលមិនឈប់។
រឿងល្អមិនចេះស្តី បាបអប្រិយមិនបញ្ឈប់
ចង់បានមិនចេះគ្រប់ ប្រឹងថ្ងៃយប់មិនចេះមាន។
ឃើញគេល្អខ្លះផង ក្រែងពៀរឆ្លងអន្តរធាន
រស់នៅមិនបៀតបៀន ទើបជាស្ថានឈានផុតទុក្ខ។

ដោយសាមណេរ **សា ចាន់ណាត់**



៥២.ឮធម៌នឹកបុណ្យ

(បទពាក្យជ្រាំពីរ)

សំឡេងបក្សាឮរងំ ពីរោះរណ្តំក្នុងសោតា
ឮហើយបាត់ទៅឥតខ្លឹមសារ បីដូចវេហាស៍ឥតកំណត់។
សំឡេងព្រះធម៌ញ៉ាំរជាប់ចិត្ត បកស្រាយរឿងពិតតាមបែបបទ
ផ្ទុយពីចម្រៀងច្រៀងស្មោះក្បត់ ធម៌ទៀងប្រាជកមិនចេះខុស។
កកើតមានកាយហៅសែនក្រ បានដោយផលល្អចងចាំចុះ
ព្រះពុទ្ធត្រាស់ដឹងប្រាប់ស្រីប្រុស សម្តែងធម៌ប្រោសវេនេយ្យសត្វ។
ព្រះធម៌ឃ្លាទើបមានម្តង ក្រក្រែកន្លងខ្សត់ពេកក្តាត់
បើបានស្តាប់ហើយស្បើយវិបត្តិ ជាមាគ៌ាស្ងាត់ផុតអន្តរាយ។
ព្រះធម៌កម្រសត្វដឹងណាស់ មិនងាយជាក់ច្បាស់នាមនិងកាយ
ច្រើនតែវង្វេងទៅអបាយ ជាប់ចិត្តស្អិតកាយក្នុងអវិចី។
ឮធម៌នឹកបុណ្យចិត្តជ្រះថ្លា វិស័យដូចផ្កាវីកថ្មីៗ
មានក្លិនក្រអូបនាលោកិយ ជនច្រើនបេតីតែងរាប់អាន។
វិស័យអ្នកមានធម៌ក្នុងខ្លួន ផុតទុក្ខផ្ងួនៗប្រេតតិរច្ឆាន
នាំឱ្យខ្ពង់ខ្ពស់សុខសួគ៌ស្ថាន ស្ងប់ចិត្តសុខប្រាណនិព្វានហោង។

ដោយសាមណេរ **សា ចាន់ណាត់**



៥៣.ចូរគិតថ្ងៃមួយណាកូន

(បទពាក្យជ្រាំបី)

ទឹកចិត្តស្នេហាប្រុសហើយនិងស្រី កើតក្នុងលោកិយពុំសូវខកខាន
ខ្លះស្នេហ៍តាមច្បាប់ចេះគិតសន្តាន មិនឱ្យរំខានដល់អ្នកដទៃ។
ចូរគិតថ្ងៃមួយដោយប្រុងស្មារតី កូនកុំគិតខ្លីធ្វើទោសសាងពៃរ៍
គឺថ្ងៃប្រសូតពុកម៉ែសែនភ័យ ទុក្ខឥតឧបមេយ្យណាកូនកនិដ្ឋា។
ឥឡូវរូបកូនក្រមុំកំលោះ មុខមាត់ស្រស់បស់ប្រៀបដូចបុប្ផា
ចេញដើរម្តងៗគួរឱ្យស្នេហា នរណាក៏ថាកូនអ្នកណាគេ។
កាលកូននៅតូចពុកម៉ែឱ្យរៀន ចំណេះរបៀនពុំសូវទំនេរ
ការងារស្រាលធ្ងន់មិនដែលប្រើទេ គឺឱ្យមាសមេរៀនដល់ថ្នាក់ខ្ពស់។
រូបកូននៅតូចពុកគិតនិងម៉ែ កូនធំផុតល្ហែរួចពីបាបគ្រោះ
ដឹងអីពេលនេះកូនបែរធ្វើហួស គឺកូនជ្រុលជ្រួសខុសប្រក្រតី។
ថ្ងៃក្តីស្រឡាញ់ដប់បួនកុម្ភៈ ពុកម៉ែសែនភ្ញាក់ស្ទើរភ្លឺកស្មារតី
កូនទិញកាដូផ្លែឈើទុំខ្ចី ស្មានជូនម៉ែឆីជូនមិត្តគេសោះ។
ព្រឹកឡើងទារលុយម៉ែឱ្យមិនស្តាយ ចិញ្ចឹមឆោមឆាយដោយចិត្តស្ម័គ្រស្មោះ
ឃើញចរិតកូនគិតអ្វីឡេះឡោះ ជ្រុលខូចខ្លួនអស់ពុកម៉ែលែងស្តី។
យប់មួយថ្ងៃមួយកូនហ៊ានតស៊ូ ជ្រើសរើសដៃគូមានប្រុសមានស្រី
ជូនផ្កាមួយទងប្តូរព្រហ្មចារី ផ្លាស់គំនិតថ្មីធ្វើតាមសម័យ។
ម៉ូតូឡូយឆាយកូនជិះឌុបគ្នា ជប់លៀងស្រាបៀរតាមសួនរញ៉ៃ
វប្បធម៌បរទេសហូរចូលរាល់ថ្ងៃ កូនមិនកែច្នៃគិតអ្វីល្អសោះ។
តាមផ្ទះសម្ភាក់ពេញប្រៀបដោយភ្ញៀវ ស្តីហ៊ោកញ្ជ្រៀវមុខមាត់ស្រស់បស់
ឮសំឡេងសើចចិន្តាក្រៀមក្រោះ វប្បធម៌គេសោះខំធ្វើម្លេះកូន។

រឿងល្អធ្វើចុះឪក៏មិនថា　　រឿងមិនបានការធ្លាក់ខ្លួនដល់សូន្យ
ចូរកូនរិះរេស្តាប់បងស្តាប់ប្អូន　　កុំឱ្យស្រពោនដូចបុប្ផាស្វិត។
កូនអើយចាំចុះមនុស្សក្នុងលោកា　　តែងមានស្នេហាតិចច្រើនដោយពិត
មិនមែនព្រហ្មណាជាអ្នកលិខិត　　គឺកម្មនោះពិតអ្នកចាត់ចែងយើង។
បន្តទៅនេះឪសូមរ៉ាយរ៉ាប់　　កូនស្រីចាំស្តាប់ឪមិនកាន់ជើង
ធម្មតាមានស្នេហ៍ក្តៅងំដូចភ្លើង　　កូនកុំពើតពើងតាំងខ្លួនជាស្នាវ។
មានរឿងហូរហែស្នេហាប្រុសស្រី　　មានរឿងចាស់ថ្មីដូចជាទុំទាវ
ប្តូរផ្តាច់ស្ម័គ្រស្មោះមិនមែនគិតព្រៀវ　　ក៏គង់ម្តាយទាវពង្រាត់កូនបាន។
ស្នេហាចៅចិត្រចារជាប្រវត្តិ　　កូនម៉ែកុំភ្លាត់បណ្តោយខ្លួនប្រាណ
កូនអើយបើស្នេហ៍ចូលស្តីកុំខាន　　រៀបការថ្មើរម៉ានចាស់ទុំដឹងឮ។
សម័យឥឡូវគឺជឿនលឿនមែន　　ម៉ែភ័យមែនទែនគឺរឿងជំងឺ
គ្រុនក្តៅរងាពុកម៉ែមិនព្រឺ　　រឿងមួយនោះគឺអេដស៍ណាមាសសួន។
ម៉ែចិញ្ចឹមកូនអស់ដប់ម្តែឆ្នាំ　　ឈឺចាប់រងកម្មមានក្រផ្នួន។
មិនអាណិតម៉ែសូមស្រណោះខ្លួន　　ណាស្រស់នឹមនួនកូនកុំបំភ្លៃ។
កូនកុំចង់សាកស្រីស្រាគ្រឿងញៀន　　នាំអន្តរធានទាំងនៅក្មេងវ័យ
ខូចការសិក្សាជួបបរាជ័យ　　ស្លាប់ទៅអវិចីតែងរងទុក្ខា។
កូនអើយធ្វើអ្វីគិតប្រពៃណី　　ខ្មែរល្អគ្មានពីរល្បីពេញលោកា
ខ្មែរមានទឹកដីអង្គរថ្លៃថ្លា　　ព្រមទាំងភាសាកូនថៃឱ្យគង់។
សាសនាយើងមានកូនរៀនគិតចុះ　　កុំដើរផ្លូវខុសរៀនកុំឱ្យល្ងង់
កូនកុំភ្លើតភ្លើនភ្លើងពណ៌នាំលង់　　ដូចកុកជាប់ជង់មិនផុតទុក្ខឡើយ។
សប្បាយមួយថ្ងៃទុក្ខមួយជីវិត　　នេះគឺរឿងពិតគិតចុះត្រាណាត្រើយ
ឪគ្រាន់តែប្រាប់ណែនាំឱ្យហើយ　　ក្រែងលោបានស្បើយផុតក្តីសោកា។

ស្តីដល់រឿងនេះឪនឹកពាក្យចាស់ ពិតប្រាកដណាស់លោកបានពោលថា
កសិករធ្វើស្រែនិងចម្ការ ខុសត្រូវម្តេចម្តាឆ្នាំក្រោយធ្វើទៀត។
ចំណែកយកគូគឺប្រពន្ធប្តី មិនមែនស្រួលស្អីខុសហើយចង្អៀត
ខូចខ្លួនខូចប្រាណប្លែកទាំងមារយាទព្រមទាំងពួកញាតិគេពោលដៀលស្តី។
ដូច្នេះកូនអើយមុនសម្រេចចិត្ត ព្រមស្ម័គ្រស្នេហ៍ស្និទ្ធកូនកុំគិតខ្លី
ឃើញភ្លាមស្នេហ៍ភ្លេតច្រើនដួលដេកដីចាស់គេយើងថ្មីគឺមើលមិនយល់។
កូនអើយស្តាប់ចុះឪមិនយកឈ្នះ ស្នេហ៍កាំរន្ធះច្រើនតែអំពល់
ស្នេហ៍ភ្លើងចំបើងឪសូមពន្យល់ ពិតគ្មានមង្គលទេណាពាលពៅ។
វាចាចុងក្រោយសូមទានអភ័យ បងប្អូនគ្រប់វ័យក្រែងលោមិនត្រូវ
តែទោះយ៉ាងណាសូមអ្នកត្រូវផ្លូវ ចេះស្តាប់ម៉ែឪជាតិខ្មែរថ្កើងថ្កាន។
ការពោលមកនេះមិនមែនទាំងអស់ តិចតួចប៉ុណ្ណោះដែលជ្រុលជ្រួសប្រាណ
បើបានស្តាប់ហើយកែខ្លួនកុំខាន សូមសុខក្សេមក្សាន្តក្នុងជីវិតអើយ។

ដោយសាមណេរ **សា ចាន់ណាត់**



៥៤.ត្រឹមតែជាសង្ខារ

(បទពាក្យប្រាំពីរ)

ឱះឱសង្ខារអ្នកតាក់តែង　　វិនាសហួតហែងគ្រប់សត្តា
កើតហើយស្លាប់វិញជាធម្មតា　　គឺអនិច្ចាមិនទៀងទេ។
បញ្ចក្ខន្ធគឺរូបហើយនិងនាម　　គ្មានអ្វីនៅស្ងៀមឱ្យទំនេរ
វិលវល់ជាទុក្ខទាំងយើងគេ　　សុខសួគ៌និរយេគ្មានចន្លោះ។
ធម៌អនត្តាមិនមែនខ្លួន　　ក៏មិនមាំមួនសូន្យសុងស្មោះ
ត្រឹមតែជាធាតុត្រូវក្រៀមក្រោះ　　វិនាសទាំងអស់គ្មានសល់ឡើយ។
ធម៌អាថ៌សាស្តាពោលសច្ចៈ　　សត្វលោកសែនខ្វាក់ឫកតោះតើយ
ដឹងថាកើតស្លាប់មិនរកត្រើយ　　រស់បែបនេះហើយស្អុយទាំងស្រស់។
មិនជឿធម៌ព្រះជឿតាមមារ　　ចុងក្រោយគ្រាំគ្រាស្លាប់ទាំងអស់
គុណមិនចម្រើនទោសទណ្ឌស្មោះ នេះហើយសប្បុរសគឺសង្ខារ។

ដោយសាមណេរ **សា ចាន់រ៉ាត់**



៥៥.មរតកជីវិត

(បទពាក្យជ្រាំពីរ)

ជីវិតជាការធ្វើដំណើរ អាក្រក់ប្រសើរស្រេចលើអ្នក
អារម្មណ៍ទាំងឡាយប្រៀបដូចធ្នាក់ ទាញសត្វទម្លាក់ក្នុងសង្សារ។
ឱត្រៃលក្ខណ៍ធម៌ទ្រព្យជីវិត ប្រែប្រួលវិបរិតគ្រប់សង្ខារ
មិនអាចឃាត់ឃាំងសូមតវា កើតចាស់មរណាទាំងប្រុសស្រី។
រីឯទុក្ខមិនងាយទ្រាំ តែងតែដឹកនាំសត្វលោកិយ
ឱ្យរងសោកសៅក្នុងភពបី នរកអវិចីមនុស្សទេវតា។
ឱៈឱអ្វីៗមិនមែនខ្លួន គ្មានអ្វីមាំមួនអនត្តា
មរតកជីវិតគ្មានខ្លឹមសារ ត្រឹមជាសង្ខារកើតហើយស្លាប់។
ធ្មេញបាក់សក់ស្កូវរូបជរា មិនអាចការពារទោះយូរឆាប់
គួរសាងបុណ្យទានឱ្យប្រញាប់ ព្រោះពេលជិតស្លាប់មកដល់ហើយ។
គ្មានអ្វីប្រសើរជាងធម៌ព្រះ គ្មានអ្វីយកឈ្នះមច្ចុឡើយ
គួរពឹងត្រៃរតន៍ទើបបានស្បើយ អាចនាំដល់ត្រើយផុតទុក្ខ។
ធម្មតាមានរូបតែងមានរោគ សប្បាយវិយោគជាធម្មតា
បើរស់ខ្វះសីលគ្មានប្រាជ្ញា បែបនេះលោកថារស់ដូចស្លាប់។
ឥឡូវសាសនាតែងមាននៅ គួរស្វែងរកផ្លូវឱ្យប្រញាប់
ធម៌អាថ៌នៅមានចូរខំស្តាប់ បាលីសារសព្វលោកបរិយាយ។
រស់ហើយមិនសាងបុណ្យកុសល ច្បាស់ជាខ្វាយខ្វល់ក្នុងអបាយ
រមែងទុក្ខសោកក្តៅក្រហាយ ព្រោះតែសោកស្តាយភ្លេចស្មារតី។
នរជនណាមានគំនិត រៀនសូត្រធម៌ពិតព្រះជិនស្រី
រមែងឆ្លងផុតភពទាំងបី ដល់ព្រះបុរីនិព្វានជាក់។

ព្រះធម៌ប្រៀបដូចជាអន្លង សម្រាប់ទូងឱ្យសត្វភ្ញាក់
កុំឱ្យកិលេសទាញទម្លាក់ ធម៌ប្រាប់ជ្រៅរាក់ឱ្យដឹងច្បាស់។
ស្តាប់ធម៌រាល់ថ្ងៃកុំវង្វេង កុំអាងថាក្មេងមិនទាន់ចាស់
ព្រោះពេលឥឡូវស្លាប់ច្រើនណាស់ ក្មេងច្រើនជាងចាស់ក៏មានដែរ។
រៀបរាប់មកនេះចង់ឱ្យល្អ ខ្មៅប្រៃជាសណាពុកម៉ែ
មរតកជីវិតស្លាប់ហូរហែ ដូច្នេះគួរតែសាងសុចរិត។
ប្លង់ផ្លូវព្រះមានរៀនគិតចុះ បើពោលទៅខុសសូមអាណិត
បើយល់ថាត្រូវកុំបែកចិត្ត មរតកជីវិតយ៉ាងនេះឯង។

ដោយសាមណេរ **សា ចាន់ណាត់**

(ព្រះគាថាប្រារព្ធចំពោះព្រះខទិរវនិយអវត្ថេរ)

គាមេ វា យទិ វារញ្ញេ
និន្នេ វា យទិ វា ថលេ
យត្ថ អរហន្តោ វិហរន្តិ
តំ ភូមិរាមណេយ្យកំ។

ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា ទោះជាស្រុកក្តី ព្រៃក្តី ទីទាប ក្តី ទីទួលក្តី ទីនោះឯង ជាភូមិគួរត្រេកអរ។

In a village or in a forest, in a valley or on a hill, wherever arahat dwell, that place is delightful.

៥៦.ទម្បធម៌គេទេក្មួន

(បទពាក្យជ្រាំបី)

អក្ខរាវៀបរាប់ប្រាប់ជាដំណឹង ឱ្យក្មេងចាស់ប្រឹងថែរក្សាទម្បធម៌ជាតិ
សាមគ្គីរួបរួមបន្តយវិវាទ ចរិតមារយាទកុំឃ្លាតពីខ្មែរ។
ទម្បធម៌ភាសាសាសនាព្រះពុទ្ធ ថ្លៃថ្លាវិសុទ្ធលំអុតពុកម៉ែ
វិជ្ជាសិល្បៈចម្លាក់ហូរហែ ប្តូរផ្តាច់មើលថែមរតកដូនតា។
ស្លៀកពាក់ដើរហើរដំណើរភុជង្គ នៅក្មេងចំទង់កុំភ្លេចសិក្សា
រៀនលេខនព្វន្តក្បួនច្បាប់មាត្រា ស្វាហាប់ឧស្សាហ៍ហានក្លាជានិច្ច។
សម្បត្តិធនធានខ្មែរមានមិនខ្វះ រ៉ែមាសប្រាក់កាសរ៉ែត្បូងនិងពេជ្រ
ព្រៃឈើប្រាសាទក្បាច់ល្អរំលេច ចងចាំជានិច្ចកុំភ្លេចស្មារតី។
ស្ទឹងបឹងទន្លេឆ្នេរសមុទ្រស្អាត ទេសចរសង្វាតមកទាំងប្រុសស្រី
តាមឆ្នេរសមុទ្រស្រស់ស្អាតប្រិមប្រិយ លក់នំចំណីសេដ្ឋកិច្ចធូរធារ។
មច្ឆាគង្គាអរាច្រើនណាស់ ស្រែកផ្តាំក្មេងចាស់ឱ្យថែការពារ
បក្សីអរាំផ្គោះផ្គងរកគ្នា បក្សាយំទារស្រែករកអ្នកជួយ។
ឈប់ស្លេះប៉ុណ្ណឹងនឹងប្រាប់រឿងផ្សេង ណែនាំក្មេងៗទុកជាជំនួយ
វេលាមានខ្លីជីវិតតែមួយ រាល់ថ្ងៃខ្វល់ព្រួយវប្បធម៌បរទេស។
វប្បធម៌បុរាណខ្មែរល្អគ្មានពីរ មានប្រពៃណីសាកសមវិសេស
ឃើញក្មេងឥឡូវច្រើនធ្វេសប្រហែស ខ្លួនមានចំណេះតែធ្វេសគំនិត។
ស្លៀកពាក់ខើចខ្លីសម្តីហួសមាឌ បរទេសខំឆ្លៀតផ្សាយរឿងងងឹត
វប្បធម៌លីលាសាសនាប្រឌិត ឱ្យខ្មែរបាក់ចិត្តភ្លេចកេរ្តិ៍ដូនតា។
ដប់បួនកុម្ភៈជាធ្នាក់អវិចី អស់ព្រហ្មចារីក្បត់លោកមេបា
កាដូតិចតួចកួចផ្សំបាច់ផ្កា ជប់លៀងហ៊ីហាឡើងសណ្ឋាគារ។

កុលាបមួយទងនួនល្អងទន់ចិត្ត ស្ម័គ្រស្មោះស្នេហ៍ស្និទ្ធខ្លះឆ្លងរោគា
កើតអេដស៍នៅក្មេងចោលម្តាយពុំងា ហក់លោតរកគ្នាហាក់ដូចខ្វះស្មារតី។
ម្តៃប្រាំខែធ្នូបុណ្យយេស៊ូសោះ ក្រមុំកំលោះភ្លូកទឹកភ្លូកដី
វប្បធម៌គេផ្សេងវង្វេងស្មារតី ឈ្លក់សម័យថ្មីគ្មានដឹងខ្មៅស។
ខ្លួនសចិត្តខ្មៅប្រដៅមិនស្តាប់ ឫកពាសែនយ៉ាប់អាក្រក់ថាល្អ
ខុសចិត្តមេបាខេមរាបវរ ញាក់ភ្នែកកាច់កខុសវប្បធម៌ខ្មែរ។
វប្បធម៌គេទេមាសមេកុំចង់ ផ្លូវរៀចកុំបង់ផ្លូវត្រង់ត្រូវថៃ
ខ្ញុំថាតាមដឹងកុំខឹងពុកម៉ែ ដឹងខុសត្រូវកែបើល្អធ្វើចុះ។
នៅទីបញ្ចប់ម្រាមដប់លើកផ្តុំ ពាក្យមិនសមរម្យក្រែងមានកំហុស
ខុសខាតលើសលោះខន្តីស្រីប្រុស មេត្តាសន្តោសកវីផងទាន។

ដោយសាមណេរ **សា ចាន់រ៉ាត់**



៥៧.សាងអ្វីបាននោះ

(បទពាក្យជ្រាំបី)

សម្តីមិនប្រែដៃខ្ញុំមិនវែង គេថាខ្ញុំឆ្វែងព្រោះគេនៅស្តាំ
បញ្ញានៅខ្វៃលៃតាមចំណាំ គំនិតសាំញ៉ាំផ្តែផ្តាំតាមដឹង។
ព្រះពុទ្ធគ្រប់អង្គផ្សរផង់បារមី លះកាត់លោកិយស្មារតីរឹងប៉ឹង
ទ្រង់ត្រាស់សម្តែងថ្លែងប្រាប់ទីពឹង ឱ្យសព្វសត្វប្រឹងដឹងសច្ចៈធម៌។
រីធម៌ទាំងឡាយក្លាយមកពីហេតុ ឃើញច្បាស់ក្រឡែតផុតការញាប់ញ័រ
ទិដ្ឋិប្រកាន់ដូចស្វាជាប់ជ័រ គួបផ្សំលោកធម៌ញ៉ែរញាក់សង្ខារ។
សាងសីលឱ្យទានជាស្ពានបណ្ឌិត រស់សាងសុចរិតជីវិតស្រស់ថ្លា
ស្តាប់ធម៌ហើយគិតចម្រើនបញ្ញា លោភៈទោសាមោហាអន្តរាយ។
សាងបាបខ្លួនឯងថ្លែងឱ្យព្រះជួយ បន់សូមជំនួយជួយឱ្យសប្បាយ
រឿងនេះគួរស្តុតមិនផុតអបាយ ឈឺចិត្តក្តៅកាយក្រហាយចាញ់បោក។
ធ្វើបាបបានបុណ្យធុនអន់បញ្ញា ជឿពាក្យឃោសនាចង់សុខបានសោក
ចង់សើចបានយំទុក្ខធំវិយោគ ដឹងហើយឆាប់ក្រោករស់រៀនធម៌អាថ៌។
ធ្វើល្អបានល្អបវរភាសិត ត្រាស់ដឹងធម៌ពិតដឿតពូជបញ្ញា
សាងអ្វីបាននោះចងចាំចុះណា លុះអរហន្តាទើបជាសុខពិត។

ដោយសាមណេរ **សា ចាន់ណាត់**



៥៨.ត្រឹមតែជាខ្យល់មាត់

(បទពាក្យជ្រាំបី)

ពពកសខ្មៅស្កិតលើវេហាស៍ ដួងព្រះសូរិយាដួងព្រះចន្ទ្រា
ទឹកដីភ្លើងខ្យល់អស់សត្វនានា ត្រូវមនុស្សនិន្ទាសរសើរធម្មតា។
រឿងពាក្យសម្តីមិនអាចប្រាកដ គ្មានដែនកំណត់ឱ្យត្រូវចិន្តា
កុហកបោកប្រាសខុសពីសច្ចា ត្រូវចងចាំថាត្រឹមជាខ្យល់មាត់។
គេថាគេស្តីតាមតែគំនិត ស្តាប់ឮហើយគិតកុំឱ្យមានភ្លាត់
ធ្វើគថ្លង់ខ្វាក់អប់រំហាមឃាត់ កុំខឹងតាមមាត់អ្នកពោលស្តីថា។
សរសើរនិន្ទាមានពីបុរាណ ហាមឃាត់មិនបានត្រូវចង់ចាំណា
ម្នាក់ថាម្នាក់ខឹងមួយណាអស្ចារ្យ តាមពិតលោកថាបាបដូចតែគ្នា។
គេថាកុំខឹងត្រូវប្រឹងខំអត់ ខន្តីប្រាកដផ្តាច់ពៀរវេរា
បើពាក្យណាល្អសឹមយកជាគ្នា ពោលតាមធម្មថាសុភាសិត។
បានកើតជាមនុស្សគួរតែសាងល្អ សន្សំធម៌សគឺពោលពាក្យពិត
កុំញុះញង់គ្នានាំបែកញាតិមិត្ត គួរសាងសុចរិតទៅសួគ៌ាឋាន។
រីពាក្យសម្តីមានទាបមានខ្ពស់ កុំពោលទ្រគោះនាំឱ្យថោកប្រាណ
ស្លាប់ទៅសោយទុក្ខពេកពន់ប្រមាណ អស់ញាតិសន្តានគួរពោលតែពិត។

ដោយសាមណេរ **សា ចាន់ណាត់**

៥៩.ជីវិតគឺត្រៃលក្ខណ៍ធម៌

(បទកាកគតិ)

ឱពេលវេលា តែងតែទំពា ស៊ីសត្វទាំងឡាយ
ស៊ីទាំងខ្លួនឯង ក្រមុំមេម៉ាយ ស៊ីរាល់រូបកាយ
ឥតមានចន្លោះ។
វេលាកន្លង ព្រាត់ញាតិប្អូនបង គ្មាននឹកស្រណោះ
វេលាតែងញាំង អ្វីៗទាំងអស់ នារីកំលោះ
ក៏វាស៊ីដែរ។
គួរអនិច្ចា គ្រប់អស់សត្តា ផ្លាស់ប្តូរប្រួលប្រែ
ជរាព្យាធិ ខិតជិតហូរហែ ទុក្ខរាល់ថ្ងៃខែ
គ្មានដំណោះស្រាយ។
ធម៌ឈ្មោះទុក្ខំ គ្មានអ្វីតតាំង មានតែអន្តរាយ
ជាចំណងមារ ចងមិនងាយស្រាយ សត្វគ្រប់រូបកាយ
តែងជួបប្រទះ។
ឱអនត្តា មិនមែនអាត្មា គួរឱ្យរង៊ៀស
ប្រែប្រួលមិនទៀង ខ្លាំងដូចរន្ទះ មិនអាចយកឈ្នះ
ត្រៃលក្ខណ៍ធម៌ឡើយ។
ខ្លឹមសារជីវិត បើតាមធម៌ពិត គឺគុណនេះហើយ
បញ្ញាកើតឡើង ទើបអ្នកបានឡើយ រស់បានឃើញត្រើយ
គឺព្រះនិព្វាន។
រស់កុំប្រមាទ ឧស្សាហ៍សង្វាត ចិត្តបាបរយលាន
លះអវិជ្ជា សាងបញ្ញាញាណ ពិសេសសាងស្ពាន

គឺបុណ្យកុសល។

បើដឹងកើតស្លាប់	គួរតែប្រញាប់	លះគ្រឿងខ្វាយខ្វល់
ទិដ្ឋិមានៈ	តណ្ហាដូចខ្យល់	ដុតរោលគ្មានសល់
	ប្រាថ្នាឥតឈប់។	
រស់រយវស្សា	លង់គ្មានប្រាជ្ញា	ងងឹតដូចយប់
បានមិនចេះស្កប់	មានមិនចេះគ្រប់	វិលវល់ក្នុងភព
	ឥតដែនកំណត់។	
រស់សាងប្រាជ្ញា	ដោះស្រាយបញ្ហា	តាមធម៌ប្រាកដ
ទានសីលជាហេតុ	ខន្តីអំណត់	មគ្គដល់ប្រាកដ
	ទើបរស់បានសុខ។	

ដោយសាមណេរ **សា ចាន់រ៉ាត់**

(ព្រះគាថាប្រារព្ធចំពោះខ្មួយសថកម្ម)

យថា ទណ្ឌេន គោបាលោ គាវោ បាជេតិ គោចរំ

ឯវំ ជរា ច មច្ចុ ច អាយុំ បាជេន្តិ បាណិនំ។

គង្វាលគោ រមែងកៀងគោទៅកាន់ទីគោចរដោយអាជ្ញា ដូចម្តេច មិញ ជរា និងមច្ចុ តែងកៀងអាយុរបស់សត្វទាំងឡាយ ដូច្នោះឯង។

As with a stick the cowherd drives his cattle to the pasture, so also, Ageing and Death drive the life of beings.

៦០.អត់ធោសដូនបុណ្យ

(បទព្រហ្មគីតិ)

រៀបរាប់ប្រាប់កាត់ៗ សូមលើកហត្ថឱនសិរសា
ខុសខាតសូមមេត្តា កុំឡួឡាទានប្រណី។
រឿងពិតប្រាប់តាមដឹង គ្មានកំហឹងនិន្ទាស្តី
ខុសឆ្គងយកធ្វើអ្វី ដ្បិតគិតខ្លីខ្វីប្រាជ្ញា។
ថ្លាថ្លែងតាមគំនិត ជូនញាតិមិត្តពិចារណា
ចារចែងរឿងសាសនា ប្រាប់ខេមរាថាឱ្យដឹង។
វប្បធម៌ខ្មែរល្អណាស់ ប្រាប់ចាស់ៗឱ្យក្មេងប្រឹង
សៀវភៅចារដំណឹង ដាច់ខ្យល់ភឹងសល់អក្ខរា។
សូមជូនបុណ្យកុសល ចូរមានដល់លោកយាយតា
បងប្អូនជនខេមរា សូមសុខាកុំមានពៀរ។
សុខសួគ៌ផុតអវិចី កុំមានភ័យមកពាធា
សាមគ្គីកុំឈ្លោះគ្នា លុះដល់គ្រាជីវិតក្ស័យ។

ដោយសាមណេរ **សា ចាន់ភ័ត**



សៀវភៅដែលរៀបរៀងដោយខ្ញុំព្រះករុណា
សាមណេរ សា ចាន់ង៉ាត់

១.បញ្ហាជីវិត និងព្រះធម៌ (ព.ស. ២៥៥៤)
២.ខ្ញុំតែងជូនអ្នក (ព.ស. ២៥៥៤)
៣.គួរសិក្សាធម៌ (ព.ស. ២៥៥៥)
៤.កម្រងអក្ខរា (ព.ស. ២៥៥៥)
៥.ទឹកចិត្តអ្នកម្តាយ (ព.ស. ២៥៥៥)
៦.ទំព័រជីវិត (ព.ស. ២៥៥៦)
៧.ទស្សនអប់រំ (ព.ស. ២៥៥៦)
៨.កំណាព្យតបគុណ (ព.ស. ២៥៥៦)

☞ ស្នាដៃសមណៈ (ត្រៀមនឹងចេញផ្សាយ ខ្នាត ១៦ X ២៣ cm មានកម្រាស់ជាង ៥០០ ទំព័រ ក្របក្រាស់រឹងដូចព្រះត្រៃបិដក)។

☞ ឈ្មួលគ្នាក់ខ្លួនឃើយ (ត្រៀមនឹងចេញផ្សាយ ខ្នាត ១៥ X ២១ cm មានកម្រាស់ប្រហែល ១៦០ ទំព័រ មានក្របទន់ធម្មតា)។

☞ គង់មានថ្ងៃមួយ (ត្រៀមនឹងចេញផ្សាយ ខ្នាត ១៥ X ២១ cm មានកម្រាស់ប្រហែល ១៦០ ទំព័រ មានក្របទន់ធម្មតា)។



ឆាមពុទ្ធបរិស័ទចូលរួមបោះពុម្ពសៀវភៅនេះ

-សាមណេរ សា ចាន់វ៉ាត់...៥០ក្ប -ឧ.សិ. អៀម វ៉ាន.....២

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះពុទ្ធបរិស័ទទាំងអស់ដែលបានបរិច្ចាគថវិកា ដើម្បីឧបត្ថម្ភក្នុងការបោះពុម្ពសៀវភៅនេះ និងសៀវភៅក្រោយៗទៀតរបស់ «ក្រុមឃុវសមណាអ្នកនិពន្ធ»។

សូមជូននូវព្រះពុទ្ធពរទាំងឡាយ ៤ ប្រការគឺ: អាយុ ១ វណ្ណៈ ១ សុខៈ ១ ពលៈ ១ ព្រមទាំងសម្បត្តិទាំងឡាយ ៣ គឺសម្បត្តិមនុស្ស ១ សម្បត្តិទេវតា ១ និងសម្បត្តិព្រះនិព្វាន ១ ចូរកើតមានដល់ពុទ្ធបរិស័ទ កុំបីប្រែក្លាយទៅជាប្រការដទៃឡើយ។

សូមអនុមោទនា! សូមអនុមោទនាបុណ្យ!! សូមអនុមោទនាមហាកុសល!!!

បញ្ជាក់: សៀវភៅមួយក្បាលតម្លៃ ៣.៣០០ រៀល

ក្រុមគ្រួសាររបស់កុមារ **សា ចាន់ង៉ាត់** ថតក្នុងឆ្នាំ ១៩៩៣



ម៉ែគឺជាព្រះរបស់កូន
ម៉ែគឺជាព្រះក្នុងលោកិយ
ម៉ែជាព្រះព្រហ្មសែនកម្រ
ម៉ែថ្នមរូបកូនលើសបានមកុដ
ម៉ែមិនឱ្យកូនធ្វើអាក្រក់
ម៉ែជាគ្រូពេទ្យនៅចាំថែ

ម៉ែគឺជាក្បូននៃប្រុសស្រី
ម៉ែប្រោសប្រណីចិញ្ចឹមបុត្រ។
ម៉ែមានចិត្តល្អថ្លៃវិសុទ្ធ
ម៉ែស្មោះបំផុតមិនគេចកែ។
ម៉ែជូនមរតករាល់ថ្ងៃខែ
ម៉ែបើកប្រាក់ខែឱ្យកូនចាយ។

ដោយសាមណេរ **សា ចាន់ង៉ាត់**

MP Printing House
អាងពុម្ព ម៉ៅ ផុន
MAO PHON Printing House

ISBN-9789996331398